ព្រះរាជាណាចក្រកម្ពុជា

មន្ទីរអប់រំយុវជននិងកីឡារាជធានីភ្នំពេញ

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាជំនាន់ថ្មី វិទ្យាល័យព្រែកលៀប

៣✵៣

# ស្នាដៃចូលរួមអបអរសាទរ ទិវាជាតិអំណានលើកទី៧

## លើប្រធានបទ

# "តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ"


បេក្ខជន **ជក់ សុភា** ភេទប្រុស កើតនៅថ្ងៃ៣ ខែមិថុនា ឆ្នាំ១៩៩៦

ជាបង្រៀននៅ សាលាជំនាន់ថ្មី វិទ្យាល័យព្រែកលៀប រាជធានីភ្នំពេញ

ទូរសព្ទ៖ 086 204 699



ព.ស. ២៥៦៥ គ.ស. ២០២២

# មាតិកា

**សេចក្តីផ្តើម**

**១-ការវិវត្តនៃអក្សរសិល្ប៍ក្រោយសម័យអង្គរ**.....២

១.១-អក្សរសិល្ប៍លើសិលាចារឹក.....៣

១.២-អក្សរសិល្ប៍លើសាស្ត្រា.....៣

១.៣-អក្សរសិល្ប៍លើក្រាំង.....៦

**២-ឥទ្ធិពលពុទ្ធសាសនាក្រោយសម័យអង្គរ**.....៧

២.១-ពុទ្ធសាសនាក្នុងសង្គមខ្មែរ.....៧

២.២-ឥទ្ធិពលពុទ្ធសាសនាមកលើអក្សរសិល្ប៍ខ្មែរ.....៧

**៣-អក្សរសិល្ប៍ពុទ្ធនិយម**.....១០

៣.១-ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម.....១០

៣.២-តំណែងនិពន្ធនៃរឿងបែបពុទ្ធនិយម.....១១

ក-ផ្តើមរឿង.....១១

ខ-ដំណើររឿង.....១២

គ-បញ្ចប់រឿង.....១៣

**៤-តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ**.....១៤

៤.១-ការអប់រំចរិយាសាស្ត្រ.....១៤

ក-សីលធម៌.....១៥

ខ-គុណធម៌.....១៩

៤.២-ការបណ្តុះស្មារតីសន្តិភាព.....២៣

៤.៣-ការបណ្តុះពុទ្ធិស្មារតី.....២៧

៤.៤-ឥទ្ធិពលទស្សនវិជ្ជាពុទ្ធសាសនាក្នុងការអប់រំចរិយាសាស្ត្រ.....៣០

ក-ទស្សនៈកម្ម-ផល.....៣០

ខ-បញ្ចសីល.....៣៣

៤.៥-តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្នុងវិធីតំណែងនិពន្ធវណ្ណកម្មខ្មែរ.....៣៨

ក-កម្រងកែវ បទកាព្យ.....៣៨

ខ-រូប្បារូបារម្មណ៍.....៣៩

៤.៦-តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាក្នុងការផ្សព្វផ្សាយវប្បធម៌.....៣៩

ក-ជំនឿ.....៣៩

ខ-ទំនៀមទម្លាប់ប្រពៃណី.....៤១

គ-សិល្បៈ......................................................................................................................................៤២
៤.៧- តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាមកលើសង្គមខ្មែរនាពេលបច្ចុប្បន្ន........................................៤៣
ក-ធម្មទេសនា.............................................................................................................................៤៣
ខ-សិល្បៈ......................................................................................................................................៤៤
គ-នវនាម.......................................................................................................................................៤៦
**សន្និដ្ឋាន**
**គន្ថនិទ្ទេស**

# តួនាទីអក្សរសិល្ប៍ពុទ្ធសាសនានៅសម័យក្រោយអង្គរ

## *សេចក្តីផ្តើម*

សម័យអង្គរជាពេលវេលាមួយនៃការរីកចម្រើនខ្លាំងស្ទើរគ្រប់វិស័យរហូតក្លាយជាចក្រភពអង្គរទៀតផង។ ព្រះរាជាគ្រប់ព្រះអង្គបានខិតខំកសាងប្រាង្គប្រាសាទធំស្កឹមស្កៃសម្រាប់ឧទ្ទិសថ្វាយអាទិទេពក្នុងរាជរបស់ទ្រង់។ ឥទ្ធិពលរបស់អាណាចក្រអង្គរក៏មិនអាចឈរជើងបិតបេរ រហូតឈានដល់ទីបញ្ចប់នៃសម័យដ៏រុងរឿងនេះផងដែរ។ ក្រោយការបែកបាក់នេះ កម្ពុជាបានឈានជើងចូលក្នុងភ្នក់ភ្លើងសង្គ្រាម ចម្បាំងរាំងជល់ វិបត្តិផ្ទៃក្នុងរហូតស្ទើរផុតដង្ហើមពីផែនទីពិភពលោកនេះ។ សម័យក្រោយអង្គរឬសម័យកណ្តាល ដែលគេផ្តោតសំខាន់ទៅលើសម័យកាលពីរសំខាន់គឺលង្វែក និងឧដុង្គ (១៤៣១-១៨៦០)។

ជាមួយគ្នាអក្សរសិល្ប៍ខ្មែរត្រូវបានវិវត្តទៅតាមដំណាក់កាលនីមួយៗនៃប្រវត្តិសាស្ត្រ។ កំឡុងសម័យអង្គរ យើងរកឃើញត្រឹមតែអត្ថបទជាសិលាចារឹកតែប៉ុណ្ណោះ។ ក្រោយសម័យដ៏រុងរឿងនេះ ត្បិតសង្គមខ្មែរធ្លាក់ក្នុងកលិយុគយ៉ាងណាក្តី ក៏យើងអាចឃើញអត្ថបទអក្សរសិល្ប៍ហាក់មានសន្ទុះឡើងវិញ រហូតអ្នកប្រាជ្ញអក្សរសាស្ត្រលោកចាត់ទុកថា «យុគមាសនៃអក្សរសិល្ប៍»ទៀតផង។ សម័យក្រោយអង្គរ ប្រជារាស្ត្រខ្មែរបានធ្លាក់ក្នុងវិបត្តិផ្លូវចិត្ត ភ័យខ្លាច តក់ស្លុត ព្រាត់ប្រាស់គ្រួសារ ទុក្ខសោកញាំញីជារឿយៗ។ ត្រង់នេះជាឱកាសមួយដ៏ល្អនៃលទ្ធិពុទ្ធសាសនាបានពង្រីកខ្លួនឱ្យកាន់តែខ្លាំងក្នុងសង្គមខ្មែរ។ ពុទ្ធសាសនាបានឈានជើងចូលក្នុងសង្គមខ្មែរតាំងពីសម័យមុនអង្គរម្ល៉េះ ក្រោមទម្រង់ជាមហានិកាយ។ ប៉ុន្តែក្រោយការដួលរលំនៃអាណាចក្រអង្គរ សាសនាព្រាហ្មណ៍ដែលគោលសាសនាមួយដែលទ្រសម័យអង្គរឱ្យរឹងមាំនោះក៏បានសាបរលាបផងដែរ។ ស្ថិតក្នុងរង្វង់នៃឥទ្ធិពលពុទ្ធសាសនានេះ អក្សរសិល្ប៍សម័យក្រោយអង្គរឬសម័យកណ្តាល ចង់ឬមិនចង់ក៏គង់តែទទួលឥទ្ធិពលនេះដោយខានពុំបាន។ លក្ខណៈពិសេសមួយរបស់អក្សរសិល្ប៍ពុទ្ធសាសនានោះគឺ ការលួងលោមនិងផ្តែកផ្តួលឱ្យជឿលើបុណ្យបាប កម្មផលពីអតីតជាតិ ប្រការនេះវាបានចូលរួមចំណែកបន្ធូរបន្ថយភាពតានតឹងអារម្មណ៍ប្រជាជនខ្មែរឱ្យរសាយផុតពីទុក្ខកង្វល់ ភាពរញ៉េរញ៉ៃ ញាំញីនៃវិបត្តិសង្គមជាតិ។ តែនេះមិនមែនជាមុខងារតែមួយគត់របស់អក្សរសិល្ប៍ពុទ្ធនិយមនោះទេ បើយើងស្រាយរាំងនននៃទ្រឹស្តីពុទ្ធសាសនា យើងនឹងឃើញលំហនៃទស្សនវិជ្ជាខ្មែរ ក្នុងការអប់រំនិងទិដ្ឋភាពនៃសង្គមមនុស្សនាសម័យនោះតាមរយៈផ្ទៃរឿង។

ជាការពិតណាស់ជុំវិញទស្សនាទាននៃអក្សរសិល្ប៍ពុទ្ធនិយមនេះ បានបណ្តុះមនុស្សឱ្យក្លាយជាពលរដ្ឋល្អប្រកបដោយសីលធម៌ គុណធម៌ក្នុងសង្គមខ្មែរពីបុរាណកាលមកម្ល៉េះ។ តម្លៃទាំងនេះដែលធ្វើឱ្យអក្សរសិល្ប៍ពុទ្ធនិយមមិនអាចសាបសូន្យពីសង្គមខ្មែរ នៅតែបន្តអត្ថិភាពមកដល់បច្ចុប្បន្ន។ ក្នុងការសិក្សាទៅលើតួនាទីអក្សរសិល្ប៍ពុទ្ធសាសនាក្រោយសម័យអង្គរ យើងសូមលើកយកនូវរឿងចំនួន៦មកឆ្លុះបញ្ចាំងជាតួយ៉ាងនៃអក្សរសិល្ប៍ពុទ្ធនិយមដោយអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ យើងលើកយករឿងពីទសជាតក សុវណ្ណសាមជាតក និងវេស្សន្តរជាតក ដោយហេតុរឿងទាំងពីរនេះពេញនិយម គួរនៅលើវត្តអារាមនាសម័យកណ្តាល។ រីឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយ យើងសូមលើក

យករឿងក្រុងសុភមិត្រ និងរឿងទេវន្ទមកផ្ទុះបញ្ចាំង។ ចំណែកឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ(ផ្លូម) យើងសូមលើកយករឿងភោគកុលកុមារ មរណមាតា មកផ្ទុះបញ្ចាំងតែប៉ុណ្ណោះ។

## ១-ការវិវត្តនៃអក្សរសិល្ប៍សម័យក្រោយអង្គរ

ដូចដែលយើងបានដឹងហើយថា ការលេចឡើងនូវនិន្នាការពីរ ក្នុងការបែងចែកអក្សរសិល្ប៍ខ្មែរគឺតាម ប្រវត្តិវិទ្យា និងភាសាវិទ្យា[1]។

ប្រវត្តិវិទូបានចែកតាមលំដាប់សម័យ គឺ

- សម័យមុនអង្គរ ពីសតវត្សទី១ ដល់ ស.វ.ទី៨
- សម័យអង្គរ ពីស.វ.ទី៩ ដល់ទី១៤
- សម័យក្រោយអង្គរ ពីស.វ.ទី១៥ ដល់ ១៨
- សម័យអាណានិគមបារាំង ពីគ.ស. ទី១៨៦៣ដល់ គ.ស. ១៩៥៣
- សម័យបច្ចុប្បន្នពីគ.ស. ១៩៥៣ រហូតដល់សព្វថ្ងៃ

ជួនកាលគេចែកលម្អិតតទៅទៀតក្នុងសម័យនីមួយៗ។ ចំណែកឯភាសាវិទូ បានចែកចង្កោមអក្សរសិល្ប៍ខ្មែរតាមការវិវត្តនៃភាសា និងនិរុត្តិសាស្ត្រគឺ

- សម័យបុរាណ ដែលហៅថា ខ្មែរបុរាណ ឬខ្មែរចាស់ គឺជាភាសាខ្មែរដែលបុព្វបុរសយើងបានធ្វើចំណារលើ ផ្ទាំងថ្មដាពាសពេញលើអាណាចក្រយើង ប្រសិទ្ធនាមហៅថា “សិលាចារឹក”។ “ភាសាខ្មែរបុរាណ” គឺរាប់ចាប់ពីស.វ. ទី៧ ដល់ស.វ.ទី១៤។
- សម័យកណ្តាល ឬសម័យ “ភាសាខ្មែរកណ្តាល” គឺជាភាសាខ្មែរដែលយើងឃើញលើសិលាចារឹកខ្លះៗ នៅលើសាស្ត្រាស្លឹករឹត ក្រាំង គម្ពីរ ក្បួនច្បាប់ផ្សេងៗក្នុងកំឡុងស.វ.ទី ១៩។
- សម័យបច្ចុប្បន្នកាល គឺជាសម័យនៃភាសាខ្មែរទំនើបឬខ្មែរថ្មី គឺជាភាសាដែលខ្មែរយើងនិយាយសរសេរ ប្រើការរហូតដល់សព្វថ្ងៃនេះឯងគឺតាំងពីកណ្តាលស.វ.វទី១៩ ដល់ទី២០នេះ។[2]

ជារួមយើងឃើញថា តាមរយៈបញ្ចេកសម័យកាលអក្សរសិល្ប៍ខ្មែរខាងលើ អាចឱ្យយើងដឹងខ្លះៗពីទំនាក់ទំនងនៃការវិវត្តសាស្ត្រាល្បែងក្នុងប្រវត្តិអក្សរសាស្ត្រខ្មែរសម័យកណ្តាល។ ជារួមអក្សរសាស្ត្រសម័យកណ្តាល គេតែងគិតទៅលើអក្សរសាស្ត្រក្នុងសម័យកាលធំៗពីរគឺ សម័យលង្វែកនិងឧដុង្គ។

យោងតាមលោកបណ្ឌិត ឃីង ហុកឌី បានលើកឡើងថា អក្សរសាស្ត្រសម័យកណ្តាល គឺសំដៅចំពោះ សំណុំចង្កោម អត្ថបទទាំងឡាយដែលនិពន្ធរចនាឡើងនៅក្នុងភាសា “ខ្មែរកណ្តាល” គឺគិតតាំងពីស.វ.ទី១៥ ដល់ដើមសតវត្សទី១៩[3] ។

---

[1] ឃីង ហុកឌី, *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*, បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៣, ទំ. ៤

[2] -ដ-ទំ. ៥

[3] -ដ-, ទំ. ២១

នៅក្នុងសម័យកណ្ដាលនេះផងដែរ គេឃើញលេចចេញទម្រង់អក្សរសិល្ប៍២ប្រភេទគឺ អក្សរសិល្ប៍លើសិលាចារឹក និងអក្សរសិល្ប៍លើក្រាំង និងសាស្ត្រា ។

**១.១-អក្សរសិល្ប៍លើសិលាចារឹក**

ផ្នែកសិលាចារឹកនេះ ឃើញមានតែសិលាចារឹកជ័យវរ្ម័នទី៧តែប៉ុណ្ណោះដែលមានលក្ខណៈអក្សរសិល្ប៍។ សិលាចារឹកជ័យវរ្ម័ន ត្រូវបាននិពន្ធឡើងដោយ បណ្ឌិតជ័យវរ្ម័ន បានបង្ហាញអំពីការប្រាថ្នា សុំសេចក្ដីសុខសប្បាយ ជួបជុំគ្រួសារ សោយសម្បត្តិទិព្វនាអនាគតជាតិរបស់បណ្ឌិតជ័យវរ្ម័ន តាមរយៈការបួស ក្រោមដំបូលព្រះពុទ្ធសាសនា ព្រមទាំងបញ្ជាក់អំពីការគោរពបូជាព្រះពុទ្ធសាសនា ការកសាងបដិមាព្រះពុទ្ធអំពីមាស ការធ្វើកុសលដោយដោះលែងទាសាទាសី ឱ្យមានសេរីភាព ការដាក់បណ្ដាសារដល់ជនណាដែលលួចសម្បត្តិព្រះ បង្ហាញពីជំនឿលើកម្មផល បុណ្យបាប នរកស្ថានសួគ៌ ថែមទៀត[4]។

អត្ថបទសិលាចារឹកដទៃនាសម័យកណ្ដាលមានដូចជា សិលាចារឹកគោកស្វាយចេក(K.754) សិលាចារឹកប្រាសាទខ្នារ (K.177) សិលាចារឹកប្រាសាទនគរបាជ័យ សិលាចារឹកតាព្រហ្មនៅវត្តបាទី(K.39) សិលាចារឹកភ្នំបាក់ខែង (K.285 K.465)…ជាដើម ។

អត្ថបទសិលាចារឹកមានទំហំខ្លី ព្រោះយើងដឹងហើយថាការចារចារឹកលើផ្ទាំងថ្ម ជាការលំបាកគឺត្រូវប្រើពេលយូរណាស់ ដើម្បីឆ្លាក់អត្ថបទនីមួយៗ ដូចនេះឃើញថាទាល់តែអត្ថបទនោះមានសារៈប្រយោជន៍ខ្ពង់ខ្ពស់ ជាទីសក្ការៈ ឬទាក់ទងនឹងសត្យាប្រណិធាន។ល។ ទើបអាចរចនាលើសិលាទាំងនេះបាន។[5]

**១.២- អក្សរសិល្ប៍លើសាស្ត្រា**

បើនិយាយអំពីប្រវត្តិនៃសាស្ត្រាស្លឹករឹត ពុំមែនទើបតែកកើតមាននៅសម័យកណ្ដាលនោះទេគឺបានកើតមានតាំងពីយូរលង់ណាស់មកហើយព្រោះថា បើគេសង្កេតទៅលើប្រវត្តិនៃការប្រើប្រាស់ឧបករណ៍សរសេររបស់ខ្មែរយើងមានអក្សរសម្រាប់សរសេរ តាំងពីរាប់រយឆ្នាំមុនគ.ស. មកម្ល៉េះ គ្រាន់តែការសេរនោះនៅមានលក្ខណៈ បុរាណប៉ុណ្ណោះ ដោយមានមតិខ្លះឱ្យដឹងថា "…ចំណែកការប្រើប្រាស់អក្សរខ្មែរចេះប្រើតាំងពីសតវត្សទី៦មុន គ្រឹស្តសករាជគឺខ្មែរចេះសរសេរឬចារច្រើនធ្វើនៅលើស្លឹក នៅលើស្បែកនៅលើក្រដាស ហើយចារនៅលើថ្ម… [6] ។ក្នុងចំណោមនោះមានតែសិលាចារឹកទេដែលសេសសល់មកដល់បច្ចុប្បន្ន ឯស្បែកសត្វនិងស្លឹកត្រូវបានខូចអស់ហើយ ពុំអាចធន់ទ្រាំដល់បច្ចុប្បន្នឡើយ។ តែទោះបីជាយ៉ាងណា យើងក៏នៅតែអាចដឹងបានថា វត្ថុទាំងនោះត្រូវបានគេយកមកប្រើប្រាស់សម្រាប់សរសេរ ដោយសម្អាងទៅលើឯកសារកំណត់ហេតុ ជីវតាក្វាន់ ដែលជាអ្នកស្រាវជ្រាវចិនបានមកដល់ស្រុកខ្មែរនាសម័យអង្គរបានឱ្យដឹងថា "លិខិតជម្មតាឬអត្ថបទទាំងអស់ ដូចជាឯកសារផ្លូវការជាដើមសុទ្ធតែសរសេរលើស្បែកសត្វ ប្រើស រមាំង ឬស្បែកសត្វដទៃទៀតដែរគេយកមក ហាលឱ្យស្ងួតលាបពណ៌ខ្មៅ។ គេកាត់ស្បែកនោះឱ្យមានទំហំ

[4] លាង ហាប់អាន, *ប្រវត្តិអក្សរសាស្ត្រខ្មែរ*, បណ្ណាគារ គិម អេងលេខ, ភ្នំពេញ, ១៩៦៧, ទំ. ២១១

[5] ឃីង ហុកឌី, *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*, ដ.ឯ.ម, ទំ. ២១

[6] លឹម ហាក់, *សិក្សាអំពីប្រវត្តិ និងបច្ចេកទេសគម្ពីរខ្មែរ*,សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា,១៩៩៥,ទំ. ២

ធំឬតូចទៅតាមសេចក្តី ត្រូវការនិងយកកម្សៀ ម្យ៉ាងមកប្រើមានសណ្ឋានដូចដីស នៅស្រុកចិនដែលគេលុញឱ្យវែង ចិតចុងស្រួចគេហៅថា សោ ហើយគេសរសេរដោយដៃបានជាប់ជឹតល្អណាស់មិនងាយនឹងរលុបឡើយ[7] ។ម្យ៉ាងទៀតក្នុងកំណត់ហេតុនេះដដែល ក៏បានបញ្ជាក់ទៀតដែរថាការប្រែពីចិនមកគេពុំនិយាយឱ្យច្បាស់ថាស្លឹករឹតនៅឡើយទេ ប៉ុន្តែលោកគិតថា លោកជីវតា ក្វាន់ពុំដឹងពីរបៀបដែលគេសរសេរលើស្លឹកនោះទេ ឯលោកផ្ទាល់សន្និដ្ឋានថាគេចារដោយប្រើដែកចារ ហើយយកធ្យូងលាបប្រេងមកលុបទើបបានជាស្នាមខ្មៅនេះ ដូច្នេះមានន័យថា ពិតជាសរសេរស្លឹករឹត។ ម្យ៉ាងទៀត ប្រភពដដែលបានឱ្យដឹងទៀតថា ស្លឹកនេះកត់ត្រានូវធម៌សម្រាប់ព្រះសង្ឃ ខាងពុទ្ធសាសនាសម្រាប់ទេសន៍ ដូច្នេះគ្មានអ្វីក្រៅពីសាស្ត្រាស្លឹករឹតឡើយ។ ជាមួយគ្នានេះនៅក្នុងសិលាចារឹកខ្លះ ក៏បានឱ្យដឹងថា មានការធ្វើគម្ពីរ អំពីស្លឹក មាស ប្រាក់ ដែលគម្ពីរនោះហៅថា Rikta ។ ហើយគេសន្និដ្ឋានថា គម្ពីរ ឬ Rikta សន្លឹកនេះគឺប្រហែលជាសាស្ត្រាស្លឹករឹតបច្ចុប្បន្ន[8]។

សាស្ត្រាស្លឹករឹតត្រូវបានធ្វើពីស្លឹកទ្រាំង ឬចាស់បុរាណហៅថា “ស្លឹកសម្លាញ”ដែលប្រទះក្នុងសិលាចារឹកបុរាណផងដែរ[9] ហើយពេលខ្លះគេក៏ប្រើ ស្លឹកត្នោត ប៉ុន្តែពិបាកចារបន្តិច។ តាមវចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត ទ្រាំង គឺជាឈ្មោះ តចសារព្រឹក្សមួយប្រភេទ(សណ្ឋានជ្រៃ)មានធាងវែង “មានស្លឹកប្រើការបានច្រើនយ៉ាង គឺចារសាស្ត្រាហៅថាស្លឹករឹត... ដើមទ្រាំងនេះ ដុះពីគ្រាប់វាក្នុងព្រៃធំៗក្នុងប្រទេសកម្ពុជា មានខែត្រក្រចេះ និងខែត្រកំពង់ធំច្រើនជាងខែត្រឯទៀតជា តចសារព្រឹក្សមានប្រយោជន៍ច្រើន គេអាចដាំតាមព្រះវត្តអារាមក៏បានមិនសូវរើសដីប៉ុន្មានទេ រស់បានយូរឆ្នាំវែងជាងអាយុមនុស្ស អ្នកមានអាយុវែង ប៉ុន្តែលុះដល់កំណត់កាលក៏បញ្ចេញផ្កាត្រង់ចំកំពូលមានផ្លែ ជាផ្លាយដូចផ្លែផ្លាយផ្លែចាក លុះផ្លែទុំហើយ តចសារព្រឹក្ស នេះក៏ងាប់រាប់ថាជារុក្ខជាតិបញ្ចេញផ្កាផ្លែសម្លាប់ដើម... [10] ។ ដើមទ្រាំងនេះគេអាចយកទៅប្រើបានច្រើនយ៉ាងដោយធាងទ្រាំងគេយកទៅធ្វើជា រំពាត់ ដំបង ពន្ទមូល ដាម ...រីឯស្លឹកទ្រាំងគេយកទៅធ្វើជាសំពៀត ស្បោង កន្ទេល ស្លឹកក្ពល់ ស្លឹករឹត... [11]។

រីឯព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម ចុះផ្សាយក្នុងទស្សនាវដ្តី កម្ពុជសុរិយាបានហៅទ្រាំងថាជាស្លឹករឹតនិងឱ្យដឹងថា “ស្លឹករិតជារុក្ខជាតិ ដុះនៅលាយឡំជាមួយនឹងរុក្ខជាតិផ្សេងៗជារុក្ខជាតិមានតែដើម ធាង ស្លឹក ដុះចេញមកជាកំពូលប៉ុណ្ណោះ គ្មានមែកទេ(សម្បូរជាងគេនៅខេត្តក្រចេះ) [12]។

សាស្ត្រាត្រូវបានគេបែកចែកជាបីគឺ សាស្ត្រាទេសន៍ សាស្ត្រាក្បួន និងសាស្ត្រាល្បែង។

ចំពោះសាស្ត្រាល្បែង គេយល់ថា ពាក្យល្បែង មានក្នុងភាសាខ្មែរជាយូរមកហើយ យើងឃើញមានដំបូងនៅក្នុងសិលាចារឹក K.254 នៅសតវត្សទី១២បន្ទាត់ ១៩ មានពាក្យ “គរុលំបែង” គឺ”គ្រូល្បែង” នេះឯង។ លោក សឺដេស យល់ថាជា “គរុ ដែលធ្វើពិធីផ្សេងៗទេ គឺមិនយកទ្រនឹប” ។ ពាក្យ ល្បែង នេះទៀតសោតយើងឃើញមាននៅពាសពេញ

---

[7]ជីវតាក្វាន់, ***ទឹកដីនិងប្រពៃណីអ្នកស្រុកចេនឡា***, រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០១៣ ទំ.៣៨

[8] -ដ-,ទំ. ៣២

[9] អាំងជូលាន,ព្រាប ចាន់ម៉ារ៉ា, ស៊ីយ៉ុន សុភារិទ្ធ,គង់ វីរៈ, ***កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ***,លេខ២ ធ្នូ ២០០៦ ធ្នូ២០០៧ , ចំណុច ៥.៦

[10] ជួន ណាត,***វចនានុក្រមខ្មែរភាគ***១ ២, ដ.ឯ.ម, ទំ. ៤៦៩ -៤៧០

[11] លី ស៊ីវ, ***អរិយធម៌ខ្មែរទាក់ទងនឹងអក្សរសិល្ប៍បែប ពុទ្ធនិយម បែបព្រហ្មនិយម បែបខ្មែរនិយម***, ភ្នំពេញ, បោះពុម្ពលើកទី២, ២០០២, ទំ. ១៦២-១៦៣

[12]អ៊ុម ស៊ុម, ***គម្ពីរស្លឹករិត***, ចុះផ្សាយក្នុងទស្សនាវដ្តី កម្ពុជសុរិយា លេខ ៤៨, ១៩៩៤, ទំ. ៩៤

អត្ថបទអក្សរសាស្ត្រសម័យកណ្ដាល[13]។ ជាក់ស្ដែងនៅក្នុងច្បាប់ត្រីនេតិ ក្នុងច្បាប់ផ្សេងៗ ទំព័រ ៩១ ដល់៩៤៖ វគ្គ៧៤ "កុំលេងជាល្បែង រំពឹងយល់ឈ្នេង ពាក្យពុំពីរោះ ស្រដីឱ្យដាច់ ឱ្យស្រេចឱ្យស្មោះ កុំធ្វើឡេះឡោះ សសោះអន្ទង។" ។ រីឯច្បាប់ប្រុស ក្នុងច្បាប់ផ្សេង ទំព័រ ១ ដល់១០៖ វគ្គ ៥២ " លោកថាហៅឆ្គួតបី មួយឆ្គួតស្រីមួយឆ្គួតស្រា មួយឆ្គួតល្បែង ពាលា លេងបៀប៉ាធូកំតាត់" ។

យ៉ាងណាមិញលោក អូ ឈៀង ក៏បានឱ្យនិយមន័យថា ល្បែង មកពីពាក្យ "លេង" ដូច្នេះ ល្បែងមានន័យថា អ្វីដែលជាទីកម្សាន្តសើចបំពេញអារម្មណ៍។ល។[14]

ជារួម សាស្ត្រាល្បែង ត្រូវបានលោកអ្នកអក្សរសាស្ត្របានឱ្យនិយមន័យខុសៗគ្នាដូចជា៖

យោងតាមវចនានុក្រមខ្មែរ សម្ដេចព្រះសង្ឃរាជ ជួន ណាត បានលើកឡើងថា សាស្ត្រាល្បែង គឺជាប្រលោមលោកសម័យកណ្ដាល។ លោកបញ្ជាក់ទៀតថា ប្រលោមលោកនេះនៅក្នុងសម័យដើម សាស្ត្រាល្បែងឬរឿងល្បែងខាងសម្រាយ ច្រើនតែងជាពាក្យកាព្យ... ខាងបាលីច្រើនតែងជា បកិណ្ណកៈឬវេយ្យាករណ៍បាប គឺជាពាក្យបាលីរាយៗ ជួនមានគាថាបាលីបញ្ចូលមកខ្លះដោយអន្លើៗ ដូចជាបញ្ញាសជាតកជាដើម រឿងសាស្ត្រាទាំងនោះជាពាក្យកាព្យសម្រាយក្ដី ជាបាលីក្ដីហៅថា  "សាស្ត្រាល្បែង ឬរឿងល្បែង" ដូចគ្នា ត្រូវគ្នានឹងរឿងសាស្ត្រាសៀវភៅប្រលោមលោកសម័យបច្ចុប្បន្ននេះ[15]។

តាមទស្សនៈបណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន លើកឡើងថាក្នុងកំឡុងស.វ.ទី ១៨-១៩ អ្នកនិពន្ធខ្មែរខ្លះបានដកស្រង់យករឿងក្នុងជាតកមួយចំនួន មកប្រែសម្រួលជាភាសាខ្មែរ ដោយទុកគាថាភាសាបាលីខ្លះៗ ហើយអ្នកនិពន្ធខ្លះទៀតបានដកស្រង់ដំណើររឿងក្នុងជាតកមកតាក់តែងទៅតាមគំនិតរបស់ខ្លួន។ ស្នាដៃទាំងនោះត្រូវបានចារលើសាស្ត្រាស្លឹករឹតហៅថា សាស្ត្រាល្បែង[16]។

ស្រដៀងគ្នានេះ បណ្ឌិតសភាចារ្យ សោម សុមុនី យល់ឃើញថា សាស្ត្រាល្បែងជាប្រលោមលោកពាក្យកាព្យដែលទទួលឥទ្ធិពលពីពុទ្ធសាសនា ហើយមានលក្ខណៈឯកភាពបីគឺ ទី១ មធ្យោបាយគឺចារលើស្លឹក ឬក្រាំង ពោលគឺពុំមែនឆ្លាក់លើថ្មដូចសម័យមុនទៀតឡើយ។ ទី២ ការសរសេរជាពាក្យកាព្យ លើសាស្ត្រា ហើយអ្នកនិពន្ធមាននិន្នាការពុទ្ធនិយម។ ចំណុចចុងក្រោយគឺសម័យកាល គឺត្រូវនឹងចន្លោះសតវត្សទី១៧-១៨-១៩[17]។

រីឯបណ្ឌិត ធ សោ លោកយល់ថា អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ បានដល់ស្នាដៃ ដែលជាសាស្ត្រាល្បែងកើតនៅសតវត្សទី១៧-១៨-១៩[18]។

អ្នកស្រាវជ្រាវខ្មែរដ៏ឆ្នើមម្នាក់នៅប្រទេសបារាំង បណ្ឌិតសភាចារ្យ ឃីង ហុកឌី បានឱ្យជាគំនិតថា រឿងល្បែង ជាស្នាដៃអក្សរសាស្ត្រមួយដែលច្នៃប្រឌិតសម្រាប់ប្រលោមលោកលួងលោម  អារម្មណ៍អ្នកអានក្នុងកម្រងភាសាកំណាព្យដ៏

---

[13] ឃីង ហុកឌី, *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*, ដ.ឯ.ម, ទំ. ២៧

[14] -ដ- ទំ. ២៥

[15] ជួន ណាត, *វចនានុក្រមខ្មែរ* ភាគ១ភាគ២, ដ.ឯ.ម, ទំ. ៦៦៥

[16] ស៊ុំ ឈុំប៊ុន, *ឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ឯកទេសអក្សរសិល្ប៍*, ២០០៣

[17] សោម សុមុនី, *ឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ឯកទេសអក្សរសិល្ប៍*, ២០០៣

[18] ធ សោ, *សិក្សារឿងព្រះវេស្សន្តរជាតក*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ១៩៩៤, ទំ. ៣១

ប្រណីត ពោលគឺជាកំរងអត្ថបទរឿងរ៉ាវប្រពៃណី ដែលតាក់តែងជាកំណាព្យឃ្លោងឡើងនៅរវាងស.វ.១៨-១៩។ នេះជាផលិតកម្មអក្សរសាស្ត្រមានទំហំវែងអន្លាយ ចំនួនជាមធ្យមនៃរឿងល្បែងនីមួយៗ មានប្រហែល៨០០០ឃ្លា[19]។

រឿងល្បែង គឺជាស្នាដៃអក្សរសាស្ត្រដែលច្នៃប្រឌិតសម្រាប់ប្រលោមលួងលោមអារម្មណ៍អ្នកអានក្នុងកម្រងកំណាព្យ ដ៏ប្រណីតពោលគឺកម្រងអត្ថបទរឿងរ៉ាវបែបប្រពៃណីដែលតាក់តែងជាកំណាព្យឃ្លោងឡើងនៅសតវត្សទី១៨-១៩[20]។ រឿងល្បែងតំណាងលក្ខណៈពិសេសនៃអក្សរសាស្ត្រសម័យកណ្ដាលដែលជាអត្ថបទធំជាងគេក្នុងសម័យនោះ ដោយយោងទៅលើទំហំប្រវែងនៃអត្ថបទនីមួយៗ[21]។

ឆ្លងតាមរយៈការលើកយកលោកទស្សនៈនៃអ្នកអក្សរសាស្ត្រយើងរួចមកយើងអាចសំយោគបានថា សាស្ត្រាល្បែង គឺជាប្រលោមលោកសម័យកណ្ដាល ដែលតាក់តែងជាពាក្យកាព្យបុរាណ អាចឆាបឆក់ព្រលឹង អ្នកអានឱ្យរន្ធត់ញាប់ញ័រទៅតាមសាច់រឿង ខ្លឹមសារច្រើនទាក់ទងនឹងចលនាពុទ្ធនិយម ហើយចារនៅលើស្លឹករឹត កើតមាននៅក្នុងចន្លោះសតវត្ស១៧ ដល់១៩។ ប្រភេទសាស្ត្រាល្បែងនេះបានគាំទ្រទៅលើស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមក្លាយនិងក្លាយហួសហេតុយ៉ាងសំខាន់។ ត្បិតនាសម័យក្រោយអង្គរឬសម័យកណ្ដាល សាស្ត្រាល្បែងបានដើរតួនាទីក្នុងការផ្សព្វផ្សាយយ៉ាងសកម្មនូវទស្សនៈ គោលគំនិតនៃពុទ្ធសាសនា។

## ១.៣- អក្សរសិល្ប៍លើក្រាំង

ចំណែកឯក្រាំងវិញ ក៏ប្រហែលមកពីពាក្យថា រាំង។ ដូច្នេះក្រាំងគឺជាគម្ពីរដែលគេយកក្រដាសស្នាយរឹង មកបិទភ្ជាប់គ្នាខ្ទប់ឬខ្ទប់ ឱ្យវានៅក្នុងពុម្ពតែមួយ ឬជាសៀវភៅតែមួយក្បាល មានសណ្ឋានជាផ្នត់ៗអង្កាញ់ៗជាមួយគ្នា ដែលជាធម្មតាមាន៣៨ផ្នត់[22]។

ជាមួយគ្នានេះដែរ តាមវចនានុក្រមខ្មែរ សម្ដេចសង្ឃ ជួន ណាត បានលើកថា ក្រាំងគឺជាសៀវភៅធ្វើដោយក្រដាសស្នាយ ឬក្រដាសមនជាដើម បត់ជាជាន់ៗជារបៀបត្រឹមស្មើ ប្រើបានសម្រាប់ សរសេរកត់ត្រាអ្វីទាំងពួង[23]។

ជារួមយើងឃើញថា ការចារទៅលើសិលាចារឹកមានភាពលំបាកច្រើនទាំងទំហំអត្ថបទក្នុងការចារមានលក្ខណៈខ្លី ហើយអត្ថន័យនោះទៀតសោតច្រើននិយាយអំពីព្រះមហាក្សត្រ ការធ្វើអំណោយទាន ដល់ប្រាសាទ ពាក្យសច្ចាប្រណិតធានជាដើម។ ដែលនេះជាហេតុធ្វើឱ្យទម្រង់អក្សរសិល្ប៍មានលក្ខណៈចង្អៀត។ របត់ថ្មីមួយបានប្រែប្រួលបែបបទក្នុងការចារឱ្យមានលក្ខណៈងាយស្រួលជាងសរសេរលើថ្ម ហើយអាចចារបានទំហំអត្ថបទវែងនោះ ដូនតាខ្មែរបានងាកមកប្រើការចារលើសាស្ត្រាស្លឹករឹតឬក្រាំងវិញម្ដង។ អត្ថបទទាំងនេះត្រូវបានចារចម្លងតៗគ្នា នៅតាមវត្តអារាមនីមួយៗទុកសម្រាប់សិក្សា សូត្រស្វាធ្យាយជាដើម។

---

[19] ឃីង ហុកឌី, ***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម, ទំ. ៨៣

[20] កេង វ៉ាន់សាក់, ***ទិដ្ឋភាពខ្លះៗនៃអក្សរសិល្ប៍ខ្មែរ***, ប្រែសម្រួលដោយ សេន សេង, បោះពុម្ពលើកទី១, ភ្នំពេញ, ២០១៦, ទំ. ៣១

[21] ឃីង ហុកឌី, ***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ***, ដ.ឯ.ម, ទំ. ៨៤

[22] លឹម ហាក់, ***សិក្សាអំពីប្រវត្តិនិងបច្ចេកទេសគម្ពីរខ្មែរ***, ដ.ឯ.ម, ទំ. ៤

[23] ជួន ណាត,***វចនានុក្រមខ្មែរភាគ***១ ២, ដ.ឯ.ម, ទំ. ៨៩

## ២- ឥទ្ធិពលពុទ្ធសាសនាក្រោយសម័យអង្គរ

### ២.១- ពុទ្ធសាសនាក្នុងសង្គមខ្មែរ

ព្រះពុទ្ធសាសនាត្រូវបានចូលមកផ្សព្វផ្សាយនៅលើដែនដីសុវណ្ណភូមិក្នុងសតវត្សទី៣មុនគ.ស. ក្នុងរជ្ជកាលព្រះបាទអសោកមហារាជ ២១៨មុនគ.ស.[24]។រីឯបើតាមគម្ពីរមហាវង្ស ពង្សាវតារលង្កាទ្វីប ក្នុងសៀវភៅពុទ្ធសាសនាសង្ខេប បានសរសេរថា កាលដែលព្រះសោណត្ថេរនិងឧត្តរត្ថេរនិមន្តទៅដែនដីសុវណ្ណភូមិនោះ ព្រះអង្គនិមន្តទៅកោះមួយហៅថា សុវណ្ណទ្វីប មានន័យថាកោះមាស។ តាមសេចក្តីខាងលើយើងអាចដឹងពីស្លាកស្នាមនៃពុទ្ធសាសនាបានហូរចូលមកសង្គមខ្មែរតាំងពីមុនគ.ស.មកម្ល៉េះ ប៉ុន្តែឥទ្ធិពលនៃពុទ្ធសាសនាពុំទាន់ជ្រួតជ្រាបដល់ស្រទាប់នៃប្រជានុរាស្ត្រនៅឡើយ។ នៅសម័យនគរភ្នំ ត្រូវបានគេយល់ថា គេគោរពព្រះពុទ្ធសាសនាហីនយានផង និងមហាយានផង ជាក់ស្តែងគេបានឃើញព្រះពុទ្ធរូប៤០អង្គ នៅតំបន់ភាគខាងក្រោមនៃទន្លេមេគង្គ នឹងមាននៅតំបន់ជាច្រើនទៀតនៅប្រទេសថៃដែលធ្លាប់មានទំនាក់ទំនងជាមួយអាណាចក្រភ្នំ[25]។បន្តមកដល់សម័យចេនឡា ព្រះពុទ្ធសាសនាធ្លាប់តែមានការរីកចម្រើននាសម័យនគរភ្នំនោះ ត្រូវបានចុះអានុភាពខ្លួនបន្តិចម្តងៗតែពុំសាបសូន្យភ្លាមទេ ដោយគេបានរកឃើញ ព្រះពុទ្ធរូបនៅស្រុកព្រៃកប្បាសខេត្តតាកែវដែលបានកសាងឡើងនៅស.វ.ទី៧។ ដោយឡែកសិលាចារិកនៅវត្តព្រៃវៀរស្រុកកំពង់ត្របែក ខេត្តព្រៃវែងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១បានសរសេរថា«មានភិក្ខុពីរអង្គជាបងប្អូនបង្កើតជាក្សត្រ បានចេញទៅសាងព្រះផ្នួសហើយគង់នៅវត្តព្រៃវៀងនោះមានព្រះនាមថា ភិក្ខុរតនភាណុនិងភិក្ខុរតនសិង្ហ»[26]។ ក្នុងសម័យអង្គរ ដំណាក់កាលដំបូង ព្រះពុទ្ធសាសនាហីនយាននៅតែបន្តចុះអានុភាពនៅឡើយនោះព្រះពុទ្ធសាសនាមហាយាន(អាចរិយវាទ)មានការរីកចម្រើនរុងរឿង ចាប់តាំងពីសម័យកាលព្រះបាទរាជេន្ទ្រវរ្ម័នទី១ ព្រះអង្គបានប្រោសសណ្តោសដល់ ព្រះពុទ្ធសាសនា ទោះជាព្រះអង្គគោរពព្រហ្មញ្ញសាសនាក៏ដោយ[27]។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ត្រង់ជាសាសនិកដ៏ធ្ងើមប្រតិបត្តិព្រះពុទ្ធសាសនាមហាយានគោពព្រះពោធិសត្វអវលោកិស្វរៈ និងព្រះប្រាជ្ញាបារមិតា[28]។ក្រោយសម័យអង្គរ ព្រះពុទ្ធសាសនាថេរវាទបានមកជំនួស ព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាមហាយាន។ តួយ៉ាងព្រះបាទពញាយ៉ាតមានជំនឿលើពុទ្ធសាសនាថេរវាទ ព្រះអង្គបានចាត់ឱ្យកសាងវត្តជាច្រើនកន្លែងនៅរាជធានីចតុមុខដូចជាវត្តលង្កា វត្តកោះ វត្តព្រះពុទ្ធឃោសារាម(វត្តចិនដំដែក) វត្តឧណ្ណាលោម វត្តខ្ពបតាយ៉ង់(វត្តបទុមវតី)និងវត្តភ្នំដូនពេញ។ចូលដល់រជ្ជកាលព្រះអង្គឌួង ព្រះអង្គបានជួសជុលនឹងកែលម្អវត្តអារាមដែលនៅជុំវិញក្រុងឧដុង្គឡើងវិញ ព្រមទាំងរៀបចំជារចនាសម្ពន្ធព្រះសង្ឃតាមឋានានុក្រម ដោយមានសម្តេចព្រះសង្ឃរាជទាំងពីរគណៈគឺ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយចាប់ពីឆ្នាំ១៩៤៧មក[29]។

---

[24] ហួត តាត, *ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប*, ពុទ្ធសាសនបណ្ឌិត្យ, ២៩៧០, ទំ. ៤

[25] អៀន ហៃវីស, *ប្រវត្តិនិងការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជាភាគ១*, នគរវត្ត, ២០១០, ទំ. ១៩

[26] ហ៊ុន ជារិទ្ធ, *អរិយមគ្គនៃអង្គ៨តាមរយៈប្រជុំរឿងព្រេងខ្មែរ, និក្ខេបបទ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ*,២០១៨, ទំ.៣០

[27] -ដ-, ទំ.៣១

[28] អៀន ហៃវីស, *ប្រវត្តិនិងការប្រតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជាភាគ១*, នគរវត្ត, ២០១០, ទំ. ៤៦-៤៧

[29] ហ៊ុន ជារិទ្ធ, *អរិយមគ្គនៃអង្គ៨តាមរយៈប្រជុំរឿងព្រេងខ្មែរ*, -ដ-ឯ-ម-, ទំ.៣២

## ២.២- ឥទ្ធិពលពុទ្ធសាសនាមកលើអក្សរសិល្ប៍ខ្មែរ

ព្រះពុទ្ធសាសនាថេរវាទទៅសម័យកណ្ដាល បានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរជំនួសឱ្យពួកព្រាហ្មណ៍ដ៏ល្បីល្បាញនៅសម័យអង្គរ ដែលបានផុតទៅនៅកំឡុងសតវត្សរ៍ទី១៤។ នៅក្នុងឯកសារពង្សាវតារទាំងអស់ បង្ហាញឱ្យឃើញថាពុទ្ធសាសនាថេរវាទជាសាសនារដ្ឋ និងជាសាសនាផ្លូវការមួយដែលមានលក្ខណៈឯកភាពនៅទូទាំងប្រទេស តពីនោះរហូតមកដល់សព្វថ្ងៃ។ រាល់សង្គ្រាមទាំងអស់ ទាំងសង្គ្រាមជាមួយបរទេស ជាពិសេសប្រទេសសៀមនិងទាំងសង្គ្រាមក្នុងស្រុក ការកាប់ចាក់គ្នារវាងសមាជិករាជវង្សានុវង្ស ដែលអាងថាខ្លួនមានសិទ្ធិឡើងសោយរាជ្យដូចគ្នា គេតែងយកលេសមួយយកមកនិយាយគឺ "ដើម្បីសេចក្ដីសុខនៃសមណជីព្រាហ្មណ៍ និងប្រជានុរាស្ត្រផងដែលជាអ្នកកាន់ព្រះពុទ្ធសាសនា"។ បន្ទាប់មកគេនឹងចាប់ផ្ដើមធ្វើសង្គ្រាម ឬបញ្ឈប់សង្គ្រាម ដោយមានការចរចាបង្កើតយុទ្ធសន្តិភាពដោយស្ម័គ្រចិត្តរៀងៗខ្លួន (Eng 1985) [30]។

ដូចដែលយើងបានដឹងហើយថា ព្រះពុទ្ធសាសនាថេរវាទបានចូលមកកម្ពុជាស្របពេលដែលកម្ពុជាកំពុងធ្លាក់ខ្លួនទៅក្នុងភ្នក់ភ្លើងនៃសង្គ្រាម កលិយុគ កាប់ចាក់ ហែកហួរគ្នា រវាងប្រទេសជិតខាង រវាងរាជវង្សគ្នាឯងជាដើម។ រីឯគម្ពីរក្បួនច្បាប់ផ្សេងៗត្រូវបានខ្ទេចខ្ទីទៅក្នុងភ្នក់ភ្លើងនៃសង្គ្រាមនោះផងដែរ។ ដែលនេះជាហេតុធ្វើឱ្យប្រជានុរាស្ត្របាត់បង់នូវទំនុកចិត្តលើការដឹកនាំ គ្មាននូវសេចក្ដីក្លាហាន ហើយផ្ដេកផ្ដួលទៅលើទស្សនៈរបស់ព្រះពុទ្ធសាសនា ដូចជាទស្សនៈកម្មផល ទស្សនបុណ្យបាប ឬទស្សនៈអរិយសច្ចៈជាដើម។ ក្នុងន័យនេះអាចធ្វើឱ្យពួកគាត់មានលំនឹងចិត្តឡើងវិញ។

ប្រភពអក្សរសិល្ប៍ខ្មែរក្រោយសម័យអង្គរ ឬសម័យកណ្ដាលដែលជារឿងល្បែងមួយចំនួនធំគឺ ទាញមកពីគម្ពីរជាតកនៃព្រះត្រៃបិដកព្រះពុទ្ធសាសនា គម្ពីរបញ្ញាសជាតក និងកម្រងសង្គមធម៌និងវប្បធម៌ខ្មែរយើង។ កវីនិពន្ធបានប្រើពាក្យឬបញ្ញត្តិជាច្រើនទាក់ទងនឹងពុទ្ធសាសនាដូចជាបញ្ហាកម្មផល អន្តរាគមន៍ ទេវៈ ការសជាតិ។ល។ ដែលជាលក្ខណៈពុទ្ធសាសនាដែរ។ ចំណែកទីវាល និងទីកាលទៀតសោតគឺវែងឆ្ងាយណាស់ឧទាហរណ៍ ទីកន្លែងមាននៅស្ថានសួគ៌ជាជាន់ថ្នាក់ ស្ថានកណ្ដាល ពារាណសី ព្រៃហេមពាន្ត ស្ថានបាតាល ស្ថាននរក ជាជាន់ជាថ្នាក់។ល។ ឯពេលវេលាគឺមានបច្ចុប្បន្នជាតិឬសព្វថ្ងៃ អតីតជាតិឬជាតិមុននិងអនាគតជាតិឬជាតិក្រោយៗ[31]។

ជាក់ស្ដែងនៅក្នុងរឿង ពុទ្ធិសែន ដែលជាស្នាដៃសាស្ត្រាល្បែងមួយដែលមានប្រជាប្រិយភាពក្នុងសង្គមខ្មែរ រហូតដល់ប្រសិទ្ធនាមភ្នំមួយឈ្មោះថា ភ្នំនាងកង្រី។ មិនត្រឹមតែប៉ុណ្ណោះ រឿងនេះបានយកលំនាំតាម រថសេនជាតក ដែលស្ថិតនៅក្នុងគម្ពីរបញ្ញាសជាតកទៀតផង។ រឿងនេះក៏បានបង្ហាញពីលក្ខណៈកម្មផល ដែលខ្លួនបានសាង។ ពោលគឺបុព្វហេតុដែលនាំឱ្យនាងទាំងដប់ពីរ បានខ្វះភ្នែកទាំងអស់នោះគឺបណ្ដាលមកនៅពេលដែលនាងទាំង១២បានវង្វេងផ្លូវហើយនាងទាំងអស់បានចូលទៅក្នុងស្ទឹងចុះទៅចាប់ត្រីជាអាហារ។ អ្នកទាំង១២បានចាប់បានត្រីចង្វារម្នាក់ៗ បាន

---

[30] វង់សុធារ៉ា ណុបសុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ២០១៣, ទំ.១៣៦

[31] ឃីង ហុកឌី, ***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ***, ផ.ឯ.ម., ទំ. ៨៤

ដោតភ្នែកទាំងសងខាងរបស់ត្រីដើម្បីយួរ។ ប្លែកតែនាងពៅមួយដោតតែម្ខាងប៉ុណ្ណោះ ដូចយ៉ាងលើកក្នុងកំណាព្យឡើងថា៖

បបួលគ្នាផ្លាស់ សំពត់បន្លាស់ ដាក់ឆ្នេរនទី
ស្បែគាតក្តាំងក្តាត់ ក្រវាត់ឥន្ទ្រិយ អស់រៀមប្អូនស្រី
ចរចុះគង្គា។
ខ្លះរាវខ្លះចាប់ ខ្លះបានសម្លាប់ សឹងត្រីចង្វា
ដោតភ្នែកទាំងសង ពុំពិចារណា នាងពៅពុំងា
ដោតភ្នែកតែមួយ។
ហេតុពៀរនោះហោង រត់ពុំរម្លង វេរាឯងឱ្យ
ងូតហើយឡើងគោក ត្រណោតសៀតក្រោយ ផ្លាស់សំពត់ដោយ
អង្គឯងទីទៃ។[32]

ទាំងនេះហើយដែលជាហេតុនាំឱ្យនាងទាំង១១ ត្រូវបានខ្វះនេត្រាទាំងសង ហើយនាងពៅខ្វះតែម្ខាង។ ក្នុងន័យនេះបើមើលទៅលើទ្រឹស្តីកម្មផល កម្មដែលសាងនៅក្នុងបច្ចុប្បន្នជាតិ ហើយផ្តល់ផលក្នុងបច្ចុប្បន្នជាតិគេហៅថាទិដ្ឋធម្មវេទនីយកម្ម។ នាងទាំង១២បានកសាងនូវកម្មដោយដោតភ្នែកត្រីនោះត្រូវបានផ្តន្ទាមកក្នុងបច្ចុប្បន្នជាតិដូច្នេះដែរ។

រីឯរឿងស្រទបចេកវិញនោះយើងឃើញថា កម្មផលដែលថៅស្រទបចេកបានសាងនៅអតីតជាតិបានទទួលផលនូវបច្ចុប្បន្នជាតិ។ កម្មដែលនាំឱ្យថៅស្រទបចេក បាត់បង់អស់គ្រួសារ ទ្រព្យសម្បត្តិ រហូតទៅគ្មានខោអាវស្លៀកពាក់ទៅយកស្រទបចេកមកបិទបាំងខ្លួននោះបណ្តាលមកពី កាលពីជាតិមុនស្រទបចេកបានទៅ វាយសម្រាតស្បង់ព្រះសង្ឃធ្វើឱ្យព្រះសង្ឃអាក្រាតរត់ខ្មាសគេ ហើយកម្មពៀរនេះបានផ្តល់ផលដូច្នេះឯង។

សាមណេរមួយណា ចរចេញយាត្រា ទៅតែឯកអង្គ
គាប់ជួនបុរស ដើរស្មោះទៅត្រង់ ជួបជុំលោកសង្ឃ
សាមណេរនោះណា។
បុរសនោះឯង ចាប់សម្រាតលេង តាមតែចិន្តា
សង្ឃនោះខ្មាសគេ ឥតឯងឧបមា បន្តិចបុរិសា
ប្រគេនស្បងវិញ។
ពៀរនោះឯងណា តាមទាន់កុមារា ឱ្យរងទុក្ខម្នេញ
ពៀរនោះបាំងបិទ ចិត្តសេដ្ឋីមិញ មិនឱ្យគិតកាញ

[32] ***ពុទ្ធិសែន***, ពុទ្ធសាសនបណ្ឌិត្យ., ទំ. ១៦

ក្រែងកូនក្រីក្រ។[33]

នេះសបញ្ជាក់ឱ្យឃើញថា កម្ម ទាំងឡាយដែលស្រទបចេកបានប្រព្រឹត្តកាលពីជាតិមុនត្រូវបានទទួលផលនៅបច្ចុប្បន្នជាតិនេះឯង កម្មទាំងនេះនៅក្នុងទ្រឹស្តីកម្មផលគេហៅថា ឧបបជ្ជនីយកម្ម។ យ៉ាងណាមិញ តាមរយៈរឿងនេះអ្នកនិពន្ធចង់បង្ហាញឱ្យមនុស្សទូទៅកុំទៅប្រឡែងលេងខុសទំនងជាមួយព្រះសង្ឃ រហូតមានឃ្លា "កុំក្តីក្តាំនឹងសង្ឃ" ទៀត។

ចំពោះរឿងសព្វសិទ្ធិ ដែលជាវណ្ណកម្មរបស់ហ៊ឹនកក្តីអក្សរ គន់ ក៏បានបង្ហាញនូវបញ្ហាកម្មផលនេះដែរ។ នៅត្រង់មូលហេតុដែលនាំឱ្យចាបចៀបកប្បាសទាំងពីសម្លាប់ទៅក្នុងភ្នក់ភ្លើងទាំងខ្លួននិងកូនទៀតនោះ ក៏ដោយសារកម្មពីជាតិមុន អ្នកទាំងពីរជាមនុស្សហើយដុតសត្វស្លាបឱ្យស្លាប់ ម្ល៉ោះហើយកម្មពៀរនោះបន្តរហូតដល់ទៅប្រាំរយជាតិ។

| | |
|---|---|
| ភ្លើងនោះក៏ឆេះជាផេះផង់ | ផាយផាត់បាត់អង្គជាធូលី |
| សត្វនោះនាំគ្នាស្លាប់ទាំងពីរ | ព្រោះមានវេរីទីវេរា។ |
| កាលភពមុនឡើយបក្សានោះ | បានលុះបុញ្ញភាពចាប់ជាតិជា |
| មនុស្សហើយដុតសត្វឱ្យមរណា | វេរានោះតាមតែរាល់ជាតិ។ |
| មោះមកផ្តន្ទានាលោកិយ | បក្សាបក្សីកើតវិវាទ |
| ដុតខ្លួនឯងវិញពុំឃ្លាឃ្លាត | គ្រប់ប្រាំរយជាតិទើបរដោះ។[34] |

នេះជាកម្មដែលអ្នកទាំងពីរបានសាងពីអតីតជាតិហើយបានហុចផលមកបច្ចុប្បន្នជាតិ។ ជាងនេះទៅទៀតកម្មដែលអ្នកទាំងពីរមិនទុកចិត្តគ្នា របស់សត្វចាបចៀបកប្បាសត្រូវបានឆ្លងទៅអនាគតជាតិ ពោលគឺជាតិជាសព្វសិទ្ធិនេះឯង។ នៅក្នុងទ្រឹស្តីកម្ម-ផល កាលបើកម្មខ្លះទៀតអាចផ្តល់ផលក្នុងជាតិជាលំដាប់តទៅទៀតគេហៅថា អបរាបរវេទនីយកម្ម។

តាមរយៈការលើកឡើងខាងលើនេះ អាចសបញ្ជាក់ឱ្យឃើញពីឥទ្ធិពលនៃព្រះពុទ្ធសាសនាបានជៀតចូលទៅក្នុងផ្នត់គំនិតខ្មែរ តាមរយៈស្នាដៃសាស្ត្រាល្បែងដែលជាតឹកតាងនៃអក្សរសិល្ប៍ពុទ្ធនិយមនាសម័យកណ្តាល។ ទាំងអស់នេះ។ ការទាំងនេះហើយដែលធ្វើឱ្យខ្មែរមានការខ្លាចអោនូវការប្រព្រឹត្តអំពើបាបទាំងឡាយ ដែលអាចនាំឱ្យខ្លួនធ្លាក់នៅក្នុងនរកអវចីជាដើម។ ឥទ្ធិពលពុទ្ធនិយមនេះជារនាំងមួយសម្រាប់បង្ខាំងមនុស្សឱ្យប្រព្រឹត្តល្អ អំពើជាកុសល ព្រមទាំងបន្ធូរភាពតានតឹងនៅក្នុងកាលៈទេសៈប្រទេសកំពុងមានកលិយុគបានផងដែរ។

## ៣- អក្សរសិល្ប៍ពុទ្ធនិយម

### ៣.១- ប្រភេទអក្សរសិល្ប៍ពុទ្ធនិយម

គោលគំនិតសំខាន់ៗនៃព្រះពុទ្ធសាសនាត្រូវបានបែកជាជាបីដែលគេហៅថា ព្រះត្រៃបិដក។ ព្រះត្រៃបិដកមានបីផ្នែកគឺ វិន័យបិដក(ព្រះវិន័យ) សុត្តន្តបិដក(ព្រះសូត្រ) និងអភិធម្មបិដក(ព្រះអភិធម្ម)។ ក្នុងនោះអក្សរសិល្ប៍ខ្មែរ

[33] យស ជិន, *ស្រទបចេក*, ពុទ្ធសាសនបណ្ឌិត្យ., ទំ. ៥២

[34] ហ៊ឹនកក្តីអក្សរ គន់, *រឿងសព្វសិទ្ធិ*, ពុទ្ធសាសនបណ្ឌិត្យ., ទំ. ១១

មួយចំនួនក៏បានដកស្រង់ចេញពីគម្ពីរព្រះពុទ្ធសាសនានេះដែរ។ អក្សរសិល្ប៍ពុទ្ធនិយមគឺជារឿងរ៉ាវអត្ថបទអក្សរសិល្ប៍ជាច្រើន ដែលអ្នកនិពន្ធបានដកស្រង់ចេញមកអំពីគម្ពីរក្នុងព្រះពុទ្ធសាសនា មានគម្ពីរព្រះត្រៃបិដក និងគម្ពីរអដ្ឋកថា ធម្មបទ វិសុទ្ធិមគ្គ មង្គលត្ថទីបនី ទសជាតក៍ និងបញ្ញាសជាតក៍ជាដើម មកតុបតែងជាចងក្រងជាវណ្ណកម្មរបស់ខ្លួន។[35] យោងទៅតាមលោក លាង ហាប់អាន លោកបានចែកអក្សរសិល្ប៍ពុទ្ធនិយមជាបីផ្នែកគឺ ពុទ្ធនិយមមែនទែន(ពុទ្ធនិយមសុទ្ធ) ពុទ្ធនិយមក្លាយ និង ពុទ្ធនិយមក្លាយហួសហេតុ(ពុទ្ធនិយមផ្លម)[36]។

អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ គឺជារឿងដែលស្ថិតនៅក្នុងជាតិទាំង១០របស់ព្រះពោធិសត្វមុនត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ ពុទ្ធនិយមសុទ្ធនេះស្ថិតក្នុងគម្ពីរទសជាតក។ រឿងទាំងនោះមានដូចជារឿង តេមិយជាតក ជនកជាតក សុវណ្ណសាមជាតកជាដើម។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយ គឺជាអក្សរសិល្ប៍ដែលអ្នកនិពន្ធបានដកស្រង់ ចេញអំពីគម្ពីរបញ្ញាសជាតក ជាគម្ពីរអដ្ឋកថាកើតមាននៅប្រទេសលាវ ត្រង់ឈៀងម៉ៃ ប្រហែល៥០០ឆ្នាំប៉ុណ្ណោះ[37] ។រឿងទាំងនោះមានដូចជា ព្រះសមុទ្ទឃោស រឿងព្រះសុធនកុមារ រឿងក្រុងសុភមិត្រ រឿងទេវន្ទ រឿងសុបិនកុមារ ជាដើម។

អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ(ពុទ្ធនិយមផ្លម)គឺជារឿងដែលពុំស្ថិតនៅក្នុងគម្ពីរ ក្បួនខ្នាតអំពីបុរាណណាមួយឱ្យបានច្បាស់លាស់ទេ ប្រសិនបើមានបញ្ជាក់នាម ក្បួនខ្នាតដើម គម្ពីរដើម គឺអ្នកនិពន្ធគ្រាន់តែថាប៉ុណ្ណោះ ពុំមានដំណើររឿងដូចគ្នាបេះបិទឡើយ ឧទាហរណ៍រឿងកាកី[38]។

### ៣-២. គំរោងនិពន្ធនៃរឿងបែបពុទ្ធនិយម

ចំពោះអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធនិងក្លាយ គេច្រើនសរសេរជាពាក្យរាយនិងកម្រងកែវ។ រីឯអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសត្រូវបានអ្នកនិពន្ធ ប្រើវិធីតែងជាពាក្យកាព្យ។ រឿងសឹងតែទូទៅតែងឡើងជាកំណាព្យដ៏មានបទផ្សេងៗគ្នា មានបទកាកគតិ ព្រហ្មគីតិ ភុជង្គលីលា បន្ទោលកាក ឬពំនោលជាដើម។ ការដែលយកពាក្យកាព្យមកប្រើបែបនេះជាមធ្យោបាយសម្របសម្រួលទៅតាមគោលបំណង ក្នុងឧត្តមគតិរឿងដែលបំពេរអារម្មណ៍ បន្ធូរក្តីទុក្ខព្រួយឱ្យរសាយនេះឯង[39]។

#### ក. ផ្តើមរឿង

ចំពោះការផ្តើមរឿងនៃប្រភេទអក្សរសិល្ប៍ពុទ្ធនិយមយើងឃើញមានលក្ខណៈឯកភាពគ្នាស្ទើរតែទាំងអស់ ដោយបានធ្វើបទនមស្ការ ព្រះរតនត្រ័យ គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រំឭកគុណគ្រូបាធ្យាយជាដើម។ ក្រៅពីនេះ ចំពោះអក្សរសិល្ប៍ពុទ្ធនិយមក្លាយនិងក្លាយហួសហេតុ កវីនិពន្ធក៏បាន សរសេររៀបរាប់អំពីថ្ងៃខែ ពេលវេលានៃការ

[35] ម៉ុញ សារី, *វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ*, មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាពកម្ពុជា, ២០១១, ទំ. ២៦៤

[36] លាង ហាប់អាន, *សិក្សាអត្ថបទអក្សរសិល្ប៍ខ្មែរ* ភាគ១, ១៩៦៦, ទំ.១៨២-១៣៧

[37] ម៉ុញ សារី, *វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ*, ដ.ឯ.ម, ទំ. ២៦៤

[38] លាង ហាប់អាន, *សិក្សាអត្ថបទអក្សរសិល្ប៍ខ្មែរ ភាគ១*, ១៩៦៦, ទំ.២៣៦

[39] លាង ហាប់អាន, *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ,* ដ.ឯ.ម., ទំ. ២១៦-២១៧

តាក់តែងនិពន្ធ ដោយពេលខ្លះជាពុទ្ធសករាជ មហាសករាជ ចុល្លសករាជជាដើម។ បន្ទាប់មកអ្នកនិពន្ធអាចប្រាប់អំពីគោរម្យ៍ងារ ឋានៈ ឬ នាមរបស់ខ្លួនមកបញ្ជាក់។

ឧ. នៅក្នុងរឿងហង្សយន្ត អ្នកនិពន្ធបានលើកបានឡើងដូច្នេះ

| | | |
|---|---|---|
| អហំយើងខ្ញុំ | ក្រួញក្រាបប្រណម | ព្រះអង្គឥតធ្លង |
| កាលកបសន្លឹក | ពោធិព្រឹក្សទន្ទង | ព្រះអង្គជាច្បង |
| | ទូទាំងត្រៃភព។ | |
| ស្តេចដូចភារកេ | ត្រាត្រាច់ត្រដែត | ត្រដឹងស្កប់ស្កប់ |
| ផ្ទុកសត្វនិករ | អមរសោយសព្វ | នានាំគ្រាន់គ្រប់ |
| | ដាក់ដល់និព្វាន។ | |
| បង្គំព្រះធម៌ | ប្រសើរមានអាថ៌ | ជាសំណាញ់ពាណ |
| សម្តេចពុទ្ធវង្ស | ស្រោចស្រង់សត្វបាន | បរិបូណ៌ឋិតឋាន |
| | សុខសួគ៌ទៀងទាត់។ | |
| បង្គំសង្ឃសាង | សីលសុទ្ធលះលាង | បាបបោះបង់បាត់ |
| ទុកសោកប្រាយប្រាស | លាកលះស្នេហ៍ស្និទ្ធ | សេពសោយសម្បត្តិ |
| | សួគ៌សួស្តីសេដ្ឋា។[40] | |

ជាទូទៅយើងសង្កេតឃើញថា ក្នុងផ្នែកនៃសេចក្តីផ្តើមនេះ ស្ទើតែគ្រប់រឿងពុទ្ធនិយមក្លាយនិងក្លាយហួសហេតុ សុទ្ធតែប្រើកាព្យ បទកាកគតិ[41]។

**ខ. ដំណើររឿង**

ចំពោះដំណើររឿង ច្រើននិយាយពីជីវិតនៃពូជពង្សរាជវង្សានុវង្សនៃព្រះពោធិសត្វ ហើយដែលធ្វើទានសន្សំកុសលបារមីផ្សេងៗ។រីឯរឿងខ្លះបង្ហាញពីព្រះពោធិសត្វធ្វើចម្បាំងជាមួយស្តេចយក្ស ស្តេចមនុស្ស សត្រូវគ្រប់ទីទិស ឬ ពេលខ្លះជាមួយក្រុមគ្រួសារ ញាតិវង្សដែលក្បត់គ្នាចង់ដណ្តើមរាជសម្បត្តិ ហើយភាគច្រើនតួអង្គឯកដែលតំណាងសភាវៈល្អរមែងមានជ័យជំនះលើសភាវៈអាក្រក់ជាប់ជានិច្ច។ ពេលខ្លះជម្លោះត្រូវបានបញ្ចប់ដោយសន្តិវិធី ដោយការប្រើប្រាជ្ញាក្នុងការផ្ចាញ់សត្រូវ ឯពេលខ្លះទៀតក៏មានការធ្វើចម្បាំងគ្នាដែលជាឥទ្ធិពលរឿងនៅសេសសល់ពីទំនោរលទ្ធិព្រាហ្មណ៍និយម។ ភាគច្រើនតួអង្គច្រើនតែជាស្តេចនិងមានសិទ្ធិធំធេងលើស្ត្រី ដោយគេអាចមានប្រពន្ធច្រើនដោយគ្មានការតវ៉ាពីប្រពន្ធដើមតែជានិច្ចកាលប្រពន្ធទាំងឡាយតែងតែមានការច្រណែន និន្ទា ឈ្នានីសគ្នាឬដណ្តើមរាជសម្បត្តិគ្នាទុកឱ្យកូនរៀងៗខ្លួន បង្កទៅជាទំនាស់មានការបែងចែងបក្សពួក កាប់ចាក់គ្នាពេញវាំង។

[40] *ហង្សយន្ត*, ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥៥២, ទំ.១

[41] សេង សោភា, *សាស្ត្រាល្បែង*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ មុខជំនាញអក្សរសិល្ប៍ រាជបណ្ឌិត្យសភា, ២០០៤,ទំ. ៧៤

ពេលខ្លះដំណើររឿងនិយាយពី បញ្ហាកម្មផលដែលតួអង្គបានប្រព្រឹត្តទៅពីអតីតជាតិហើយវាឆ្លងមកដល់បច្ចុប្បន្នជាតិជាដើម។ ម្យ៉ាងទៀត ដំណើររឿងខ្លះទៀតក៏បានបង្ហាញពីលក្ខណៈដែលនាំឱ្យឈានទៅរកគំនិតបែបវិទ្យាសាស្ត្រផងដែរដូចជារឿងហង្សយន្តជាដើម។

ចំណែកឯដំណើររឿង នៅក្នុងផ្ទៃរឿងមានជួប ព្រាត់ទុក្ខសោក សប្បាយ សង្គ្រាមកាប់ចាក់ស្លាប់ ដណ្តើមរាជ្យគ្នា តណ្ហា ប្រណែន ឈ្នានីស គឺសុទ្ធសឹងជាជីវិតពិតរបស់មនុស្សក្នុងសង្គម ឬលក្ខណៈមនុស្សនិយម។

ឧ. នៅក្នុងរឿងព្រះជិនវង្សជាដើម ស្តេចជិះហង្សទៅមានប្រពន្ធពីនគរមួយទៅនគរមួយនិងមានមហេសីដល់ទៅប្រាំពីរដោយពុំមានការរិះគន់ជិនធ្ងន់ពីសង្គមឡើយ។គេចាត់ទុកជារឿងធម្មតា សម្រាប់បុរសភេទជាពិសេសបុរសដែលមានពូជពង្សខ្ពស់មានឋានៈបុណ្យសក្តិឬជារាជវង្សជាដើម។ ក្រឡេកមើលរឿង កាកី ស្តេចមានស្រីស្នំរាប់ពាន់ រឿងស្រទបចេក ស្តេចមានមហេសីពីរគឺនាងកេសរមាលា និងនាងកេសរបុប្ផា រឿងពុទ្ធិសែននាងកង្រី ស្តេចមានមហេសី១៣រួមទាំងនាងយក្សសន្ធមារ រឿងសង្ខសិល្បជ័យ ស្តេចមានមហេសីម្តង៧ នេះមិនគិតពីស្រីស្នំ ភីលៀង មីនំមីនាងជុំវិញចាំគាត់បម្រើផង ក្នុងខណៈដែលភរិយា មហេសី និងស្នំទាំងនោះត្រូវបានគេប្រដៅឱ្យប្រកបដោយកក្តីភាព ស្មោះត្រង់នឹងប្តី ស្លាប់រស់ជាមួយស្វាមីតែម្នាក់ហើយបើករណីនាងធ្វើមិនបានឬបំពាននោះមិនត្រឹមតែស្វាមីនោះទេ សូម្បីសង្គមទាំងមូលមនុស្សស្រីដូចគ្នាក៏ថ្កោលទោសនាងដែរ។ នេះជាឧទាហរណ៍គំរូមួយ ដែលជាគុណវិបត្តិពិតៗរបស់សង្គមដែលមនុស្សប្រុសតែងតែឆ្លៀតកេងចំណេញយកប្រៀបលើស្ត្រីតាំងពីផ្នែកកម្លាំងកាយ កម្លាំងចិត្ត ផ្នែកជីវភាពរស់នៅនិងតតាំងទស្សនៈក្នុងសង្គមជាដើម។[42]

ចំពោះវិធីសរសេរ គឺគេប្រើពាក្យកាព្យចម្រុះបទគ្នាពីដើមដល់ចប់ក្រៅពីនេះក៏ឃើញមានការប្រើកាព្យកាកគតិសុទ្ធពីដើមដល់ចប់ច្រើនដែរ ឯបទអ្វីផ្សេងកម្រឃើញមានការសរសេរសុទ្ធ ពីដើមដល់ចប់ដូចបទកាកគតិនេះឡើយ។

អ្នកនិពន្ធប្រើពាក្យពេចន៍ធម្មតាលាយឡំនូវមគធភាសាឬសំស្ក្រឹតបន្តិចបន្តួចតាមចំណេះដឹងរបស់ខ្លួនក្នុងការតែងរៀបរៀង[43]។

**គ. បញ្ចប់រឿង**

ចំពោះបញ្ចប់រឿង អ្នកកវីនិពន្ធភាគច្រើនបញ្ចប់រឿងដោយមានការសជាតិ ចំពោះរឿងទាំងឡាយដែលមានប្រភពមកពីបណ្ណាសជាតកឬនានាជាតកជាដើម។ ម្យ៉ាងវិញទៀតរឿងមួយចំនួនតូចខ្លះអាចបញ្ចប់ដោយការធ្វើការឧទ្ទិសប្រាថ្នានូវកងកុសលជាបែបអធិដ្ឋាន។ រីឯរឿងមួយចំនួនទៀត នៅចុងបញ្ចប់អ្នកនិពន្ធបានប្រាប់នូវស្តេចចម្លងមកពីប្រទេសជិតខាងទៅវិញ។ នេះក៏ដោយសារនាកាលសម័យខ្មែរបែកបាក់ ឯកសារទាំងអស់នោះត្រូវបានសៀមយកទៅ ក្រោយពីប្រទេសបានសុខស្រួលអ្នកចេះដឹងបានទៅពីសៀមហើយចម្លងមកវិញហើយក៏បញ្ជាក់ថាជាសេចក្តី ប្រែសម្រួលដូច្នេះ។

ឧ. នៅក្នុងរឿង ពុទ្ធិសែននាងកង្រី ដែលបានបង្ហាញពីការសជាតិរបស់តួអង្គមួយចំនួនដូចជា៖

[42] សេង សោភា, *សាស្ត្រាល្បែង*, ដ.ឯ.ម., ទំ. ៧៤
[43] លាង ហាប់អាន, *សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ*, ដ.ឯ.ម., ទំ. ២១៨

ភិក្ខុអើយរីស-  ន្ទមារកាចក-  ន្លងលោកទាំងឡាយ
ឥឡូវចាកចេញ  វិលវិញពុំឆ្ងាយ  ទ្រឹស្តិទ្រុស្តសប្បាយ
ចោរចិត្តឫស្យា។
យោនយកកំណើត  កំណត់ទៅកើត  ជាចិញ្ចារិកា
ធ្លាក់ទៅនរក  ទល់ទុក្ខវេទនា  លលៀកមិនត្រា
មិនបានរំដោះ។
រីមណីកែវសូរ  នាំពុទ្ធង្កូល  លីលាហៀរហោះ
ជាមោគ្គល្លាន  ស្រេចបានរឹងស្មោះ  លើសលែងចំពោះ
ប្រសើរពេកពន់។
រីព្រះតាបស  ទ្រង់ធម៌សប្បុរស  ប្រសើរពេកពន់
យោងយកជាតិជា  ព្រះមហាអនន្ត  អនេកគ្រប់គ្រាន់
ចែកចប់ម្ល៉េះហោង។[44]

ការបញ្ចប់រឿងបែបនេះ ធ្វើឱ្យស៊ីសង្វាក់ទៅនឹងប្រភេទរឿងជាតកនានា ទោះបីជាពេលខ្លះ ការសជាតិនេះពុំសូវត្រឹមត្រូវសមហេតុផលដូចទសជាតក ឬបញ្ញាសជាតកក៏ដោយ។ នេះដោយហេតុថា សាស្ត្រាល្បែងជាអក្សរសិល្ប៍ពុទ្ធនិយមក្លាយខេមរនិយម ដូច្នេះបានផ្តុំចម្រុះនូវទេវៈនៃសាសនានិងជីវភាពរស់នៅពិតៗរបស់មនុស្សពោលគឺពុទ្ធនិយមលាយព្រាហ្មណ៍និយម និងក្លាយខេមរនិយម។

## ៤- តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរ

### ៤.១- ការអប់រំចរិយាសាស្ត្រ

យើងតែងតែឮអំពីការសរសើរថាមនុស្សជំនាន់មុនរៀនក្រោមសាលាវត្តអារាមគ្មានសៀវភៅ ទំនើបបោះពុម្ព តែហាក់បីដូចជាមានសីលធម៌ ប្រកបដោយសេចក្តីយោគយល់អធ្យាស្រ័យ ឬក៏ចេះគោរពឱនលំទោន ម្តាយឪពុក ចាស់ព្រឹទ្ធាចារ្យ ព្រមទាំងចេះស្គាល់បុណ្យបាប ល្អអាក្រក់ជាដើម។ រីឯបច្ចុប្បន្ន វិទ្យាសាស្ត្ររីកចម្រើន ការសិក្សាបានខ្ពង់ខ្ពស់ មានសាលាទំនើបនៅក្នុងការសិក្សា ផ្ទុយទៅវិញ បញ្ហាសីលធម៌ហាក់បីដូចជាធ្លាក់ចុះគួរឱ្យកត់សម្គាល់។ តួយ៉ាងព្រះរាជសុន្ទរកថាក្នុងវេទិកាអរិយធម៌អាស៊ីលើកទី១នៅប្រទេសចិន ព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់មានព្រះរាជបន្ទូលថា “*បច្ចុប្បន្ននេះសាកលលោកយើងកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការរីកចម្រើន និងជឿនលឿន ដោយមានជំនាញខាងវិទ្យាសាស្ត្រ និងសម្ភារៈដែលមិនធ្លាប់មានពីមុន។ ប៉ុន្តែទន្ទឹមនឹងការរីកចម្រើនខាងលើនេះសីលធម៌និងអភិសមាចារ ក្នុងជីវភាពសង្គម ក៏មានការស្រុតចុះគួរឱ្យព្រួយបារម្ភណាស់ដែរ។...*” ត្រង់នេះអាចឱ្យយើងឃើញពីការព្រួយបារម្ភ មិនចំពោះតែកម្ពុជា តែសម្រាប់សាកលលោកទាំងមូលអំពីបញ្ហាសីលធម៌នេះ។

---

[44] ***ពុទ្ធិសែន***, ពុទ្ធសាសនបណ្ឌិត្យ, ១៩៧២, ទំ. ២០៤

### ក- សីលធម៌

អក្សរសិល្ប៍ពុទ្ធនិយម នាសម័យកណ្តាលបានដើរតួនាទីសំខាន់នៅក្នុងការក្រិត គួសវង់នូវការប្រព្រឹត្តរបស់មនុស្សឱ្យដើរតាមផ្លូវមួយដ៏ល្អ ក្លាយជាពលរដ្ឋប្រពៃសម្រាប់សង្គមជាតិ។ ភាពចម្រុះពណ៌នៃការអប់រំទៅលើសីលធម៌របស់មនុស្សនេះហើយបានធ្វើឱ្យអក្សរសិល្ប៍ពុទ្ធនិយមនេះបានបន្តអត្ថិភាពមកបច្ចុប្បន្នយើងនេះផងដែរ។

ជាការពិតណាស់ការរស់នៅក្នុងសង្គមមិនសំងំយកតែសុខបានតែម្នាក់ឯងឡើយ ពោលគឺយើងត្រូវពឹងពាក់ជួយគ្នាទៅវិញទៅមកទើបយើងអាចរស់នៅប្រកបដោយក្តីសុខពិត។ តួយ៉ាងនៅក្នុងរឿងព្រះវេស្សន្តរដែលជាជាតិទី១០របស់ព្រះពុទ្ធអង្គមុននឹងត្រាស់ជាព្រះសម្មាសម្ពុទ្ធនោះ ទ្រង់បានបំពេញនូវទានបារមីយ៉ាងក្រាស់ក្រែលបំផុត។ក្នុងចំណោមមហាទានទាំងប្រាំនោះ យើងងាកមកចាប់អារម្មណ៍លើការបំពេញធនបរិច្ចាគ។ នៅពេលស្តេចស្រុកព្រាហ្មណ៍ឈ្មោះកលិង្គរាស្ត្រនៅឯទុរ្ពិក្ខគ្រាម មានគ្រោះទុរភិក្ស គ្មានភ្លៀងធ្លាក់ ស្រូវដំណាំក៏ខូចខាត ទើបទ្រង់ត្រាស់ចាត់ឱ្យព្រាហ្មណ៍ទាំងប្រាំបីមាន រាមព្រាហ្មណ៍ ធជព្រាហ្មណ៍ លក្ខណព្រាហ្មណ៍ សុជាតិព្រាហ្មណ៍ កោណ្ឌញព្រាហ្មណ៍ សុយាមព្រាហ្មណ៍ យញ្ញព្រាហ្មណ៍ សុជាតមន្តព្រាហ្មណ៍ឱ្យទៅសុំដំរី បច្ច័យនាគេន្ទ្រដែលជាដំរីនាំមកនូវមង្គលនោះ។ ដោយយល់ឃើញនៅលក្ខណៈបែបនេះហើយទើបធ្វើឱ្យព្រះវេស្សន្តរទ្រង់សុខចិត្តបរិច្ចាគឱ្យទោះបីជាមានការមិនពេញចិត្តពីសំណាក់ប្រជានុរាស្ត្រក៏ដោយ។ ត្រង់នេះអាចឱ្យយើងឃើញពីចិត្តសប្បុរសធម៌ មនុស្សធម៌របស់ព្រះវេស្សន្តរក្នុងនាមបុគ្គលនៅក្នុងសង្គម ដោយមិនអាចឈរមើលមនុស្សជាតិទាំងមូលស្លាប់ដោយដាច់ស្បៀងយ៉ាងអាណោចអធ័មនោះទេ។

ជាតម្លៃសីលធម៌ ក៏ទោះបីជាមនុស្សយើងធ្វើខុសចំពោះអ្នកណាក៏ដោយ ការដែលភ្ញាក់រឭក ដឹងនូវទង្វើរបស់ខ្លួនដែលបានធ្វើខុសកន្លងនោះ ក៏ចាត់ចូលជាផ្នែកសីលធម៌មួយដ៏សំខាន់ផងដែរ។ ជាក់ស្តែងនៅពេលព្រះបាទបិលយក្សបានបាញ់ធ្នូសរចំសុវណ្ណសាមហើយនោះ ព្រះអង្គក៏បាននឹកស្តាយក្រោយចំពោះអំពើរបស់ខ្លួនដែលបានជ្រុលជ្រួសនោះ។ ការដែលបាញ់ចំសុវណ្ណសាមនេះ មិនបានធ្វើឱ្យសុវណ្ណសាមឈឺចាប់ទេ សាមបានសោកស្តាយព្រោះគ្មានអ្នកមើលថែម្តាយឪពុកខ្លួន។ ដោយការគិតពិចារណា ព្រះបាទបិលយក្សមិនអាចឈរមើលម្តាយឪពុករបស់សាមនៅកំព្រាទាំងខ្វាក់នេត្រានោះទេ។ ព្រះអង្គសុំខ្លួនចូលទៅបម្រើអ្នកទាំងពីរជំនួសសាម។ ត្រង់នេះបញ្ជាក់ពីការភ្ញាក់រឭករបស់ទ្រង់ ព្រមទាំងការទទួលខុសត្រូវមួយចំពោះអ្វីដែលខ្លួនបានធ្វើឡើង។ វាបានជួយជាគំនិតដល់ជនានុជនឱ្យចេះលុបលាងនូវកំហុសរបស់ខ្លួនដែលបានកសាងតាមរយៈការភ្ញាក់រឭក និងប្រឈមមុខនឹងអំពើរបស់ខ្លួនបានធ្វើក្នុងនាមជាមនុស្សជាតិ។

ក្នុងរឿងក្រុងសុភមិត្រ ដែលស្ថិតនៅក្នុងបញ្ញាសជាតក ហើយត្រូវបានតាក់តែងនិពន្ធជាបទកាព្យដោយឧកញ៉ាកោសាធិបតី កៅ នោះក៏បានឆ្លុះបង្ហាញពីតម្លៃខាងផ្នែកសីលធម៌ផងដែរ។នៅពេលដែលចាប់ដៃគ្នាជាប្តីប្រពន្ធ អ្នកទាំងពីរបីដូចជារូបមួយជីវិតពីរដូច្នេះឯង។ ម្ល៉ោះហើយអ្នកទាំងពីរត្រូវរួមសុខរួមទុក្ខជាមួយគ្នាមិនថាគ្រាណាក៏ដោយ។ ស្ថិតក្នុងវេលាដ៏លំបាកនៃការបាត់បង់រាជ្យសម្បត្តិទៅឱ្យអនុជក្រុងអសុភមិត្រ ព្រះបាទសុភមិត្របានលាមហេសីយាងទៅកាន់ព្រៃតែឯកឯង។ ប៉ុន្តែត្រូវបានព្រះនាងកេសនីជំទាស់ សុំយាងទៅតាមស្វាមីផង។ ដូចលើកឡើងថា៖

| | | |
|---|---|---|
| បើស្តេចចៀសចាក | ឱ្យប្អូនលំបាក | សមនឹងក្សីណក្ស័យ |
| ប្អូនសុំទៅផង | រួមរងក្សត្រថ្លៃ | ប្រការម្តេចក្តី |
| | ពុំលែងឡើយហោង។(ទំ. ១៤) | |

ត្រង់នេះបើយើងងាកចេញពីតួអង្គកន្សែសារពេជ្ជ យើងអាចឃើញពីភក្តីភាពរបស់មនុស្សស្រីធម្មតា ដែលតែងត្រាច់រង្គត់ទៅតាមស្វាមីគ្រប់ទិសទី។ ភក្តីភាពរបស់ព្រះនាងកេសនីនេះហើយ បានផ្តល់ជាតម្លៃខាងផ្នែកសីលធម៌នៅក្នុងក្រុមគ្រួសារឱ្យស្រឡាញ់គ្នាមិនមែនតែពេលមានបាននោះទេ តែត្រូវថែរក្សាគ្នារហូតដល់ចាស់កោងខ្នង ហើយគ្រប់កាលៈទេសៈទៀតផង។

រីឯរឿងទេវន្ទរបស់ អម្រឹតក្សត្រីម៉ុក ដែលតែងជាបទកាកគតិទាំងនោះ បានឆ្លុះបញ្ចាំងអំពីទស្សនៈបញ្ហាសីលធម៌ជាច្រើន ដែលអប់រំចរិយាសាស្ត្រមនុស្សឱ្យក្លាយជាមនុស្សល្អនៅក្នុងសង្គម។ តួយ៉ាងនាងចន្ទាដែលជាប្អូនរបស់ទេវន្ទ នៅពេលដែលគេចចេញពីយក្សនន្ទិដែលក្លែងជាបិតា នាងចន្ទាបានទៅដល់នគរហេមន្ត ហើយបានជួបនឹងរាជបុត្រមួយអង្គឈ្មោះ អភ័យកុមារ។ ត្រង់នេះ អ្នកទាំងពីរបានលបលួចរួមរ័ក្សទាំងក្មេងវ័យ ដោយមិនឱ្យបងដឹង។ មិនត្រឹមតែប៉ុណ្ណោះ អ្នកទាំងពីរបានរកល្បិចកល ដើម្បីប៉ុនប៉ងសម្លាប់ទេវន្ទទៀត ដូចលើកបង្ហាញ៖

| | | |
|---|---|---|
| ភ័យកុមារ | យាងទៅទាស់ទ្វារ | អរឱបអង្គនាង |
| ព្រឺព្រួចស្នេហ៍សិទ្ធ | ជួយជិតសារពាង្គ | លើកពយាសយាង់ |
| | ចូលក្នុងស្គរមាស។ | |
| នាងផាត់នាងប្រាន | ប៉ុន្មានៗ | ពុំមានលាកលះ |
| រួបរឹតអស់អង្គ | ប្រតិយង្គមិត្រមាស | ព្រឺព្រួចរួមវា- |
| | ស្នាសិទ្ធស្នេហា។ (ទំ. ១១៨) | |

ត្រង់នេះហើយបានបង្ហាញឱ្យឃើញពីគំនិតនៅក្មេងវ័យ ឈាមរាវ ដោយយកកាមតណ្ហាដឹកមុខភ្លេចអ្វីទាំងអស់ ដែលខ្លួនជាស្ត្រី។ ម្យ៉ាងទៀតដោយអំពើទាំងនេះ នាំឱ្យនាងនិងភ័យកុមារ មានចិត្តឈានទៅសម្លាប់ទេវន្ទដែលជាបងតែមួយទៀតផង។ ក្នុងន័យនេះ ការកសាងគ្រួសារនៅក្នុងវ័យក្មេងពេកនាំឱ្យពួកគេងាយនឹងប្រព្រឹត្តអំពើផ្តាំផ្តង ព្រោះចិត្តនៅចង់សប្បាយ។ លើសពីនេះ ដំណើររបស់នាងចន្ទាហាក់កំពុងភ្លេចអ្វីទាំងអស់សូម្បីតែបង កម្រត់កម្រជាមួយគ្នានៅក្នុងព្រៃ ក៏ដាច់ចិត្តសម្លាប់។ វាឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាសីលធម៌ក្នុងនាមជាមនុស្ស មិនត្រូវភ្លេចបងប្អូនដែលជាឈាមរួមឧទរជាមួយ ក៏ទោះបីជាអ្នកមានប្តីឬប្រពន្ធ បងប្អូននៅតែជាមនុស្សដែលតាមជួយអ្នក ដូចពាក្យចាស់បុរាណលើកឡើងថា «កាត់ទឹកមិនដាច់ កាត់សាច់មិនបាន»។

នៅក្នុងបទនិពន្ធរបស់ព្រះឃ្លាំងនង សាស្ត្រាល្បែងភោគកុលកុមារយើងក៏ឃើញបានពន្លេចឱ្យឃើញពីបញ្ហាសីលធម៌ជាចម្បងដែលនាំឱ្យឈានទៅរកអធិករណ៍នៃរឿង។ ក្នុងចំណោមការអប់រំនោះយើងឃើញកវីនិពន្ធបានលើកយកចំណុចមួយក្នុងការអប់រំសីលធម៌ ចរិយាសាស្ត្ររបស់នារីខ្មែរ តាមរយៈតួអង្គព្រះមាតារបស់នាងសុខុមាលន្ទាដោយព្រះនាងលើកពី ភរិយាកាឡណ្ណីដែលមានបីប្រភេទគឺ៖

១.ឃាដភរិយា៖ តាមរយៈរឿងភោគកុលកុមារលោកបានចែកឃាដភរិយាចំនួនបួនប្រការគឺ ប្រការទី១ ជាស្ត្រីរឹងរូស ប្រទូស្តរាយនឹងប្តី សម្លក់សម្លឹងពោលពាក្យទ្រគោះបោះបោកជាដើម។ រីប្រការទី២ ចិត្តស្រើបស្រាល លួចទៅរួមរ័ក្ស មានសហាយជាមួយអ្នកដទៃ។ រីប្រការទី៣ មិនចេះកោតខ្លាចគោរពស្វាមី ដេរស្តីជំពៀលមើលងាយប្តីជាដើម។ រីប្រការទី៤ មានចិត្តកំណាច ទៅនិយាដើមប្តី និយាយអាក្រក់ពីប្តីឱ្យអ្នកផងដឹងឮជាដើម។

២. ចោរភរិយា៖ ការលើកឡើងនៅក្នុងរឿងចោរភរិយាមានប្រាំប្រការគឺ ប្រការទី១ ពុំខិតខំធ្វើការងារ ឬពុំរៀបចំប្រដាប់ប្រដាឱ្យប្តីទៅបំពេញកិច្ចការ។ ប្រការទី២ ពុំចេះសន្សំសំចៃ គិតតែចាយទ្រព្យប្តី បង្ខិនឱ្យទៅមិត្តភក្តិស៊ីចាយសប្បាយ ពុំចេះគិតគូរជាដើម។ ប្រការទី៣ មាសប្រាក់ដែលប្តីបានរកមកហើយបានពុំចេះទំនុកបម្រុង ទុកដាក់គិតតែចាយវាយតែផ្តាស។ ប្រការទី៤ គិតតែចេះតុបតែងខ្លួន ដើរលេងស៊ីផឹកបនភៀន មានសហាយហើយស្អប់ប្តីខ្លួនឯងជាដើម។ រីប្រការទី៥ លោកចែងថា បើប្តីស្រឡាញ់ហើយនោះធ្វើចិត្តធំ ង៉ឹកង៉ក់ជាដើមធ្វើឱ្យប្តីអាក់អន់ចិត្ត។

៣. សត្រូវភរិយា៖នៅក្នុងរឿងភោគកុលកុមារ សត្រូវភរិយាលោកចែកមានប្រាំមួយប្រការគឺ ប្រការទី១ ពុំចេះទំនុកបម្រុងប្តី ពុំតាមចិត្តប្តី ពោលគឺយកតែតាមចិត្តខ្លួនឯង។ ប្រការទី២ ពុំចេះរៀបចំអាហារឱ្យប្តី បើមានចំណីគិតតែធីតែម្នាក់ឯង។ ប្រការទី៣ លោកហាមមិនឱ្យមានចិត្តធំជាងស្វាមី ពោលពាក្យបន្ថោកបង្អាប់ឱ្យប្តី។ ប្រការទី៤ មានចរិតកោងកាច គិតតែដេរប្រទេសផ្តាសា បន្ទោសប្តីពុំគិតពីបាប។ ប្រការទី៥ កាលបើប្តីមានទុក្ខគិតតែមើលបំណាំ ពុំជួយសម្រាលទុក្ខ ហើយបើប្តីឈឺពុំទៅរកថ្នាំសង្កូវឬ ហៅពេទ្យហ្មមកមើលប្តីឡើយ។ និងប្រការទី៦ នៅពេលប្តីស្តីប្រដៅខឹងប្រឡោតនឹងប្តីដោយពោលពាក្យទ្រគោះបោះបោកជាដើម។

ក្រៅអំពីការអប់រំនូវសីលធម៌របស់ស្ត្រីហើយ ព្រះឃ្លាំងនងក៏បានបង្ហាញពីទុក្ខទោសដែលភរិយា បានប្រព្រឹត្តនូវកាឡណ្ណីភរិយានេះនោះនឹងធ្លាក់ទៅនរករងទុក្ខពន់ពេក អស់កាលមួយកប្បទើបរួចមក កើតជាស្រីផ្កាមាស ឬជាយក្ខិនី ឬជាស្ត្រីមេម៉ាយអស់កាលប្រាំរយជាតិ។ សូម្បីតែស្ត្រីនោះបានកសាងទានខ្លះក៏ដោយក៏ពុំអាចមាននរណាម្នាក់ជួយឱ្យរួចផុតបានដែរ ដោយសារស្ត្រីនោះមានចិត្តក្រៅធម៌។

លើសពីនេះព្រះមាតារបស់សុខុមាលទ្ធាទេវីក៏បានងាកទៅអធិប្បាយអំពី ឥរិយាបទទាំងបួនប្រភេទដែលភរិយាគួរប្រព្រឹត្តតាមនោះរួមមាន៖

១. មាតុភរិយា៖ព្រះនាងបានលើកមាតុភរិយាមានប្រាំប្រការគឺ ប្រការ១ ចេះរក្សាទ្រព្យធនដែលប្តីបានរកមកកុំឱ្យបង់បាត់ជាដើម។ ប្រការទី២ ចេះឈឺឆ្អាលពេលប្តីមានទុក្ខ ឬមានជំងឺឈឺថ្កាត់ ត្រូវចេះរត់រកពេទ្យមកជួយព្យាបាលថែទាំ។ ប្រការ៣ កាលបើមានម្ហូបអាហារថ្មីៗល្អៗត្រូវចេះទុកឱ្យស្វាមីជាអ្នកបរិភោគផង។ ប្រការ៤ ចេះទំនុបបម្រុងប្តីក្នុងរបរការងាររកស៊ីជួញប្រែទាំងឡាយ។ ប្រការ៥ ជាស្ត្រីត្រូវចេះរាប់អានញាតិផៅ កាលបើមាននំនែកត្រូវចេះចែកជូនញាតិកុំកំណាញ់តែឯង។

២. ភគិនីភរិយា៖ តាមរយៈរឿងលោកបានលើកពីភគិនីភរិយាមានបួនប្រការគឺ ត្រូវចេះស្រឡាញ់ប្តី ហើយទុកដូចជាបងខ្លួន។ ប្រការ២ ត្រូវចេះមានចិត្តអំណត់ ពុំឈ្លោះរករឿងនឹងអ្នកបម្រើផងទាំងពួង។ ប្រការ៣ ត្រូវចេះគាល់

បម្រើ ប្រណិប័តន៍ប្ដី មិនត្រូវប្រចណ្ឌញិកញ៉ក់ រំខានចិត្តប្ដី។ ប្រការ៤ មានមារយាទត្រឹមត្រូវមិនត្រូវហិចហើរនាំឱ្យប្រុសដទៃយល់បាននោះឡើយ។

៣. មិត្តភរិយា៖ លោកលើកឡើងថាមិត្តភរិយាមានបីប្រការគឺ ប្រការ១ មិនប្រទូស្តរាយ រឹងរូសបណ្ដាលឱ្យប្ដីមានការអាក់អន់ស្រពន់ចិត្ត។ ប្រការ២ ត្រូវចេះស្រឡាញ់ប្ដី រាក់ទាក់ដូចមិត្ត។ ប្រការ៣ ត្រូវមានអនុកូល(សេចក្ដីទំនុកបម្រុង សង្គ្រោះ ករុណា ពេញចិត្ត)នឹងស្វាមី ពុំមានកលល្បិចអ្វីឡើយ។

៤. ទាសភរិយា៖ លោកបានលើកពីទាសភរិយា មានបីប្រការគឺ ប្រការ១ ស្មោះស្ម័គ្រនឹងប្ដី មានសំដីពីរោះ ចេះផ្ញើខ្លួនលើប្ដីឱ្យប្ដីអាណិត។ ប្រការ២ បើស្វាមីស្រឡាញ់ស្រីស្នំបរិពារ ត្រូវចេះជួយស្រឡាញ់ បំពេញចិត្តប្ដីដោយក្ដីស្មោះស្ម័គ្រ។ ប្រការ៣ បើប្ដីខេខឹងស្រដីត្រគោះបោះបោកជេរទាំងប៉ុន្មានក៏កុំឆ្លើយឈ្លោះត ត្រូវសាសងមកវិញដោយពាក្យពីរោះវាចា។

កាលបើស្ត្រីទាំងអស់ត្រូវបានធ្វើដូចស្ត្រីទាំងបីប្រភេទខាងលើ នោះគេមិននិន្ទាដល់ម្ដាយ។ មិនត្រឹមតែប៉ុណ្ណោះទេព្រ័ក្ស ទេវតាទាំងឡាយ ជួយជ្រោមជ្រែងឱ្យពរ សុខសប្បាយ លុះចប់ជាតិទៅសោយសុខនៅឋានតុសិត មានប្រាង្គប្រាសាទល្អ មានស្រីទេពអប្សរទាំងឡាយរៀបជាជួរចាំគាល់ត្រៀបត្រាក្រាស់ក្រៃ។ ម្យ៉ាងបើអស់បុណ្យនៅឋានសួគ៌នឹងច្យុតមកកើតនាត្រកូលក្សត្រ មានប្រាជ្ញាដូចទេវតាជាស្រីគ្រប់លក្ខណ៍។ មិនត្រឹមតែប៉ុណ្ណោះ នាងនឹងបានជាមហេសីក្សត្រា បរមចមចក្រាធិរាជ នរណាទៅប្រៀបផ្ទឹមបាន។ ទោះបីជាចង់បានប្រាថ្នាជាកន្សែសារពេជ្ជ ក៏បានដូចចិត្ត ព្រោះជាបុណ្យរបស់នាង។

បើយើងងាកមកមើលសាស្ត្រាមរណមាតា ដែលពេញនិយមរបស់ខ្មែរគ្រប់ស្រទាប់វណ្ណៈ ហើយវាបានក្លាយជាផ្នត់គំនិត ទស្សនៈខ្មែរចំពោះត្រីដំរី ដែលគិតថាជាមនុស្សចាប់ជាតិ នាំឱ្យប្រជាជនមិនបរិភោគទៀតផង។ ក្នុងនោះ កវីក៏បានលើកយកបញ្ហាសីលធម៌មកពន្លេចជាចម្បងនៃចំណោទបញ្ហារឿង។ ចាប់ចេញពីបញ្ហាពុំចេះស្ដាប់បង្គាប់របស់មេបាដូចនាងកុលកេសីដែលជាកូនរបស់សេដ្ឋីបានទៅលបលួចស្នេហា ទំុមុនស្រគាលជាមួយនឹងកុដុម្ពីក៏ក្បែរផ្ទះ រហូតនាំគ្នាពង្រាត់ចេញពីផ្ទះទៅឆ្ងាយ ដូចលើកឡើងថា៖

| | | |
|---|---|---|
| កុដុម្ពីក៏សោតបាន | រួមសុខរួមប្រាណ | នឹងកេសីណា |
| ស្រេចហើយភីលៀង | នាំនាងធីតា | វិលទៅគ្រឹហា |
| | ដូចដើមប្រក្រតី។ | |
| កេសីឆ្លើយថា | អ្នកគិតនោះជា | ពេញត្រូវប្រាកដ |
| ស្រេចហើយកុដុម្ពីក៍ | គិតទីកំណត់ | វេលានឹងរត់ |
| | ប្រាប់កុលកេសី។(ទំ. ១៤) | |

ដូចដែលយើងឃើញហើយថា បញ្ហាទំុមុនស្រគាលនេះ នៅក្នុងប្រព័ន្ធគំនិតខ្មែរពុំសូវពេញចិត្តនោះទេនូវបញ្ហានេះ មិនត្រឹមតែប៉ុណ្ណោះ រហូតឈានដល់ការពង្រាត់គ្នាចាកចេញពីផ្ទះ វាកាន់តែមិនសមរម្យ។ ម្ដាយឪពុករមែងចង់ឃើញកូនសំពះក្រាបផ្ទឹម មានផ្កាស្លា មានមេបាតូចធំទទួលស្គាល់។ ផ្ទុយទៅវិញ ការធ្វើនូវទង្វើនេះទោះបីជាសង្គមទទួលយកក៏

ដោយ ក៏មានការនិន្ទាពីមនុស្សមួយចំនួនដដែល។ ទង្វើរបស់កុលកេសីដែលមិនស្ដាប់ឪពុកម្ដាយនេះ ត្រូវបានទទួលរង កម្ម ពេលគឺនាងត្រូវបានស្លាប់យ៉ាងអណោចអធ័មចោលកូនស្រី ដោយសារតែប្ដីជាទីស្រឡាញ់របស់ខ្លួនរើសដោយផ្ទាល់។

**ខ- គុណធម៌**

គុណធម៌ជាចំណុចមួយដ៏សំខាន់សម្រាប់មនុស្ស។ យោងតាមវចនានុក្រមខ្មែរ សម្ដេចព្រះសង្ឃរាជ ជួនណាត គុណធម៌ គឺជា ធម៌ដែលមានដំណើរចម្រើនសេចក្ដីសុខទុក្ខតាមជាន់តាមថ្នាក់ បានខាងអំពើល្អ អាក្រក់ គឺបុណ្យបាប ដែលបុគ្គលធ្វើ។ គុណធម៌ មកពីពាក្យ "គុណ" ជាដំណើរធ្វើឱ្យចម្រើនឡើង ដោយលក្ខណៈដែលអ្នកដទៃគួរគោរព រីឯ "ធម៌" ជាឱវាទ ក្រឹត្យក្រម ច្បាប់ វិន័យ ពាក្យទូន្មានណែនាំ។ ក្នុងន័យនេះ គុណធម៌ បានសេចក្ដីថា ការប្រព្រឹត្តអំពើល្អប្រសើរចំពោះអ្នកដទៃ ដែលជាអំពើនាំមកនូវភាពចម្រុងច្រើន កាន់តែច្រើនដែលគេផងរាល់គ្នាគោរព កោតសរសើរ ហើយក៏មានទឹកចិត្តកតញ្ញូ ចង់តបស្នងនូវអំពើល្អនោះត្រឡប់ទៅវិញ ដោយទឹកចិត្តជ្រះថ្លាពីក្នុងចិត្តក្នុងបេះដូងគេ។

នៅក្នុងរឿងមហាវេស្សន្តរជាតកក៏បានពន្លេចឱ្យឃើញពីតម្លៃគុណធម៌ជាមនុស្សជាតិមួយនៅលើភពផែនដី។ យើងឃើញហើយថា ការបំពេញទានរបស់ព្រះវេស្សន្តរ បើពិតថាវាជាកាតព្វកិច្ចមួយរបស់ព្រះអង្គក្នុងការបំពេញទានបារមីក៏មែនពិត តែការបំពេញទាននេះបានប៉ះពាល់ដល់នគរទាំងមូល អាក់អន់ស្រពន់ចិត្តនឹងទង្វើររបស់ព្រះអង្គដែលប្រគល់ដំរីបច្ច័យនាគេន្ទ្រទៅអ្នកស្រុកកលិង្គរាស្ដ្រ។ ការនេះហើយនាំឱ្យអ្នកស្រុកស្រីពិរាស្ដ្របះបោរឡើង តវ៉ាជាមួយព្រះបាទស្រីសញ្ជ័យ។ ដើម្បីបំពេញកាតព្វកិច្ចជាបុត្រល្អផង និងជាការបញ្ចៀសការមោក់ងាយមកលើព្រះអង្គដែរនោះ ព្រះវេស្សន្តរបានសុខចិត្តយាងទៅកាន់ភ្នំគិរីវង្គត។ នេះសឱ្យឃើញពីទឹកព្រះទ័យរបស់ព្រះអង្គ ក៏ទោះបីជាទ្រង់មានអំណាចយ៉ាងណា ក៏មិនប្រើគាបសង្កត់ទៅលើរាស្ដ្រទ្រង់ នាំឱ្យក្ដៅក្រហល់ក្រហាយពេញនគរដែរ។

ជាមួយគ្នានេះក្នុងរឿងសុវណ្ណសាមជាតក ក៏បានបង្ហាញពីតម្លៃគុណធម៌របស់តួអង្គដែលយើងអាចយកគ្រាប់តាមបានផងដែរ។ ជាគុណធម៌ក៏ដូចជាកាតព្វកិច្ចរបស់កូនៗត្រូវចេះបម្រើមាតាបិតាដោយមិនអាចអាក់ខានបានឡើយ។ ត្បិតលោកទាំងពីរបានលះបង់ដើម្បីយើងតាំងពីតូចក្រូចឆ្មារហូតដល់ពេញវ័យដឹងខុសត្រូវ។ សមដូចពុទ្ធដីកាដែលលើកឡើងថា "មាតាបិតាជាព្រះកន្លោង"។ ត្រង់នេះតួនាទីរបស់អក្សរសិល្ប៍ពុទ្ធនិយមបានអប់រំសីលធម៌កូនចៅប្រុសស្រីឱ្យចេះដឹងគុណមាតាបិតាផងដែរ។ ជាក់ស្ដែងនៅក្នុងរឿងសុវណ្ណសាម តួអង្គសុវណ្ណសាម ចាត់ទុកជាអតិជាតបុត្រ ក៏ព្រោះតែនៅពេលដែលទុកូលនិងបារិកាត្រូវបានចំហាយអាសិរ្វិសនោះ បញ្ចេញចំហាយពិសតាមរន្ធច្រមុះបណ្ដាលឲ្យឱ្យអ្នកទាំងពីរងងឹតភ្នែកមើលមិនឃើញ។ ពេលសុវណ្ណសាមដឹងហើយសុវណ្ណសាមយំតែក្រោយមកវិញក៏សើច ត្បិតគិតថាខ្លួនបានចិញ្ចឹមថែលោកទាំងពីរដោយផ្ទាល់។ លើសពីនេះនៅពេលសុវណ្ណសាមត្រូវសររបស់បិលយក្សពាក្យដំបូងរបស់សុវណ្ណសាមគឺ អំណឹះតទៅគ្មានរណាមើលថែម្ដាយឪពុក។ សុវណ្ណសាមមិនបានអល់អែកនឹងការឈឺចាប់របស់ខ្លួនឡើយ។ នេះហើយសឱ្យឃើញពីគុណធម៌របស់កូនចំពោះម្ដាយឪពុកដែលលោកទាំងពីរមានគុណធំធេងមិនមានអ្វីបានផ្ទឹមបាន។ នៅក្នុងជំពូកមេត្តាបារមីរបស់ព្រះសុវណ្ណសាមនេះ មិនត្រឹមតែបង្កប់នូវក្ដីមេត្តាចំពោះសត្វលោកនោះនេះ ក៏បានភ្ជាប់ទៅនឹងភាពកត្តញូរបស់បុត្រធីតា ដែលមាតាចង់បានផងដែរ។ ពិតណាស់ម្ដាយឪពុករមែង

ចង់បានបុត្រព្រោះមានបំណងប្រាំយ៉ាងគឺ ទី១ ចង់ឲ្យបុត្រចិញ្ចឹមខ្លួនវិញ។ទី២ ចង់ឱ្យបុត្រជួយធ្វើការងារ។ទី៣ ចង់ឲ្យបុត្រលើកស្ទួយវង្សត្រកូល។ទី៥ ចង់ឲ្យបុត្រទទួលមត៌ក។ និងទី៥ កាលស្លាប់ទៅចង់ឲ្យបុត្រធ្វើបុណ្យឧទ្ទិសកុសលឱ្យ [45] ។ កាលបើយើងបានបំពេញនូវកាតព្វកិច្ចទាំងនេះហើយកាលណា បុត្រធីតានឹងទទួលបានអានិសង្សជាច្រើនតួយ៉ាងដូចព្រះសម្មាសម្ពុទ្ធសរសើរព្រះសង្ឃចិញ្ចឹមមាតាបិតា ដែលជាពុទ្ធភាសិតទ្រង់សម្ដែងទុកមកក្នុងព្រហ្មសូត្រ និងសោណនន្ទជាតក ជាបទគាថាថា៖

តាយ នំ បារិចរិយាយ មាតា បិតូសុ បណ្ឌិតា

ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ។

សេចក្ដីប្រែថា (អ្នកឯណា) បានប្រតិបត្តិបម្រើនូវមាតាបិតារបស់ខ្លួនហើយ អ្នកប្រាជ្ញទាំងឡាយនោះតែងសរសើរនូវអ្នកនោះ ក្នុងលោកនេះថា អ្នកនេះជាមនុស្សមានចិត្តកត្តញ្ញូចេះប្រតិបត្តិនូវអ្នកមានគុណចំពោះខ្លួន ឯការប្រតិបត្តិយ៉ាងនេះហើយ ដែលជាផ្លូវឬជាជណ្ដើរសម្រាប់អ្នកនោះនឹងឡើង ទៅកើតក្នុងឋានសួគ៌នោះមិនខាន ដល់វេលានឹងទៅកាន់បរលោកខាងមុខទៀត ក៏អ្នកនោះឯងនឹងគង់មានប្រទះនូវលាភយ៉ាងធំគឺសេចក្ដីរីករាយសប្បាយចិត្តដោយទិព្វទ្រព្យសម្បត្តិទាំងឡាយម្ដងទៀត[46]។

ក្នុងសាស្ត្រាល្បែង ក្រុងសុភមិត្រដែលដកស្រង់ចេញពីបញ្ញាសជាតកនោះក៏បានបង្ហាញការគោរពទៅលើគុណធម៌ដឹងស ខ្មៅ ល្អ អាក្រក់ជាដើមនោះ។ ជាក់ស្ដែងនៅពេល ក្រុងសុភមិត្របានទទួលដំណឹងថា អាមាត្ររបស់ខ្លួន ជ័យសែន និងជ័យទត្តបានទៅបៀតបៀននាងកេសនីដែលជាអ្នកជាភរិយានាយភេត្រានោះ។ ក្រុងសុភមិត្រក្រោធយ៉ាងខ្លាំង ហើយបញ្ជាឱ្យពេជ្ឈឃាតយកអ្នកទាំងពីរទៅសម្លាប់ចោល។ តែត្រូវបានព្រាហ្មណ៍ បុរោហិតទូលជំទាស់មិនឱ្យយកទៅសម្លាប់ ត្បិតវាខុសនឹងប្បវេណីពីបុរាណកាល ដូចលើកឡើងថា៖

ខ្ញុំសូមឃាត់ព្រះចក្រី ត្បិតខុសវេណី អំពីបុរាណរៀងរាជ្យ។

ពុំដែលធ្វើនឹងអំណាច សម្លាប់ជាកាច ពិតពុំមានពិចារណា។(ទំ.៨០)

ដោយយល់ឃើញយោបល់របស់ព្រាហ្មណ៍បុរោហិត ត្រឹមត្រូវព្រះអង្គក៏ត្រាស់ឱ្យយកកុមារទាំងពីរមកសួរនាំ។ យើងឃើញថាដោយសារការទូលជំទាស់របស់ព្រាហ្មណ៍ បានធ្វើឱ្យការពិតអាចលេចត្រដែតឡើង។ ក្រុងសុភមិត្រក៏បានដឹងរឿងពិត ហើយបានជួបជុំមូលគ្រួសារឡើងវិញ។ ត្រង់នេះស្ដែងឱ្យឃើញថា ការដែលធ្វើអ្វីដោយមិនបានគិតពិចារណាមុន វានាំឱ្យមានវិប្បដិសារីកើតឡើងជាមិនខាន។ ការខ្វះការត្រិះរិះ ធ្វើឱ្យកម្លាំងនៃទោសៈ មោហៈ បិទបាំង សប្រែជាខ្មៅ ល្អប្រែជាអាក្រក់ជាមិនខាន។

ជាមនុស្សរស់នៅក្នុងសង្គមត្រូវប្រែកបដោយចរិយាធម៌ និងប្រកាន់នូវសីលជាប់ខ្លួនជានិច្ច។ ការគោរពចាស់ព្រឹទ្ធាចារ្យ ជាចរិយាធម៌ដ៏សមប្រកបដែលជនគ្រប់រូបត្រូវតែប្រកាន់ខ្ជាប់ឱ្យបាន ដើម្បីសេចក្ដីថ្លៃថ្នូរ ក៏ដូចជាបង្ហាញពី

[45] ភិក្ខុ គូ សុភាព, ***សីលធម៌ព្រះពុទ្ធសាសនា***, ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ២០០៨, ទំ.៣៨

[46] ញ៉ាន កឿន ស៊ិន សុវណ្ណនិ, ***លំអានទំនៀមខ្មែរបុរាណ ភាគ៤***, ភ្នំពេញ, ២០១៦, ទំ. ១០៨

តម្លៃសីលធម៌ដ៏ថ្លៃថ្នូររបស់ជាតិខ្លួន។ នៅក្នុងរឿងទេវន្ទនេះដែរ បានបង្ហាញអំពីការគោរពទៅដល់ចាស់ព្រឹទ្ធាចារ្យគឺឥសីអសង្ហៃយ្យ ដែលជាឥសីស្ទឹងស្ទាធិចម្រើនចតុពេទ្យសាស្ត្រពុទ្ធបាទនៅនាក្នុងព្រៃជ្រៅ។ ព្រះទេវន្ទ ដែលបានជិះអាជានេយ្យហោះលើអាកាស ពេលបានឃើញព្រះទេវន្ទជាឥសីចម្រើនធម៌នៅក្នុងព្រៃ ក៏បានប្រាប់សេះឱ្យចុះទាបចូលទៅដើម្បីគោរពដល់លោកតាឥសី ក្នុងបំណងជាកុសលផលបុណ្យផង និងដើម្បីសួរនាំក្រែងព្រះអង្គដឹងទីដែលមាននារីប្រកបដោយលក្ខិណា។

| | | |
|---|---|---|
| បងអើយត្បិតមាន | អាស្រមទីឋាន | ឥសីសីលា |
| ចូរបងចុះទៅ | យើងនៅនមស្សការ | ប្រតិស្ឋានជា |
| | កុសលផលបុណ្យ។ | |
| យើងទៅសួរសាន | រកស្រីកល្យា- | ណីនៅតំបន់ |
| ដ្បិតលោកមានមែន | ព្រះញាណទិព្វតន់ | ឯងអាចគួរគន់ |
| | សុះសព្វសួគ៌ព្រហ្ម។( ទំ. ២០៧) | |

តាមរយៈការបង្ហាញខាងលើ ឃើញថាព្រះទេវន្ទជាមនុស្សដែលប្រកបដោយចរិយា គឺព្រះអង្គបានបង្ហាញនូវការគោរពចំពោះចាស់ព្រឹទ្ធាចារ្យដែលប្រកបដោយសីល។ ព្រះអង្គមិនបានប្រកាន់ថាខ្លួនជាក្សត្រនោះទេ គឺព្រះអង្គនៅតែសម្តែងការគោរពចំពោះឥសីអសង្ហៃយ្យ ដែលជាអ្នកចម្រើននូវធម៌ក្នុងព្រៃ និងចម្រើននូវពុទ្ធសាស្ត្រ។ ដូចគ្នានេះដែរជនគ្រប់រូបក្នុងសង្គម ត្រូវចេះគោរពនូវចាស់ទុំព្រឹទ្ធាចារ្យ មិនថាជាចាស់ព្រឹទ្ធាចារ្យដែលជាអ្នករក្សាសីល ឬក៏មិនមានរក្សាសីលនោះទេ។ ជាកុលបុត្រកុលធីតា ត្រូវប្រកាន់នូវសីលធម៌ដ៏ល្អផូរផង់នៅក្នុងសង្គមដែលមានតពីបូរាណមក គឺការចេះគោរពចាស់ទុំនេះឯង។ វាជាទម្លាប់ដែលប្រកបដោយតម្លៃ បញ្ជាក់ពីអត្តសញ្ញាណរបស់ជាតិរបស់យើង។ ដូច្នេះយុវជនទាំងឡាយត្រូវប្រកាន់នូវសីលធម៌ដ៏ល្អនេះគឺ ការគោរពចាស់ព្រឹទ្ធាចារ្យ និងស្តាប់នូវដំបូន្មានរបស់គាត់។

រីឯនៅក្នុងរឿងភោគកុលកុមារ នៅពេលដែលភោគកុលកុមារត្រូវបានម្តាយឪពុកចែកឋានហើយនោះខ្លួនក៏បានដើរស្វែងរកសត្វឆ្កែដើម្បីមកចិញ្ចឹមជាមួយ។ ភោគកុលកុមារក៏បានប្រទះឃើញកូនឆ្កែមួយហើយក៏រត់ដេញតាមរត់ដល់ផ្ទះស្ត្រីចាស់ម្នាក់។ ភោគកុលកុមារជាក្មេងកំព្រាគ្មានទីពំនាក់ក៏បានទៅសុំទិញកូនឆ្កែនោះលោកយាយ។ ដូនចាស់បានឃើញមានចិត្តអាណិតភោគកុលកុមារ ក៏ព្រមឱ្យកូនឆ្កែនោះទៅ។ មិនត្រឹមតែប៉ុណ្ណោះ គាត់ក៏បានសុំភោគកុលកុមារធ្វើជាកូនធម៌ទៀតផង។ គាត់បានរៀបចំណីអាហារ ឱ្យភោគកុលកុមារ ហើយផ្តែផ្តាំប្រសិនបើមានទុក្ខអ្វីឱ្យមកប្រាប់គាត់ គាត់នឹងជួយ ដូចលើកឡើងថា ៖

| | | |
|---|---|---|
| ហៃកូនកល្យាណ | អ្នកនឹងចង់បាន | កូនសុនខា |
| ម្តាយសោតព្រមឱ្យ | តាមដោយចិន្តា | ម្តាយពុំប្រាថ្នា |
| | យកថ្លៃពីអ្នក។ | |
| ភ័ព្វម្តាយបានជួន | បានជួបអ្នកសួន | ថ្លើមថ្លៃវល័ក្ខណ៍ |
| ល្អល្អះឆោមឆាយ | ចិត្តម្តាយស្មោះស្ម័គ្រ | ម្តាយសូមយកអ្នក |

ជាកូនធម៌ថ្លៃ។(ទំ.១៨)

ដូនចាស់នោះបានយកភោគកុលកុមារមកធ្វើជាកូនធម៌ហើយបានជួយទំនុកបម្រុងភោគកុលកុមារ។ នៅពេលដែលភោគកុលកុមារបានឡើងសោយរាជ្យជាស្តេច ព្រះអង្គមិនបានភ្លេចនូវគុណូបការៈនេះឡើយ ព្រះអង្គបានឱ្យអាមាត្រទៅអញ្ជើញដូនចាស់មកក្នុងរាជវាំង។ ព្រះអង្គបានប្រទាននូវមាសប្រាក់ យសសក្តិទ្រព្យធន ខ្ញុំប្រុសស្រីបរស់ប្រើប្រាស់ តម្លើងឋានៈជាអ្នកគ្រប់គ្រងស្នំ ខុនណាងទាំងឡាយ។ លើសពីនេះព្រះរាជាបានឱ្យដូនចាស់ថែរក្សាឃ្លាំងព្រះរាជទ្រព្យនិងចាំគាល់បម្រើសព្វទិវាផងដែរ។ ទាំងនេះសឱ្យឃើញពីការប្រកាន់នូវគុណធម៌ក្នុងខ្លួន ជួយសង្គ្រោះអ្នកដទៃដោយសណ្តានចិត្ត នោះអំពើល្អទាំងនោះនឹងហុចផលមកវិញជាមិនខាន។

គុណធម៌ ជាធម៌មួយដែលបង្ហាញពីតម្លៃរបស់មនុស្សនៅក្នុងសង្គម។ គុណធម៌ធ្វើឱ្យមនុស្សស្គាល់នូវគុណស្គាល់នូវទោស ដឹងអ្វីត្រូវដឹងអ្វីខុស។ គុណធម៌ពិតជាសំខាន់ណាស់សម្រាប់មនុស្សនៅក្នុងសង្គម ហេតុនេះហើយទើបបានជាអ្នកនិពន្ធបានរំលេចនូវតម្លៃនៃគុណធម៌នៅក្នុងរឿងមរណមាតានេះ។ គុណធម៌ដែលស្តែងឡើងតាមរយៈរឿងមរណមាតាគឺបញ្ញាកតញ្ញូ។ ជាក់ស្តែង យើងឃើញតាមរយៈសកម្មភាពរបស់មរណមាតាក្នុងការដឹងគុណម្តាយរបស់នាងគឺនាងកុលកេសី។ ទោះជាមានការឈ្នានីសពីកាឡី មរណមាតានៅតែនឹកគិត នៅតែដឹងគុណម្តាយជានិច្ចហើយតែងបានបំពេញនូវកាតព្វកិច្ចជាកូនស្រីជានិច្ច។ តាំងពីម្តាយនៅជាមនុស្ស រហូតក្លាយជាត្រីដំរី ក៏នាងនៅតែស្រលាញ់ដឹងគុណ បម្រើមាតាគ្រប់ពេល។ ទោះបីជានាងកាឡីធ្វើបាប ប្រើឱ្យធ្វើការដោយគ្មានត្រាប្រណីយ៉ាងណា ក៏មរណមាតានៅតែឆ្លៀតយកចំណីទៅឱ្យត្រីដំរីដែលជាម្តាយរបស់នាងរាល់ថ្ងៃ។ រហូតដល់រូបកាយម្តាយនាងបានដុះជាដើមរលួសមាសដ៏ល្អ ក៏នាងនៅតែយកផ្កាយកគ្រឿងបូជាទៅថ្វាយម្តាយដែលរក្សានៅដើមរលួសមាសនោះជានិច្ច។ នេះបង្ហាញពីគុណធម៌របស់មរណមាតាចំពោះអ្នកមានគុណរបស់នាង។ យ៉ាងណាវិញ ទោះបីជាឪពុករបស់នាងស្រលាញ់យកចិត្តកាឡី និងកូនរបស់នាងមរណមាតានៅតែគោរពប្រណិប័តន៍ បម្រើឪពុកជានិច្ច។ សូម្បីតែខ្លួនក្លាយជាមហេសីព្រះរាជាហើយក៏នៅតែបំពេញនូវគុណធម៌ជាកូនចំពោះឪពុកថែមទៀត នៅពេលដែលកាឡីកុហកថាឪពុកឈឺ មរណមាតាក៏ប្រញាប់រៀបចំទៅមើលសួរសុខទុក្ខឪពុក ដោយមិនគិតពីកលល្បិចឪពុក និងនាងកាឡីចង់សម្លាប់ខ្លួនឡើយ។ ដូចមានបង្ហាញនៅក្នុងរឿង៖

| | | |
|---|---|---|
| ចំណីកាឡីនោះណា | នាងពុំភោក្តា | នាងចាំបណ្តាំជននី។ |
| ចំណីរបស់នាងស៊ី | បើគ្មានទេវី | នាងអត់នាងអន់ស្បៀមស្ងាត់។ |
| តែងយកកន្ទក់ទៅថ្វាត់ | ទៅជូនប្រណិប័តន៍ | ជននីរាល់ៗវេលា។ |
| ធ្វើវត្តប្រណិប័តន៍បិតា | ប្របាច់បាទា | មិនខានមិនឲ្យអាក់ចិត្ត។(ទំ. ៤៦) |

នេះបង្ហាញពីការដឹងគុណរបស់មរណមាតាចំពោះអ្នកមានគុណ ដោយបានធ្វើការគោរពបូជាចំពោះម្តាយដែលជាអ្នកមានគុណ និងជាព្រះរបស់នាងផងដែរ។ ដោយការប្រតិបត្តិនូវគុណធម៌ចំពោះអ្នកមានគុណនេះហើយ ទើបធ្វើឱ្យនាងបានជួបនឹងព្រះរាជា ហើយបានត្រឡប់ក្លាយទៅជាព្រះអគ្គមហេសីរបស់ព្រះរាជវិមលធម្មរាជ សោយសុខក្នុងព្រះរាជវាំងតទៅ។

## ៤.២- ការបណ្តុះស្មារតីសន្តិភាព

សន្តិភាពគឺជាប្រការដែលមនុស្សគ្រប់គ្នារមែងចង់បាន។ ទាំងសន្តិភាពផ្លូវកាយ និងផ្លូវចិត្ត។ ត្បិតបើមនុស្សមានសន្តិភាពហើយនោះ គេក៏អាចធ្វើអ្វីបានល្អទៀតផង។ ដូចពុទ្ធភាសិតមួយលើកឡើងថា "*នត្ថិ សន្តិ បរំ សុខំ*" មានន័យថា ពុំមានសេចក្តីសុខឯណាស្មើនឹងសេចក្តីស្ងប់មិនមានឡើយ"។ ដែលនេះបង្ហាញឱ្យឃើញពីការដែលមិនទៅបៀតបៀនដោយ កាយ វាចា ចិត្តនោះ នឹងនាំមនុស្សឱ្យមានសន្តិភាពក្នុងខ្លួន។

នៅក្នុងរឿងមហាវេស្សន្តរ បានបណ្តុះនូវគំនិតស្មារតីសន្តិភាពឱ្យបុគ្គលផ្ទាល់តែម្តង។ នៅពេលដែលព្រះវេស្សន្តរត្រូវបានអ្នកស្រីពិរាស្ត្រ តិះដៀល រហូតសុំឱ្យព្រះអង្គយាងចេញពីនគរទៀតនោះ ព្រះវេស្សន្តរមិនបានទៅតបតប្រទូស្តរាយនឹងអ្នកស្រីស្រុកពិរាស្ត្រនោះទេ។ ព្រះអង្គសុខចិត្តជ្រើសរើសយកភាពស្ងប់ ចាកចេញពីព្រះនគរទៅតាមការចង់បានរបស់អ្នកស្រីពិរាស្ត្រ។ មួយវិញទៀត នៅពេលដែលទ្រង់បរិច្ចាគបុត្រទាំងពីរឱ្យទៅជូជក នាងមទ្រីបានវិញមកវិញដោយពុំឃើញបុត្រក៏បានទួញសោក ហើយថាឱ្យព្រះវេស្សន្តរ។ ទោះជាយ៉ាងណាក៏ព្រះអង្គមិនតបត ទ្រង់ដឹងថានាងនឹងយល់ពីការបំពេញទានរបស់ព្រះអង្គ។ នេះហើយសឱ្យឃើញពីការអត់ឱន អត់ធ្មត់យើងអាចបញ្ចៀសនូវជម្លោះបានទាំងអស់។ ក្រោយលក្ខណៈនៃពុទ្ធនិយមនេះ វាបានជាគំនិតដល់មនុស្សគ្រប់រូបឱ្យរក្សាភាពស្ងប់ កុំតបទៅនឹងអ្នកដទៃ និងមនុស្សក្នុងគ្រួសារក៏ដោយ ត្បិតពេលដែលមានកំហឹងមនុស្សនឹងបាត់បង់លំនឹង ការត្រិះរិះហើយនាំឱ្យមានជម្លោះ ការបែកបាក់កើតឡើង។

រីឯក្នុងរឿងសុវណ្ណសាមវិញ ក៏បានបណ្តុះស្មារតីសន្តិភាពទាំងកាយវាចាចិត្តទាំងព្រមតាមរយៈតួអង្គសុវណ្ណសាម។ តាមរយៈដំណើររឿងសុវណ្ណសាម នៅពេលព្រះបាទបិលយក្សបាញ់ព្រួញចំសុវណ្ណសាមដួសស្តូកស្តឹងនៅក្បែរស្ទឹងមិគសម្មតា។ សុវណ្ណសាមមិនបានតបតអ្វីទៅកាន់បីឡយក្សនោះទេ តែទ្រង់វាចារដោយសេចក្តីផ្អែមល្ហែម៖ « លោកណាអើយ!បាញ់ខ្ញុំកំពង់ដងទឹក? ...»។ទាំងកាយក៏មិនតបត ទាំងវាចាផ្អែមល្ហែម និងទឹកចិត្តត្រជាក់ មិនមានហិង្សាទៅនឹងព្រះបាទបិលយក្ស។ អានិសង្សនៃការមិនតបត អត់ធ្មត់នេះហើយ ធ្វើឱ្យមាតាបិតា និងនាងទេវតាពហុសុន្ទរីដែលអាស្រ័យនៅឯភ្នំគន្ធមាទន៍ ចេញមកធ្វើសច្ចាធិដ្ឋានក៏ ធ្វើឱ្យសុវណ្ណសាមរស់ឡើងវិញផងដែរ។

ជាមួយគ្នានេះ រឿងក្រុងសុភមិត្រក៏បង្ហាញពីចំណុចនៃអហិង្សាដែលឈានទៅដល់ការនាំមកនូវសន្តិភាពផងដែរ។តាមរយៈដំណើររឿង ក្រុងអសុភមិត្រជាព្រះអនុជចង់ដណ្តើមរាជ្យពីបងក្រុងសុភមិត្រ។ ព្រះបាទក្រុងសុភមិត្រក៏បានសម្រេចចិត្តចាកចេញដោយឱ្យអនុជសោយរាជ្យបន្ត។ ការសម្រេចចិត្តនេះក៏កើតចេញពីការត្រិះរិះឈ្វេងយល់អំពីទុក្ខរបស់ប្រជារាស្ត្រ បើសិនជាទ្រង់មិនចាកចេញនោះទេ សង្គ្រាមបង្ហូរឈាមរវាងបងប្អូននឹងកើតឡើង មិនត្រឹមតែប៉ុណ្ណោះវាបង្កវិនាសកម្មដល់អាណានុរាស្ត្រផងដែរ។ ការឈ្វេងយល់នេះ ទើបទ្រង់យាងចាកចេញជាមួយមហេសីនិងបុត្រទាំងពីរនិរទេសទៅក្នុងព្រៃ។ ដូចយ៉ាងបានលើកឡើងថា៖

បើយើងតតាំង កងទ័ពចេញច្បាំង ឲ្យយល់ឫទ្ធិ
ក្រែងកើតកង្វល់ អម្ពលសេចក្តី អាសូរប្រណី
រាស្ត្រផងទាំងឡាយ។

នឹងកើតផ្សារក្តៅ ព្រាត់ប្រាស់កូនចៅ ហិនហោចខ្ចាត់ខ្ចាយ
ស្លុតស្លាប់សូន្យសោះ ហេតុនេះអញណាយ មិនឲ្យអន្តរាយ
ជនជាតិឡើយហោង។(ទំ.១៣)

នេះសបញ្ជាក់ឱ្យឃើញពីពលិកម្មដ៏ធំធេងរបស់ក្រុងសុភមិត្រដែលបាន លះបង់រាជ្យសម្បត្តិឱ្យទៅអនុជរបស់ខ្លួន ហើយខ្លួនសុខចិត្តនិរទេស លំបាក ព្រាត់ប្រាស់ប្រពន្ធកូនទៀតនោះ។ វាជាតម្លៃសន្តិភាពមួយដ៏ល្អត្បិតវាធ្វើឱ្យប្រទេសជាតិគ្មានសង្គ្រាមនិងប្រជាជនរស់នៅសុខសាន្ត។ ត្រង់នេះបើយើងពិចារណាបន្តិចទៀត យើងនឹងឃើញថារឿងនេះក៏មានកើតក្នុងសង្គមខ្មែរយើងត្រឹមតែ២៣ឆ្នាំមុនការតាក់តែងរឿងក្រុងសុភមិត្រនាគ.ស.១៧៩៨ ពោលក្នុងរាជ្យរបស់ ព្រះអង្គតន់ បានថ្វាយរាជ្យឱ្យព្រះអង្គនន់ក្នុងសម័យឧដុង្គ។

ការធ្វើឱ្យមានសន្តិភាពក៏ផ្តើមចេញពីបុគ្គលនោះប្រកាន់ខ្ជាប់ នូវសុចរិតធម៌ និងវៀរចាកនូវទុច្ចរិតធម៌ផងដែរ។ម្យ៉ាងទៀតការប្រកាន់ខ្ជាប់នៃសុចរិតធម៌និងវៀរសចាកទុច្ចរិតធម៌នេះ ជាស្ពានមួយឈានទៅរកសន្តិភាពសម្រាប់ខ្លួនឯងផងដែរ។ តួយ៉ាងនៅក្នុងរឿងទេវន្ទបានបង្ហាញពីទុច្ចរិតបីប្រការ ដែលនាំសត្វលោកឱ្យធ្លាក់ទៅក្នុងអវចី ប្រាសចាកពីសេចក្តីសុខ។ ទុច្ចរិតបីប្រការនោះមានដូចជា កាយទុច្ចរិត វាចាទុច្ចរិត និងមនោទុច្ចរិត។ តាមរយៈការសម្តែងធម្មទេសនារបស់ព្រះទេវន្ទ បានទេសនាទូន្មានកុម្ភណ្ឌទាក់ទងទៅនឹងទុច្ចរិតបីប្រការ ដែលនាំឱ្យសត្វទាំងឡាយធ្លាក់អវចី។ តាមការទេសនារបស់ព្រះទេវន្ទ ទុច្ចរិតមានបី កាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត។ ហើយក្នុងទុច្ចរិតបីប្រកានេះបានចែកជាដប់ប្រការថែមទៀត។ កាយទុច្ចរិតចែកចេញជាបី មួយគឺបាណា មួយគឺអទិន្នា មួយគឺកាមេ។ ឯវចីទុច្ចរិតចែកចេញជាបួន មួយគឺការនិយាយពាក្យមិនពិត មួយគឺការពោលពាក្យញុះញង់ឱ្យគេបែកបាក់គ្នា មួយគឺការពោលពាក្យទ្រគោះមិនពីរោះ មួយគឺការពោលពាក្យផ្ដាញ់ផ្ដាលបំផុតលើគេ។ ចំណែកឯមនោទុច្ចរិតមានបី មួយគឺចិត្តសង្ខាតតាមព្យាបាទគេ មួយគឺចិត្តលោភ មួយគឺចិត្តមិច្ឆា។

ពោធិសត្វឆ្លើយ ថាហៃយក្ខអើយ រីឯលោកហៅ
ថាទុច្ចរិត បីពិតអញនៅ សំដែងចែងទៅ
ឲ្យផ្សេងពីគ្នា។(ទំ. ១៣៧)

យើងឃើញហើយថា កាលបើមនុស្សវៀរចាកនូវអំពើទុច្ចរិតទាំងនេះនាំឱ្យខ្លួនគេពុំមានការបៀតបៀនពីអ្នកដទៃរស់នៅមជ្ឈដ្ឋានមួយដែលមានការគោរពកោតស្ញប់ស្ញែងជាដើម។ ទន្ទឹមនឹងនេះ ការដែលប្រព្រឹត្តនូវទុច្ចរិតខាងលើ នឹងនាំឱ្យមនុស្សនោះទទួលបាននូវកម្មផ្សេងៗ។ ដោយសារតែកុម្ភណ្ឌទាំងបួនបានប្រព្រឹត្តិនូវទុច្ចរិតទាំងបីប្រការនេះហើយ ទើបធ្វើឱ្យយក្សទាំងបួននេះក្នុងបច្ចុប្បន្នជាតិមានរូបរាងអាក្រក់ មិនមាននរណាស្រលាញ់ចូលចិត្តបែបនេះ។ ក្នុងការសម្តែងនូវធម៌របស់ព្រះទេវន្ទ បានរ៉ាយរ៉ាប់ពីផលដែលដែលទទួលបានពីការប្រព្រឹត្តិនូវអំពើទុច្ចរិតទាំងបីនេះ ពេលស្លាប់ទៅនឹងទៅកើតនៅនាឋាននរកលំបាកវេទនា បើកើតជាមនុស្សក្នុងលោកនឹងមានរូបរាងអាក្រក់អប្រិយពន់ពេក។ អ្នកខ្លះកើតមកហើយនឹងត្រូវគេប្រល័យឱ្យក្ស័យទៅវិញ ឬដោយជំងឺព្យាធិជាដើម។ ចំពោះអ្នកធ្វើបាណាតិបាតា កម្មដែលទទួលបាននោះគឺ នឹងត្រូវគេសម្លាប់ដោយគ្រឿងសស្ត្រាផ្សេងៗ ឬដោយរោគាជាដើម។ បើមានកូនចៅ ក៏នឹងត្រូវ

ប្រាសព្រាត់ បើរបស់ជាទីស្រលាញ់ក៏ប្រែជាប្រាសបាត់ទៅវិញ។ បើអ្នកឯណាប្រព្រឹត្តិនូវអទិន្នា ដល់ស្លាប់ទៅនោះនឹងទៅវេទនាទុក្ខវេទនា វេលាណាដែលកើតជាមនុស្ស ក៏នឹងកើតជាអ្នកខ្សត់ទ្រព្យ ហិនហោចទុគ៌ត គ្មានញាតិសណ្ដានស្រលាញ់រាប់រក។ ទោះនឹងមានមាសប្រាក់ទ្រព្យសម្បត្តិ ក៏នឹងប្រែជាប្រាស់វិនាសទៅវិញដោយប្រការផ្សេងៗ ដោយចោរមកលួចយកទៅដោយអ្នកមានអំណាចយកទៅ ឬដោយគ្រោះផ្សេងៗទៀត។ មួយអ្នកប្រព្រឹត្តិនូវកាមេ ដល់កាលណាស្លាប់ទៅនឹងទៅធ្លាក់ក្នុងនរកវេទុក្ខលង់លុះមកកើតក្នុងលោកិយ។ ដល់កាលមកកើតក្នុងលោកកាលណា នឹងត្រូវកើតមកជាខ្ទើយស្ទើរប្រុសស្ទើរស្រី។ បើនឹងតាំងប្រាថ្នាអ្វីក៏សឹងពុំបានដូចបំណង។

ខុសពីទុច្ចរិតទាំងបីប្រការដែលនាំឱ្យសត្វលោកឈានទៅរកអវចី ក៏មានសុចរិតបីប្រការដែលនាំសត្វលោកឱ្យដល់នូវសេចក្ដីស្ងប់សុខផងដែរគឺ កាយសុចរិត វចីសុចរិត និងមនោសុចរិត។ ហើយសុចរិតនេះឯងជាដើមហេតុនាំឱ្យមនុស្សមានសេចក្ដីសុខ ហើយប្រកបដោយសេចក្ដីស្ងប់។ នៅក្នុងរឿងទេវន្នទេះដែរ ក៏បានបង្ហាញនូវសុចរិតបីប្រការផងដែរ ដែលក្នុងសុចរិតបីប្រការនេះបានបែកចែកជាផ្នែកផ្សេងៗទៀត។ តួយ៉ាង តាមរយៈការសម្ដែងនូវធម៌ទេសនារបស់ព្រះទេវន្នអំពីសុចរិតបីប្រការ ដើម្បីទូន្មានដល់កុម្ភណ្ឌ។ ព្រះទេវន្នបានទេសនារៀបរាប់អំពីសុចរិតបីប្រការ ហើយសុចរិតបីប្រការនោះមាន កាយសុចរិត វចីសុចរិត និងមនោសុចរិត។ ដោយកុម្ភណ្ឌទាំងបួនបានវន្ទាសូមឱ្យព្រះទេវន្នបន្ថែមបង្ហាញពីសុចរិតបីប្រការនោះឱ្យខ្លួនបានដឹង។ ពេលនោះព្រះទេវន្នបានសម្ដែងនូវធម្មទេសនាប្រាប់ទៅកុម្ភណ្ឌទាំងបួន ក្នុងសុចរិតបីប្រការនោះដែលចែកចេញជាដប់ប្រការ។ ក្នុងនោះមានកាយសុចរិតបី មនោសសុចរិតបួន និងវចីសុចរិតបី។ ដែលទាំងនេះហើយជាសុចរិតទាំងបីប្រការដែលជាធម៌មង្គលដល់ជនគ្រប់គ្នា។

| | | |
|---|---|---|
| យេចឥតំ | សុចរិតំ | យក្ខអើយនរណា |
| ប្រាស់ប្រែប្រព្រឹត្តិ | នូវសុចរិតា | ទាំងដប់ប្រការ |

ហៅព្រះធម្មេ។( ទំ. ១៤៨)

តាមរយៈអត្ថបទចំណុចមួយៗនៃសុចរិតបានលើកយកមកបង្ហាញ យើងឃើញថាអំពើឬសុចរិតទាំងបីប្រការនោះ មានបែងចែកថែមជាដប់ប្រការថែមទៀតគឺ កាយសុចរិតមានការវៀរចាកនូវការសម្លាប់ជីវិតសត្វ និងមនុស្សដទៃ ការមិនលួចទ្រព្យសម្បត្តិអ្នកដទៃ និងការមិនលួចប្រពន្ធ ប្ដីអ្នកដទៃ។ រីឯមនោសុចរិតមាន ការវៀរចាកនូវភាពលោភលន់ ការវៀរចាកនូវចិត្តព្យាបាទ និងការវៀរចាកនូវចិត្តមិច្ឆាទិដ្ឋិ។ ចំណែកវចីសុចរិតវិញ គឺការមិននិយាយពាក្យកុហក ការមិននិយាយពាក្យអសុរោះ ការមិននិយាយពាក្យទ្រគោះបោះបោក ការមិននិយាយពាក្យអាក្រក់ និងការមិននិយាយពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ។

ក្នុងការប្រព្រឹត្តនូវសុចរិតបីប្រការនេះដែរ ឃើញថាក៏នឹងទទួលបានផលមកវិញជាកុសល។ នៅក្នុងសាស្ត្រាទេវន្នទេះផងដែរ ក៏បានបង្ហាញឱ្យឃើញពីផលដែលទទួលបានពីការប្រព្រឹត្តិនូវអំពើសុចរិតទាំងបីប្រការនេះផងដែរ។ ហើយផលដែលទទួលបាននេះ ជាផលដែលប្រកបដោយធម៌គឺ ផលជាកុសលដែលនាំមកនូវតែសេចក្ដីចម្រើន ដល់ជនដែលបានប្រព្រឹត្តិនូវសុចរិតទាំងបីប្រការនេះ។ តួយ៉ាង ព្រះទេវន្នបានទេសនាប្រាប់ពីផលដែលទទួលបានពីការប្រព្រឹត្តិនូវសុចរិតទាំងបីប្រការទៅដល់ពួកយក្សទាំងបួន។ អ្នកដែលប្រព្រឹត្តិនូវសុចរិតទាំងបីនេះ ទោះនឹងស្លាប់បង់ទៅ ក៏សោត

តែបានសោយសុខសាន្ត បើកាលកើតជាមនុស្សក៏កើតក្នុងត្រកូលអ្នកល្អប្រពៃ មានទ្រព្យធន ពុំដែលជួបប្រទះនូវទុក្ខទោមនស្ស មិនដែលស្គាល់ពាក្យថាប្រាស់ព្រាត់ វិនាសញាតិបងប្អូន ម្ដាយឪពុក និងប្រកបដោយយសសក្ដិ។ អ្នកនោះឯងក៏នឹងមានរូបសម្រស់ល្អល្អះ កម្រនឹងមានមនុស្សឯណាមកផ្ទឹមប្រៀបបាន។ ក្នុងការរស់នៅវិញតែងមានគេស្រលាញ់រាប់អានចូលចិត្តទាំងមនុស្ស ទាំងទេវតា មានគេជួយយកអាសារគ្រប់ពេលវេលា។

ជារួមយើងឃើញថា ការប្រព្រឹត្តនូវសុចរិតនិងវៀរចាកទុច្ចរិតទាំងអស់នេះនាំឱ្យមនុស្សមាននូវសេចក្ដីសុខក្នុងខ្លួន ពុំមាននូវមន្ទិល ឬសេចក្ដីខ្លាចក្រោធទាំងឡាយនោះឡើយ។ ម៉្យាងក៏ទោះបីជាទស្សនៈនេះស្ថិតក្នុងពុទ្ធសាសនាក៏ដោយ ក៏វាបានបង្ហាញពីលក្ខណៈបែបវិទ្យាសាស្ត្រមួយដែលអាចឱ្យមនុស្សរស់នៅប្រកបដោយភារតភាព មានសន្តិភាពទាំងផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត។

ចំណែកឯរឿងភោគកុលកុមារ ក៏បានលើកយកនូវការចេះអធ្យាស្រ័យគ្នាក្នុងសង្គមមកបង្ហាញតាមរយៈខ្សែរឿងផងដែរ។ នៅពេលដែលព្រះបាទភោគកុលកុមារបានចេញប្រយុទ្ធជាមួយនឹងព្រះបាទព្រហ្មទត្តដែលមានលោភលន់កាមតណ្ហា ចង់បានប្រពន្ធគេនោះ ហើយបានសម្លាប់ព្រះអង្គនៅពេលប្រយុទ្ធគ្នា។ ផ្ទុយទៅវិញនៅពេលព្រះបាទព្រហ្មទត្តចាញ់ហើយនោះ អ្នកទាំងឡាយដែលជាពលរេហ៍ មិនបានផ្សំគំនិតជាមួយនោះ ក៏បានសុំចុះចូល រាជទានទោសប្រោសប្រណី ដូចលើកឡើងថា៖

| | | |
|---|---|---|
| ទើបព្រះពូជពង្សពុទ្ធផៅ | បើកបន្ទូលទៅ | ថាហៃអស់មុខមន្ត្រី។ |
| គ្រប់គ្នាតើមានទោសអ្វី | កុំភ័យទៅថ្វី | អញសោតពុំយកទោសា។ |
| មន្ត្រីត្រេកអរគ្រប់គ្នា | ដ្បិតស្ដេចមេត្តា | ប្រោសទុកជីវិតឱ្យគង់។(ទំ. ១៤៨) |

ត្រង់នេះដែលបានបង្ហាញនូវសន្តិភាពនៅក្នុងសង្គមមួយតាមរយៈការចេះប្រោសប្រណីគ្នា ក្នុងនាមជាមនុស្សជាតិ។ អំពើរបស់ភោគកុលកុមារនេះ មិនត្រឹមតែជាគុណធម៌មួយនោះទេ តែវាបង្រៀនមនុស្សឱ្យចេះមានការយោគយល់ចំពោះគ្នាក្នុងនាមជាជាតិសាសន៍តែមួយ មិនត្រូវចេះប្រកាន់អូសដំណើរ បែងចែកបក្សពួកដែលនាំឱ្យដល់ការរើសអើងទៀតផង។

ការប្រកាន់ខ្ជាប់នូវការព្យាយាម អំណត់អត់ធ្មត់ រក្សានូវអហិង្សា ជាការបណ្ដុះស្មារតីមួយក្នុងការរក្សានូវសន្តិភាព។ នៅក្នុងសាស្ត្រារឿងមរណមាតានេះ បានបណ្ដុះនូវស្មារតីសន្តិភាព តាមរយៈនាងមរណមាតា តែងតែតស៊ូអត់ធ្មត់ក្នុងជីវិតរស់នៅ គ្រប់បញ្ហាក្នុងជីវិត នាងតែងតែបានតស៊ូដោយប្រើការតស៊ូព្យាយាម ហើយពិសេសជាងនេះទៅទៀតនាងប្រកាន់ខ្ជាប់នូវភាពអហិង្សាជានិច្ច។ ទោះជាត្រូវរងការធ្វើបាប ប្រមាថមើលងាយពីអ្នកដែលតាមចងពៀរឈ្នានីសនាងក៏ដោយ មរណមាតានៅតែមិនតបត ហើយព្យាយាមគេចចេញពីការចងពៀរគ្នាទៅវិញទៅមកជានិច្ច។ តួយ៉ាង កាលមរណមាតាក្លាយជាសារិកានៅពេលដែលឆន្ទាឱ្យកីលៀងយកខ្លួនទៅបោចរោម ប៉ងនឹងសម្លាប់ ចៃដន្យបានរួចខ្លួនទៅស្នាក់ជាមួយកណ្ដុរស ហើយស្ដេចកណ្ដុរសចង់ទៅសម្លាប់នាងឆន្ទាសងសឹកឱ្យនាង មរណមាតាបានឃាត់ស្ដេចកណ្ដុរសមិនឱ្យទៅចងពៀរជាមួយនឹងនាងឆន្ទាឡើយ ដូចបានរៀបរាប់ថា៖

| | |
|---|---|
| រីឯមេឆន្ទា | ចិត្តឫស្យាចោរអន្តរាយ |

ធ្វើទោសប្អូនឆោមឆាយ បងជានាសម្លាប់វា។
នាងស្តាប់ឆ្លើយសាសង កុំអ្នកបងចងវេរា
ក្រែងមានពៀរនឹងគ្នា តទៅមុខទៀតមិនខាន។ ...
នឹងយុត្តនឹងតតាំង ប៉ះកម្លាំងគេដូចម្តេច
ខ្លួនយើងកម្លាំងតិច សូមអ្នកបងស្ញៀមទៅជា។(ទំ. ១៧៤)

នេះបង្ហាញឱ្យឃើញពីការប្រកាន់នូវអហិង្សារបស់មរណមាតា ដែលបានហាមឃាត់មិនឱ្យកើតមានឡើងនូវជម្លោះ ការឈ្លោះប្រកាប់ប្រចាក់គ្នា ពោលគឺខន្តីឱ្យគ្នា កុំចងពៀរបន្តទៀត។ ដោយហេតុនេះហើយ ទើបនាងអាចរស់នៅជាមួយកណ្តុរបានសុខសាន្តរហូតដល់ពេមដុះជិតពេញខ្លួនវិញ។

### ៤.៣- ការបណ្តុះពុទ្ធិស្មារតី

អក្សរសិល្ប៍ពុទ្ធនិយម ក្រៅតែពីដើរតួនាទីក្នុងការអប់រំចរិយាសាស្ត្រ សេចក្តីថ្លៃថ្នូររបស់មនុស្ស បណ្តុះនូវសន្តិភាពរវាងគ្នានិងគ្នា វាក៏បានជួយដល់ការបណ្តុះគំនិតដល់អ្នកអាន អ្នកស្តាប់ឱ្យមានពុទ្ធិ ចំណេះដឹងតាមរយៈសកម្មភាពតួអង្គ ដំណើររឿងជាដើម។ ជាមួយគ្នានេះ អក្សរសិល្ប៍ពុទ្ធនិយមក៏បាន រំលេចក្នុងការបណ្តុះបញ្ញាមនុស្ស វាប្រៀបបានទៅនឹងមាគ៌ាមួយសម្រាប់មនុស្សឱ្យចេះត្រិះរិះគិតដោះស្រាយបញ្ហាចំពោះមុខសំដៅជានាបាននូវការអភិវឌ្ឍខ្លួន គ្រួសារ និងសង្គមជាតិទាំងមូល។

នៅក្នុងរឿងព្រះវេស្សន្តរក៏បានបណ្តុះនូវពុទ្ធិដល់មនុស្សយ៉ាងច្រើនសម្បូរបែប។ តួយ៉ាងនៅក្នុងការអប់រំគឺជាទិសដៅសំខាន់ក្នុងការអភិវឌ្ឍខ្លួន។ ជាក់ស្តែងព្រះវេស្សន្តក្នុងព្រះជន្ម១៦ឆ្នាំនៅពេលដែលទ្រង់បានរៀនចប់នូវសិល្ប៍សាស្ត្រគ្រប់ជំពូកហើយ ទើបព្រះរាជបិតាបាននាំព្រះរាជកញ្ញាព្រះមាននាងមទ្រី ជាព្រះមាតុជីតា អំពីមទ្ទរដ្ឋ មករៀបអភិសេក ហើយទ្រង់ដាក់រាជ្យថ្វាយព្រះវេស្សន្តរ។ ត្រង់នេះស្តែងឱ្យឃើញពីការយកចិត្តទុកដាល់លើការសិក្សាទោះបីជាក្សត្រក៏ត្រូវខំរៀនសូត្រផងដែរ។ លើសពីនេះតាមរយៈដំណើររឿងក៏បានបង្ហាញពីវិធីដោះស្រាយបញ្ហារបស់ជូជក។ ពិតណាស់ការកុហកវានឹងនាំឱ្យអន្តរាយជាមិនខាន។ តែពេលខ្លះការមុសានោះក៏អាចធ្វើឱ្យយើងរួចជីវិតដែរ។ ដូចយ៉ាងជូជកបានកុហកចេតបុត្រនិង អច្ចុតមហាឫសីថាជា ព្រាហ្មណ៍ទូតរបស់ព្រះបាទស្រីសញ្ជ័យ។ នេះហើយនាំឱ្យជូជកបានរួចរស់ជីវិត។ វាសមដូចបុរាណភាសិតខ្មែរលើកឡើងថា៖ «ផ្លូវវៀចកុំបោះបង់ ផ្លូវត្រង់កុំដើរហោង»។

រីឯនៅក្នុងរឿងសុវណ្ណសាមវិញក៏មិនខុសពីជាតកដទៃដែរក៏បានបង្ហាញពីពុទ្ធិសម្រាប់អ្នកសិក្សាទូទៅ។ ក្នុងជីវិតមនុស្សតែងតែមានការបង្កើតកំហុសឆ្គងដោយចេតនាក្តី អចេតនាក្តី។ ពេលដែលយើងទទួលជួបនូវកំហុស បញ្ហានេះហើយ យើងគប្បីភ្ញាក់រឭក កែប្រែវាឱ្យប្រសើរឡើងវិញ។ ការដាស់តឿនរបស់ទេពធីតាវសុន្ធរីទៅឱ្យបិលយក្សថា៖ បពិត្រមហារាជ ព្រះអង្គបានធ្វើហើយនូវបាបជាទម្ងន់...ខ្ញុំនឹងពន្យល់ឱ្យរួចពីនរក បានទៅសុគតិភព ...។ ត្រង់នេះហើយទោះបីជាបិលយក្សជាអង្គក្សត្រក៏ទ្រង់ទទួលយកពាក្យរបស់ទេពធីតា មកកែប្រែនូវកំហុសរបស់ខ្លួនផងដែរ។

ចំណែករឿងក្រុងសុភមិត្រវិញក៏បានបណ្តុះនូវគតិដល់មេដឹកនាំ ក៏ដូចជាជនានុជនក្នុងការសម្រេចចិត្តកាត់សេចក្តី វិនិច្ឆ័យអ្វីមួយឱ្យប្រកបដោយគតិយុត្តិ ពោលគឺកុំធ្វើអ្វីដោយអគិតទាំងបួនគឺ ឆន្ទាគតិ ទោសាគតិ មោហាគតិ

និង ភយាគតិ។ តួយ៉ាងនៅពេលដែលនាយភេត្រាបានឃើញ ជ័យទត្តនិងជ័យសែនកំពុងឱបរឹតជាមួយមាតាគឺព្រះនាង កេសនី។ នៅពេលដែលបានឃើញដូច្នេះ ភេត្រាពុំបានគិត ឬសួរនាំនោះទេក៏វិនិច្ឆ័យថាជាសហាយស្មន់នឹងគ្នា ក៏ទៅទូលព្រះរាជា។ ដូចលើកឡើងថា៖

វានេះស្មេរស្មា ចិត្តកាចពាលា ពុំគិតកេរ្តិ៍កាយ

វាតូចប៉ុណ្ណោះ ចេះមានសហាយ ហ៊ានម្ដេចអម្បាយ

ចោរចង់តណ្ហា។(ទំ. ៧៨)

ដោយការវិនិច្ឆ័យមិនត្រឹមត្រូវនេះហើយ អាចនាំឱ្យជ័យទត្តនិងជ័យសែនឈានទៅដល់ការស្លាប់។ ប៉ុន្តែដោយសារ តែគុណបុណ្យរបស់ព្រាហ្មណ៍ បុរោហិតអ្នកចេះដឹង លោកបានឃាត់ឃាំងដំណើរ ត្បិតខុសនឹងប្បវេណី។ នេះហើយទើបធ្វើឱ្យការពិតបានលាតត្រដាង។ ជារួមការវិនិច្ឆ័យអ្វីមួយត្រឹមតែការបានឃើញនោះ វាពិតជាហានិភ័យដល់ការសម្រេចចិត្តជាមិនខាន។

ជាការពិតណាស់ ការសេពគប់ក៏ជាហេតុមួយក្នុងការធ្វើឱ្យខ្លួនរីកចម្រើនបានដែរ។ ការសេពគប់នូវជនជាបណ្ឌិត រមែងធ្វើឱ្យជននោះទទួលបាននូវការរីកចម្រើនផ្នែកគំនិតបញ្ញាក៏ដូចជាសមត្ថភាពការងារជាដើម។ តួយ៉ាងនៅក្នុងរឿងទេវន្ទ កុម្ភណ្ឌទាំងបួនក្រោយពីស្ដាប់នូវធម្មទេសនារបស់ព្រះទេវន្ទរួចមក ក៏ទទួលបាននូវការគិតពិចារណាកឃើញនូវផ្លូវត្រឹមត្រូវសម្រាប់កសាងជីវិតរបស់ខ្លួនទៅជាតិខាងមុខ។ ដោយហេតុការសម្ដែងនូវធម៌របស់ព្រះទេវន្ទបានបង្ហាញអំពីកម្មពៀរបស់កុម្ភណ្ឌទាំងបួន ដែលបណ្ដាលឱ្យមកកើតជាយក្សបែបនេះ ដោយការអប់រំបង្ហាញនូវផ្លូវល្អនេះហើយទើបកុម្ភណ្ឌយក្សទាំងបួនបានភ្ញាក់រឭកមកធ្វើល្អ ហើយខំប្រឹងធ្វើល្អសាងនូវកុសលរក្សានូវសីលប្រាំ។ មិនតែប៉ុណ្ណោះ កុម្ភណ្ឌទាំងបួនបានយកទេវន្ទជាគ្រូ និងជានាបម្រើទេវន្ទលុះគ្រាអស់ជីវិតទៅ។

លុតលើព្រះបាទ ព្រះបរមនាថ ដាក់លើសិរិសា

ក្រួញក្រាបបង្គំ ប្រណម្យទូលថា យើងខ្ញុំនេះជា

ខ្ញុំព្រះអង្គហោង។

ព្រះអង្គសព្វញ្ញូ យើងទុកជាគ្រូ ជាម្ចាស់យើងផង

បម្រើបម្រុង ព្រះអង្គឥតហ្មង សិរសោរ៉ាប់រង

ទទួលអាសារ។ (ទំ.១៣៤)

ត្រង់នេះបង្ហាញឱ្យឃើញថាកុម្ភណ្ឌទាំងបួនទោះបីមានសាច់ឈាមរូបរាងអាក្រក់ ប៉ុន្តែក៏នៅចេះអភិវឌ្ឍខ្លួនដើម្បីបានល្អប្រសើរ ដោយដើរតាមការទូន្មានរបស់ទេវន្ទ ដែលពួកគេចាត់ទុកស្មើបានគ្រូអាចារ្យដែលជាអ្នកណែនាំឱ្យដើរលើផ្លូវប្រកបដោយសេចក្ដីប្រសើរ។ តាមរយៈតួអង្គកុម្ភណ្ឌទាំង៤ បានអប់រំដល់ជនានុជនគ្រប់រូបឱ្យចេះទទួលយកនូវការអប់រំ ការណែនាំ និងដើរតាមជនជាបណ្ឌិត ដើម្បីឱ្យផ្លូវជីវិតរបស់ខ្លួនមានការផ្លាស់ប្ដូរ និងវិវត្តឡើងថែមទៀត។

កំណាព្យមួយឃ្លារបស់ក្រមង៉ុយ ក្នុងកំណាព្យច្បាប់ល្បើកថ្មីលើកឡើង “*បើចង់ស្រោលខ្លួន រៀនសូត្រឱ្យមួន ឱ្យមាំឱ្យស្ទាត់ កុំចេះស្ទាក់ស្ទើរ ល្បីល្បើឥតបទ បើចេះប្រាកដ ប្រាក់រត់តាមហៅ*។” នេះជាឃ្លាកំណាព្យមួយដែលបាន

ដាស់តឿនក្រើនរំឭក អប់រំដល់យុវជនឱ្យ ឧស្សាហ៍ព្យាយាមក្នុងការសិក្សា ក៏ដូចជាការប្រកបរបរការងារជាដើម។ នៅក្នុងរឿងភោគកុលកុមារ អ្នកនិពន្ធក៏បានពន្លេចចេញនូវទស្សនៈនៃបណ្ដុះស្មារតីឱ្យ យុវជនត្រូវខិតខំប្រឹងប្រែងប្រកបការងារ ចេះកែខៃច្នៃនូវជីវិតរបស់ខ្លួនឱ្យបានប្រសើរឡើង។ តាមរយៈតួអង្គភោគកុលកុមារ នៅពេលពេលដែលគ្រួសារជាសេដ្ឋីបានធ្លាក់ខ្លួនក្រីក្រ មុនពេលឪពុកស្លាប់ គាត់បានផ្ដាំឱ្យភោគកុលកុមារយកសពគាត់ទៅចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី ហើយក្រោយពីនៅសល់ឆ្អឹងយកមកបង្អួស បើទាក់ត្រង់កន្លែងណា ឱ្យភោគកុលកុមារធ្វើចម្ការត្រង់នោះ៖

បើឆ្អឹងអាពុកអ្នក ជាប់ជំពាក់នឹងនិត្យនៅ
ទីឋានណាចូរចៅ គិតកាប់ឈើធ្វើចំការ។(ទំ. ១៥)

លុះដល់ រដូវធ្វើស្រែចម្ការ ភោគកុលកុមារក៏ធ្វើទៅតាមបណ្ដាំ ក៏បានជាប់ទាក់នៅទួលមួយ ហើយភោគកុលកុមារក៏បានធ្វើចម្ការនៅទីនោះឯង។ តាមរយៈបណ្ដាំរបស់ភោគសេដ្ឋីនេះ បានពញ្ញាក់ស្មារតី ឱ្យភោគកុលកុមារមានសេចក្ដីព្យាយាមឡើង ក៏ទោះបីជាអត់ពីឪពុក ហើយគ្មានទ្រព្យសម្បត្តិក៏ដោយ ក៏ត្រូវខិតខំឧស្សាហ៍ឡើងកុំចុះចាញ់នឹងវាសនា។ នៅត្រង់នេះពិតណាស់ថា តួភោគកុលកុមារជាពោធិសត្វ រមែងមានការអន្តរាគមន៍មកជួយជានិច្ចក៏ដោយ ក៏វាបានឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃសង្គម ប្រសិនបើយើងឧស្សាហ៍ព្យាយាមក្នុងការប្រកបកិច្ចអ្វីមួយដោយសុចរិតនោះ លទ្ធផលចុងក្រោយយើងនឹងអាចទទួលតបស្នងពីវា និងមានកេរ្តិ៍ឈ្មោះល្អនៅក្នុងសង្គមជាតិផងដែរ។

រីឯរឿងមរណមាតា ក៏បានបង្ហាញពីលក្ខណៈពិសេសក្នុងការអប់រំទូន្មានមនុស្សឱ្យចេះប្រើប្រាស់បញ្ញារបស់ខ្លួនក្នុងការដោះស្រាយបញ្ហាចំពោះ។ ស្ថិតក្នុងស្ថានភាពដ៏គ្រោះថ្នាក់នៅពេលដែលកុលកេសីបានជួបនឹងពួកចោរហើយពួកចោរបានយកទៅជួបនឹងមេស្រុកនោះគួសង្ស័យនេះ អាចនឹងស្លាប់ឬរស់នៅលើការដោះស្រាយបញ្ហានោះហើយ។ នាងកុលកេសីព្យាយាមរកគំនិតដោយជូនចិញ្ចៀនទៅមេស្រុក ហើយសុំធ្វើឪពុកធម៌ ព្រោះនាងអាចគិតថាមានតែមេស្រុកទេ ដែលជាអ្នកធំអស់គេ ហើយនឹងនឹងមិនខ្លាចនូវការគម្រាមកំហែងពីពួកចោរទៀត។ លើសពីនេះ ក្រោយពីបានរស់នៅជាមួយមេស្រុកហើយ នាងព្យាយាមសង្កេតមើលទីកន្លែងសម្រាប់រកស៊ី សង្កេតមើលពីរបៀបដែលអ្នករកស៊ីជួញដូរហើយបានឆ្លៀតចាប់ផ្ដើមរកស៊ីធ្វើជំនួញដោយខ្លួនឯងនិងបានកសាងផ្ទះបែកចេញពីមេស្រុកដែលជាបិតាធម៌។ នេះបង្ហាញឱ្យឃើញពីការដោះស្រាយបញ្ហាជីវភាពរស់នៅរបស់កុលកេសីក្នុងជីវភាពរស់នៅរហូតបានក្លាយជាសេដ្ឋី។ ដូចមានបង្ហាញនៅក្នុងអត្ថបទ៖

ទាំងនេះព្រោះកេសី ជាតិជាស្រីមានលក្ខណ៍ល្អ
ប្រាជ្ញាទ្រព្យមិនក្រ មិនខ្វះបាយពីថ្ងៃនោះ។...

នាងកុលកេសី ប្រើខ្ញុំប្រុសស្រី ឲ្យចរឲ្យចេញ
ឲ្យជួយជួយប្រែ ធ្វើស្រែចំណេញមាសប្រាក់បានពេញ
បានពោរទាំងផ្ទះ។ (ទំ. ១៨)

ពិតណាស់ត្រង់នេះបានស្តែងឱ្យឃើញ ពីគំនិតជាស្ត្រី ជាភរិយាដែលចេះសន្សំសំចៃមើលការខុសត្រូវក្នុងផ្ទះ ទើបគ្រួសារមានការរីកចម្រើនផងដែរ។ វាដូចទៅនឹងគំនិតខ្មែរដែលលើកឡើងថា «ផ្ទះធំស្រនុក ត្បិតភរិយាជា»។ នាងកុលកេសីបានប្រណិប័តន៍បានយ៉ាងខ្ជាប់ខ្ជួនរហូតបានបំបែកផ្ទះ ហើយក្លាយជាអ្នកមានទ្រព្យកោដិឃ្លាំងទៀតផង។

## ៤.៤- ឥទ្ធិពលទស្សនវិជ្ជាពុទ្ធសាសនាក្នុងការអប់រំចរិយាសាស្ត្រ

នាសម័យកណ្តាលនេះអក្សរសិល្ប៍ភាគច្រើន ច្រើនតែលើកពីទ្រឹស្តីពុទ្ធសាសនាមករៀបរាប់។ ដោយហេតុថាប្រជាជនជឿយ៉ាងពេញទំហឹងទៅលើពុទ្ធសាសនា។ ដូច្នេះការអប់រំត្រូវតែផ្សារភ្ជាប់នឹងទ្រឹស្តីពុទ្ធសាសនាជាចាំបាច់។ ការលើកយកទ្រឹស្តីពុទ្ធសាសនាមកនេះ ខ្លះក៏បានដកស្រង់រឿងផ្ទាល់របស់ព្រះសម្មាសម្ពុទ្ធ ចេញពីគម្ពីរព្រះត្រៃបិដក ខ្លះទៀតចេញពីមនោគតិរបស់អ្នកនិពន្ធដោយផ្សារភ្ជាប់នឹងទស្សនៈណាមួយរបស់សាសនាតែប៉ុណ្ណោះ។

### ក- ទស្សនៈកម្ម-ផល

ស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធ មហាវេស្សន្តរជាតកក៏បានចូលរួមស្ថាបនាសីលធម៌សង្គមតាមរយៈទស្សនៈកម្មផលនេះផងដែរ។ តម្លៃនេះទស្សនៈកម្មផលស្តែងឱ្យឃើញនៅចុងសាច់រឿងតែម្តង ពោលគឺការសជាតិរបស់តួអង្គនីមួយៗ។ យើងឃើញថា ការសាងនូវអំពើល្អក្នុងការឱ្យទានជាសប្បុរសរបស់ព្រះវេស្សន្តរនេះ បាននាំឱ្យព្រះអង្គបានក្លាយជាព្រះពុទ្ធអង្គ។ រីឯការសាងអកុសលកម្មរបស់ព្រាហ្មណ៍ជូជក ទាំងការមុសា ទាំងការធ្វើបាបជាលី និងកណ្ហាជិនា បានធ្វើឱ្យគាត់ក្លាយជាទេវទត្ត។ ទាំងនេះហើយជា បន្ទាត់ក្រិតនូវសកម្មភាពភាពរបស់មនុស្ស កុំឱ្យប្រព្រឹត្តិនូវអំពើអាក្រក់ បីដូចជូជក។ តួអង្គទេវទត្តនេះ ក្នុងផ្នត់គំនិតខ្មែរមិនល្អនោះទេ ត្បិតជាអ្នករាំងព្រះពុទ្ធអង្គមិនឱ្យបានត្រាស់ជាសម្មាសម្ពុទ្ធញ្ញាណ។

រីឯក្នុងទសជាតកដូចគ្នានេះដែរ ក្នុងរឿងសុវណ្ណសាមជាតក យើងឃើញយ៉ាងប្រត្យក្ស នៅក្នុងអត្ថបទ បានលើកឡើងថា នៅពេលដែលទុកូលនិងបារិកា បានចូលទៅជ្រកភ្លៀងនៅលើដំបូកមួយ ដែលនៅក្រោមនោះមានសត្វអាសិរពិសមួយអាស្រ័យនៅ។ បន្តិចក្រោយមក ញើស និងក្លិនខ្លួនរបស់ អ្នកទាំងពីរបានប៉ះនឹងខ្យល់ច្រមុះ ក៏នាំឱ្យអាសិរពិសនោះ បញ្ចេញចំហាយពិសតាមរន្ធច្រមុះ បណ្តាលឲ្យអ្នកទាំងពីរងងឹតភ្នែកមើលមិនឃើញ ។ ត្រង់នេះ យើងអាចដឹងថាផលដែលឥសីទាំងពីរនេះបានទទួល ប្រាកដជាមិនមែនកើតដោយគ្មានហេតុនោះទេ។ នៅក្នុងអដ្ឋកថា ភាសាបាលីដូចបានចែងថា កាលពីអតីតជាតិ អ្នកទាំងពីរនោះកើតក្នុងត្រកូលពេទ្យ។ ពេទ្យជាប្តីបានព្យាបាល រោគភ្នែកបុរសម្នាក់ដែលជាមហាធន។ បុរសមហាធនមិនបានឱ្យទ្រព្យអ្វី បន្តិចបន្តួចដល់ពេទ្យនោះសោះ។ លំដាប់នោះ ពេទ្យខឹងហើយត្រឡប់ទៅផ្ទះខ្លួនវិញប្រាប់ប្រពន្ធថា៖ នែភាន[47], បងបានព្យាបាលរោគភ្នែកបុរសម្នាក់ ឥលូវនេះ គេមិនឱ្យថ្លៃឈ្នួលដល់បងទេ តើយើងនឹងធ្វើដូចម្តេច?”។ ប្រពន្ធពេទ្យបានស្តាប់ហើយ ខឹងឆេវដែរ ឱ្យយោបល់ទៅដល់ប្តីថា៖ “យើងចាំបាច់ត្រូវការថ្លៃឈ្នួលពីគេធ្វើអ្វីបង ផ្សំតែថ្នាំមួយមុខ ដាក់ឲ្យគេខ្វាក់ភ្នែកទាំងសងខាងទៅវាជាការស្រេច”។ ពេទ្យជាប្តីយល់ព្រម ក៏ដើរទៅកាន់សម្នាក់បុរសមហាធន បានផ្សំថ្នាំដាក់ភ្នែកតាមយោបល់របស់ប្រពន្ធ។ បុរសមហាធននោះ មិនយូរប៉ុន្មានក៏ខ្វាក់ភ្នែកទាំងសងខាង។ដោយសារបុព្វហេតុនេះ ទើបតាបសទាំងពីរនោះ ត្រូវខ្វាក់ភ្នែកទាំងសងខាងទាំងពីរ

[47] គេហ៍; ពាក្យសម្រាប់ប្តីហៅប្រពន្ធ ក្នុងទីចំពោះមុខដោយស្មោះស្មើ ជាសម្តីរាបសារបស់ប្រជាពលរដ្ឋក្នុងបុរាណសម័យ។

នាក់ ក្នុងបច្ចុប្បន្នជាតិ។[48] នេះជាកម្មដែលកើតឡើងដោយសារកម្មពីជាតិមុនរបស់អ្នកទាំងពីរបានប្រព្រឹត្ត ហើយវាបានអន្ទោលមកដល់បច្ចុប្បន្នជាតិរបស់ពួកគេ។ កម្មផលនេះគេហៅថា ទិដ្ឋធម្មវេទនីយកម្ម។ត្រង់នេះផងដែរប្រសិនបើកម្មដែលគាត់បានសាងនោះ មិនបានឲ្យផលមកបច្ចុប្បន្នជាតិនេះ កម្មនោះនឹងត្រូវទៅជាអហោសិកម្ម គឺមិនអាចនឹងឱ្យផលទៅជាតិមុខបានទៀតនោះឡើយ។ ការលើកយកនូវទស្សនៈកម្មផលជាក់បញ្ចូលនេះ បានចង់ដឹងមនុស្សទូទៅឱ្យប្រព្រឹត្តអំពើសុចរិតជាចម្បង កុំបីមានចិត្តចងគំនុំគុំក្ហួនគ្នាទៅវិញទៅមក។

ងាកក្រឡេកមកមើលរឿងបញ្ញាសជាតកវិញ ក្នុងដំណើររឿងក្រុងសុភមិត្រ ដើមចមដែលនាំបែកបាក់ព្រាត់ប្រាស់គ្នាប្រពន្ធកូននេះគឺបណ្ដាលមកពីកម្មពៀរនេះតែម្ដង។ ជាការពិត ជ័យសែននិងជ័យទត្តបានទៅយកសេកសោមពីសម្បុកហើយបានដករោមបីទង ធ្វើចេញឈាមក្រហមឆ្អិនឆ្អៅ ដូចលើកឡើងថា៖

| | |
|---|---|
| កាលព្រះអង្គវែងទុក្ខទល់ | ហេតុអំពល់អំពើពៀរ |
| កាលស្ដេចយកបក្សី | សត្វសេកសោមឱ្យបុត្រា។ |
| ទាំងពីរយកមកលេង | គិតពុំក្រែងពៀរវេរា |
| ហើយបោចរោមសារិកា | បីទងទើបឈាមច្រាលឆ្អៅ។( ទំ.៣៥ ) |

នេះហើយជាបុព្វហេតុដែលនាំឱ្យអ្នកទាំងបួនព្រាត់ប្រាស់គ្នាគួរឱ្យសង្វេគ។ តែកម្មនេះមិនមែនអន្ទោលតែមួយជាតិនេះទេ វាអន្ទោលអស់៥០០ជាតិទៅហើយ។ ត្រង់នេះបានបង្ហាញយ៉ាងប្រត្យក្សថា ការដែលបៀតបៀនជីវិតអ្នកដទៃវានាំឱ្យខ្លួនមានកម្មពៀរ។ ម្ល៉ោះហើយ ពិតមែនថាជាទស្សនៈកម្មផលក្នុងពុទ្ធសាសនា តែវាបានបង្រៀនមនុស្ស ឱ្យខ្លាចអាក្រិត្យនូវសីលធម៌ សកម្មភាពឱ្យចៀសវាងការស្លាប់ ធ្វើបាបជីវិតអ្នកដទៃ នេះត្រឹមតែបោចរោមសត្វ៣ទង ចុះបើប៉ះពាល់ដល់ជីវិតសត្វ ឬមនុស្សទៀតតើនឹងមានពៀរប៉ុន្មានរយជាតិ។

ជាការពិតណាស់ បើយើងមើលមកលើរឿងទេវន្ទនេះវិញ ឃើញថាតួអង្គព្រះនាងសុវណ្ណកេសរកាលដែលត្រូវយក្ខិនីវាយ សម្រាតយកសម្លៀកបំពាក់បែបនោះ ក៏ព្រោះតែកម្មពៀររបស់ព្រះនាងពីអតីតជាតិ។ កាលដែលនៅជានាងអាមិត្តា ជាប្រពន្ធជជិលសេដ្ឋី។ កន្លងកាលយូរទៅសេដ្ឋីក៏សុំទៅបួសជាឥសីនៅក្នុងព្រៃជារៀងរាល់ថ្ងៃនាងអាមិត្តាតែងតែយកភោជនទៅជូនឥសីជាប្រក្រតី។ វេលាមួយ នៅពេលដែលនាងយកអាហារទៅឱ្យឥសីដែលជាប្ដីរបស់នាង ក៏ឃើញកិន្នរីមួយនៅ ចចារសួរនាំជាមួយឥសី ហើយក៏កើតចិត្តប្រចណ្ឌដោយមិនបានគិតពិចារណា ឬសួរនាំប្ដីជាមុនហើយក៏យករំពាត់ទៅវាយនាងកិន្នរីនោះឱ្យរងឈឺចាប់ទាំងកាយ និងទាំងចិត្តផងដែរ។ ហេតុនេះហើយ បានជាពេលអស់ជីវិតទៅក៏បានធ្លាក់ទៅរងទុក្ខនៅនានរក អស់ជាច្រើនជាតិអង្វែងសែនយូរ។ លុះដល់ផលបុណ្យដែលបានសាងឱ្យផល ទើបអមិត្តាបានមកកើតជាបុត្រីរបស់ក្សត្រ។ ដោយសារកម្មដែលនាងអមិត្តាបានវាយនាងកិន្នរឈឺគ្រាំគ្រានេះហើយ ទើបបានជាជាតិនេះព្រះនាងត្រូវរងកម្មគឺយក្ខិនីវាយធ្វើបាន ប៉ងសម្លាប់ហើយបានបណ្ដែតចោលទៅតាមទឹកក្នុងជាតិនេះ។ ដូចមានបញ្ជាក់នៅក្នុងអត្ថបទ៖

| | | |
|---|---|---|
| បានជាយក្ខិនី | វាវាយក្សត្រី | ព្រោះកាលជាតិមុន |

[48] កុល ផេង, *ព្រះសុវណ្ណសាមជាតក ពិស្ដារ*,ភ្នំពេញ, ២៥៦០, ទំ.២៨

នាងវាយកិន្នរ ថ្ងះមរណាជន ជាតិជាទូរុន

ទូរអាត្មា ។(ទំ. ២៦៥)

នេះបង្ហាញឱ្យឃើញពីផលកម្មរបស់ព្រះនាងសុវណ្ណកេសរ ដែលបានសាងពីអតីតជាតិ ហើយវាបន្តមកតាមរហូតដល់បច្ចុប្បន្នជាតិ ក៏បានទទួលនូវសម្បត្តិល្អដោយសារតែកុសលកម្មរបស់ព្រះនាងក្នុងអតីតជាតិដែលបានបម្រើព្រះមុនីឥសី ហើយក៏មានទទួលរងទុក្ខវេទនា ត្រូវយក្ខិនីវាយធ្វើបាបប៉ងសម្លាប់ ក៏ព្រោះតែអកុសលកម្មដែលព្រះនាងបានវាយនាងកិន្នរីក្នុងអតីតជាតិដែរ។ យើងឃើញថា បញ្ហាផលកម្មត្រូវបានពន្លេចឡើងនៅក្នុងសាស្ត្រាទេវន្ទនេះ ទាំងកុសលកម្ម និងអកុសលកម្ម។ តួយ៉ាង ព្រះនាងសុវណ្ណកេសរបានមកយកកំណើតជាបុត្រព្រះមហាក្សត្រក៏ព្រោះតែកុសលកម្មរបស់ព្រះនាងពីជាតិមុន ហើយរងទុក្ខវេទនាក្នុងនរក ក៏ដូចជាត្រូវយក្ខិនីធ្វើបាប ក៏ព្រោះតែអកុសលកម្មរបស់ព្រះនាងក្នុងអតីតជាតិដូចគ្នា។

យើងអាចឃើញយ៉ាងប្រត្យក្សនូវកម្មផលដែលកើតឡើងទាន់ហន់ នៃការប្រព្រឹត្តនូវអំពើរបស់ខ្លួននាបច្ចុប្បន្នជាតិ។ ជាក់ស្តែងតួអង្គព្រះបាទព្រហ្មទត្ត និងមេស្រុក ដែលជាអ្នកព្យាយាមព្យាបាទភោគកុលកុមារទាំងប្រជល់ដំរី លូកទឹកក្តៅ រហូតដល់ធីស៊ុត ដើម្បីយកនាងសុខុមាន្ទាទេវីមកធ្វើជាមហេសី។ ទោសនៃការលួច ឬចង់បានប្រពន្ធអ្នកដទៃនេះវាជាអំពើថ្គាំថ្គងមួយដែលខ្លួនជាថ្នាក់ដឹកនាំទៀតផងនោះ ហ៊ានប្រព្រឹត្ត។ ការណ៍នេះបាននាំឱ្យ ព្រះបាទព្រហ្មទត្តរួមជាមួយនឹងមេស្រុកធ្លាក់ទៅក្នុងនរកមហាតាបន៍ រហូតដល់កន្លះកប្បទៀតផង។

កាលនោះឯកអង្គមហាក្សត្រ ព្រះបាទព្រហ្មទត្ត នូវគាមភោជកអប្រិយ។
ភិតធ្លាក់ពីលើដំរី ដួលដល់ផែនដី ក្សីណក្ស័យជីវិតជន្មា។
ធ្លាក់ទៅសោយទុក្ខវេទនា នៅនរកមហា- តាបន៍ដល់កន្លះកល្បគត់។(ទំ. ១៤៧)

នេះសឱ្យឃើញពីបញ្ហាកម្មផលដែលកើតចេញពីការប្រព្រឹត្តមិនល្អនាបច្ចុប្បន្នជាតិ ហើយនាំឱ្យផលនោះឆ្លងដល់អនាគតជាតិទៀតផង។ ប្រការនេះក៏ទោះជាយកបញ្ហាកម្មផលក៏មកសម្អាងពិត តែអ្នកនិពន្ធបានបង្ហាញបម្រាមមួយជាផ្នត់គំនិតឱ្យប្រជារាស្ត្រខ្មែរ គិតគូរកុំបៀតបៀនប្រពន្ធប្តីកូនអ្នកដទៃ នាំឱ្យមានកម្មពៀរបែបនេះ។

នៅក្នុងខ្សែរឿង មរណមាតាវិញ ហាក់ប្លែកអំពីសាស្ត្រាមួយចំនួន ពោលគឺបានលើកពីបញ្ហាកម្មផលដែលសាងឡើងក្នុងបច្ចុប្បន្នជាតិ ហើយទទួលផលក្នុងបច្ចុប្បន្នជាតិតែម្តង ដែលកម្មនេះគេហៅថា ទិដ្ឋធម្មវេទនីយកម្ម។ យើងឃើញថា ដោយហេតុតែគ្រួសារកាឡីបានរៀបគម្រោងការសម្លាប់មរណមាតា ហើយឱ្យកូនស្រីខ្លួននាងចន្ទណី ក្លែងខ្លួនជាមរណមាតា ហើយទៅចូលរាជវាំងធ្វើជាមហេសីព្រះរាជា។ ដោយសារកម្មពៀរដែលបានធ្វើអំពើអកុសលមកលើមរណមាតានេះហើយ គ្រួសារកាឡីត្រូវរងនូវភាពលំបាកវេទនាកម្មតាមយ៉ាងទាន់ហន់ គឺនាងចន្ទណីត្រូវបានព្រះរាជាដាក់ទោសប្រហារជីវិត ហើយចំណែកគ្រួសារនាងវិញគឺកាឡី កុដុម្ពីក៍ និងចន្ទី ត្រូវព្រាត់ប្រាស់ចេញពីភូមិឋាន ផ្ទះសម្បែងធ្លាប់ជ្រក ធ្វើដំណើររងទុក្ខវេទនាក្នុងព្រៃយ៉ាងយូរ ដូចរៀបរាប់ថា៖

អស់បានទីសប្បាយ កើតអន្តរាយរត់ចោលស្រុក
ពីថ្ងៃនេះទៅមុខ មានតែទុក្ខភ័យជាអាទិ៍។

នេះសមកម្មអំពើ ដែលយើងធ្វើចិត្តប្រមាទ
ពៀរដែលយើងពិឃាត នៃនាងមរណមាតា។ (ទំ. ១៤៤-១៤៥)

ត្រង់នេះហើយ បានបញ្ជាក់ឱ្យឃើញពីកម្មដែលអ្នកទាំងបីបានសាងដោយផ្សំគំនិតគ្នាសម្លាប់នាងមរណមាតា ហើយកម្មនេះមិនបានទុកផ្តន្ទាដល់ជាតិក្រោយនោះទេ វាបានតបស្នងនៅក្នុងបច្ចុប្បន្នជាតិនេះតែម្តង។ ការលើកឡើងរបស់ កវី អ៊ុក នេះ ហាក់មានភាពត្រូវទៅនឹងបញ្ហាលោកិយសច្ចៈច្រើន ដ្បិតនរណាសាងអ្វីរមែងទទួលបាននូវផលដែលគេសាងនោះភ្លាមៗ ដោយពុំរង់ចាំជាតិខាងមុខ។

**ខ- បញ្ចសីល**

យើងឃើញមានធម៌ក្នុងការប្រតិបត្តិដូចជា និច្ចសីល ឧបោសសីល ទសសីល និង ចតុប្បារិសុទ្ធិសីល។ ធម៌ទាំងនេះសុទ្ធតែចូលរួមកសាង សន្តិភាពក្នុងចិត្ត សន្តិភាពផ្លូវកាយ និងសង្គមទាំងមូលដែរ។ វាធ្វើឱ្យមនុស្សវៀសចាកចរិតឥរិយាបថដែលជាអំពើអាក្រក់ទាំងពួង ហើយប្រកាន់ខ្ជាប់នូវសីលធម៌ គុណធម៌ សុជីវធម៌ជាមនុស្ស។ ជាក់ស្តែង និច្ចសីលឬ បញ្ចសីល ឬ សីលប្រាំ ជាសីលដំបូងក្នុងការប្រតិបត្តិក្នុងនាមជាពុទ្ធសាសនិក។ និច្ចសីលមានសិក្ខាបទចំនួនប្រាំ គឺ បាណាតិបាតា អទិន្នាទានា កាមេសុមិច្ឆាចារា មុសាវាទា សុរាមេរយមជ្ជប្បមាទដ្ឋានា។ក្នុងនិច្ចសីលបានអប់រំច្រើនមិនត្រឹមតែជាទ្រឹស្តីធម៌អាថ៌ប៉ុណ្ណោះទេ តែបានជួយមួយផ្នែកដល់ការអប់រំសីលធម៌ សន្តិភាពរបស់មនុស្ស។

នៅក្នុងសុវណ្ណសាមជាតកក៏បានបង្ហាញពីការទេសនារបស់សុវណ្ណសាមទៅកាន់ បិលយក្សដែលបានដឹងកំហុសខ្លួន។ ក្នុងនោះសុវណ្ណសាមបានបង្ហាញថា បើចង់រួចផុតពីកម្មទាំងឡាយ និងចង់ឱ្យព្រះអង្គទៅកើតនៅសួគ៌ទេវលោកនាយ គប្បីឱ្យប្រព្រឹត្តិគន្លងធម៌ទាំង១០ប្រការ។ លើសពីនេះព្រះពោធិសត្វបានប្រទាននូវសីលប្រាំឱ្យបិលយក្សយកទៅរក្សាផងដែរ។ នេះហើយជាឥទ្ធិពលមួយដ៏សំខាន់នៃទស្សនៈសីលប្រាំ ឬបញ្ចសីល ឬនិច្ចសីលនេះឯង បានបញ្ចូលទៅក្នុងស្នាដៃរឿង ប្រសិនបើមនុស្សចង់កើតនូវសួគ៌ឋានគប្បីរក្សា និងប្រព្រឹត្តនូវសីលនេះឯង។ នៅក្រោយការចង់បានសោយសុខនៅសួគ៌ឋាននេះ ការបើមនុស្សប្រព្រឹត្តនូវសីលទានទាំងនេះនាំឱ្យសង្គមគេទាំងមូលមានភាពសុខសាន្តគ្មានជម្លោះ គ្មានការប្រទូស្តរាយកើតឡើងនោះឡើយ។

ចំណែកឯរឿងក្រុងសុភមិត្រវិញ ក៏បានបង្ហាញពីទស្សនៈនិច្ចសីលនេះដែរសម្រាប់អប់រំជននានុជនទាំងឡាយឱ្យប្រកាន់ខ្ជាប់។ ក្រោយពេលការដឹងគ្រប់សព្វក្រុងសុភមិត្រ បានរៀបចំឱ្យបុត្ររបស់ខ្លួនទាំងពីរគឺ ជ័យសែនជាបងឡើងគ្រងរាជ្យសម្បត្តិបន្ត រីឯជ័យទត្តជាប្អូនឡើងជាអគ្គមហាសេនា។ ពេលដែលជ័យសែនឡើងគ្រងរាជ្យទ្រង់ក៏បានប្រកាន់ខ្ជាប់នូវទសពិធរាជធម៌ សុចរិតធម៌ ព្រមទាំងទ្រង់រក្សាសីលប្រាំ អដ្ឋសីល ភាវនារៀងរាល់រាត្រី។ លើសពីនេះទ្រង់ក៏បានទូន្មានអស់សេនាមន្ត្រីឱ្យកាន់នូវសីលប្រាំជានិច្ច ដូចលើកឡើងថា៖

ស្តេចទ្រង់សីលប្រាំ អដ្ឋសីលចាំ សព្វទិនទិវា
សង្វេគសង្វាត ស៊ឹងស្នាធ៏ភាវនា នៅលើប្រាង្គប្រា-
សាទសព្វរាត្រី។
ព្រះអង្គក្សត្រក្សាន្ត ស្តេចតែងទូន្មាន សេនាមន្ត្រី

ឱ្យកាន់សីលប្រាំ ចងចាំស្មារតី រាស្ត្ររដ្ឋសោភី

ក្សេមក្សាន្តនគរ។(ទំ.៩៣)

នេះហើយ យើងឃើញថា ទង្វើនិងការអប់រំទូន្មានប្រៀនប្រដៅរបស់ ជ័យសែន វាពិតមែនថាជាទស្សនៈរបស់សាសនាក៏ពិតមែន តែវាបានបម្រើឱ្យសេចក្តីត្រូវការ ភាពសុខសាន្តរបស់មនុស្សទូទៅ។ ប្រសិនប្រើសេនាមន្ត្រី ប្រជានុរាស្ត្រ ចៀសវាង អំពើទាំង៥នោះ ការលួច ការសម្លាប់ ការកុហក ការចង់បានប្រពន្ធកូនគេ ការសេពគ្រឿងស្រវឹងនោះ វានឹងធ្វើឱ្យសង្គមមានស្ថិរភាព គ្មានភាពរញ៉េរញ៉ៃទៀតផង។ ទាំងនេះបើនិយាយពីផ្លូវលោក តែបើមើលទៅផ្លូវសាសនា អ្នកទាំងនោះនឹងទៅកើតនៅឋានសួគ៌ពិតប្រាកដ។

ក្នុងការរក្សានូវបញ្ចសីលនេះ ការទទួលយកនូវបញ្ចសីលក៏ជាឥទ្ធិពលមួយរបស់ទ្រឹស្តីព្រះពុទ្ធសានាផងដែរ។ តាមរយៈសាស្ត្រាទេវន្ទនេះ បានបង្ហាញពីការទទួលយកនូវបញ្ចសីលពីកុម្ភណ្ឌទាំងបួន ដើម្បីបានស្តាប់នូវព្រះធម៌ទេសនាពីសំណាក់ព្រះទេវន្ទ។ ហេតុតែចង់ស្តាប់នូវព្រះធម្មទេសនារបស់ព្រះទេវន្ទ កុម្ភណ្ឌទាំងបួនក៏ព្រមឱនសិរសាបង្គំទទួលសុំស្មាទាននូវបញ្ចសីល។ ដូចលើកឡើងថា៖

ទើបពោធិសត្វ ពន្លកពុទ្ធង្ករ បន្ទូលទៅថ្កាន
ហៃអស់មហាយក្ស សីលប្រាំស្មាទាន ចូរអ្នកឲ្យបាន
ចាំជាក់ប្រក្រតី។
បាណាតិបា- តាអទិន្នា កាមេសុរា
មិឆាចរិយា មុសាវាទិ មជ្ជំបិរិ
វេរមណា។
បាណាតិបាត ឲ្យវៀរប្រមាទ ជីវិតសត្តា
អទិន្នាទាន វៀរមានលោភា លោភលួចទ្រព្យា
នៃអស់មហាជន។
កាមេសុមិច្ឆា កុំបរទារកា វៀរលួចប្រពន្ធ
នៃអ្នកនានា ឲ្យមកជាម- ន្ទិលទាស់ទូរន់
ដូចដល់អាត្មា។
មុសាវាទី វេរមណី វៀរពាក្យមុសា
មជ្ជំបិរី វៀរពីសុរា គឺលាមកជា
ថ្នាំបំពុលអង្គ។
ពន្លកសារពេជ្រ ឲ្យសីលប្រាំស្រេច ទៀងទើបត្រាស់ទ្រង់
បន្ទូលទៅថា ហៃមហាយក្សយង់ ចូរប្រស្តែងទ្រង់
ស្មារតីរាល់គ្នា។(ទំ. ១៣៥-១៣៦)

នេះបង្ហាញឱ្យឃើញពីការទទួលយកនូវបញ្ចសីលរបស់កុម្ភណ្ឌទាំងបួន ដើម្បីបានស្តាប់នូវធម្មទេសនារបស់ព្រះទេវន្ទ។ តាមរយៈអត្ថបទដកស្រង់ខាងលើ សបញ្ជាក់ថាតួអង្គយក្សទាំងបួនបានទទួលនូវបញ្ចសីល ដោយបានឱនកាយបង្គំព្រះទេវន្ទ ដែលនមស្សការនូវសីលប្រាំឱ្យទៅដល់កុម្ភណ្ឌទាំងបួន។ យើងឃើញថាឥទ្ធិពលពុទ្ធសាសនានេះបានចាក់ឫសយ៉ាងជ្រៅក្នុងសាស្ត្រាទេវន្ទនេះ ដោយបានបង្កប់នូវគោលទ្រឹស្តីព្រះពុទ្ធសាសនាគឺសីលប្រាំនេះឯង។ ម្យ៉ាងទៀតបានបង្ហាញពីការសម្តែងនូវធម៌ទេសនា ដែលជាការអប់រំទូន្មានរបស់ព្រះសម្មាសម្ពុទ្ធក្នុងសម័យពុទ្ធកាល ដែលបន្តរហូតមកហើយអ្នកនិពន្ធបានលើកយកទ្រឹស្តីនេះមក បញ្ចូលក្នុងស្នាដៃរបស់ខ្លួន ហើយបានបង្ហាញពីតួអង្គទេវន្ទ ដែលជាតួអង្គព្រះពោធិសត្វ ជាអ្នកសម្តែងនូវធម៌ទេសនាទូន្មានដល់ដល់កុម្ភណ្ឌទាំងបួន។

ជាការពិតណាស់បើក្រឡេកមកមើលរឿង ភោគកុលកុមារជា ប្រភេទអក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុនេះវិញ យើងឃើញថា ក្នុងការគ្រងរាជ្យរបស់ ព្រះបាទភោគកុលកុមារតែងមានព្រះទ័យសប្បុរស ធ្វើទានដល់អាណានុរាស្ត្រ។ ព្រះអង្គក៏បានប្រៀនប្រដៅអស់មន្ត្រី សេនាបតី ប្រុសស្រីទូទាំងនគរឱ្យចេះរក្សាសីល ពិសេសសីលប្រាំនេះតែម្តង ដូចលើកឡើងថា ៖

| | | |
|---|---|---|
| ត្រេកទ្រង់សីលប្រាំ | អស្តង្គសីលចាំ | ពុំភ្លាត់ភ្លេចភ្លាំង |
| ទូន្មានមន្ត្រី | ប្រុសស្រីរាស្ត្រទាំង | នគរឲ្យតាំង |
| | រក្សាសីលធម៌។(ទំ.២០៤) | |

ក្នុងការទូន្មាននោះព្រះអង្គក៏បានប្រាប់ដល់រាស្ត្រនូវសិក្ខាបទទាំងប្រាំ ព្រមទាំង បាបកម្មដែលទ្រុស្តទៅនឹងសីល និងកុសលកម្មដែលបានទទួលពេលប្រព្រឹត្តសិក្ខាបទនេះ។

- ***សិក្ខាបទទីមួយ*** គឺបាណាតិបាតា ដោយទ្រង់លើកថា រីនរណាជាអ្នកសម្លាប់ឬ ចិត្តប៉ងស្លាប់ម្រឹគីម្រឹគា មច្ឆា ឬមនុស្សនោះ នឹងត្រូវវេងបាបក្នុងឋាននរក ដោយយមរាជបោះចូលក្នុងភ្លើងក្តៅសន្ធោសន្ធៅ។ រីឯយមបាល ចាក់នឹងស្នច្បូកដែកក្តៅ។កាលបើគម្រប់ប្រាំរយឆ្នាំ ដោយប្រាំបួនលានឆ្នាំមនុស្សទើបស្មើមួយថ្ងៃឋាននរក។ ក្រៅតែអំពីវេងទុក្ខនោះហើយ កាលបើមកកើតជាមនុស្សនឹងក្លាយទៅជា មាន់ ជ្រូក ទា ត្រី ដែលគេកាប់សម្លាប់ ចំនួនប្រាំរយជាតិ។ ប្រសិនបើកើតជាមនុស្ស ត្រូវគេចាក់ កាប់ បាញ់ ដោយ អស់ប្រាំរយជាតិដូចគ្នា។លើសពីនេះគេនឹង ក្លាយទៅជាមនុស្សមានរោគា ដំបៅពក គមខ្នង ភ្នែកខ្វាក់ខ្វិន ដៃជើងកៀងកួង់ ហើយប្រសិនបើមានបុណ្យសក្តិនឹងឆាប់អាយុខ្លីជាដើម។ ផ្ទុយទៅវិញប្រសិនបើគេអនុវត្តខ្ជាប់ខ្ជួននូវសិក្ខាបទនេះគេនឹងទៅកើត នៅនាឋានសួគ៌ចាតុម្មហារាជិកា ជាទេវបុត្រស្អាតបិតនៅលើប្រាសាទប្រាំពីរយោជន៍ តែបើជាស្ត្រីនឹងកើតជាទេពកញ្ញាផងដែរ។ អ្នកទាំងពីរគម្រប់ ប្រាំរយឆ្នាំគត់ ទើបច្យុតចុះមកផែនដីកើតក្នុងត្រកូលក្សត្រ រស់នៅដោយសុខដុមពុំមានជំងឺ ពុំមានសត្រូវណាមកបៀតបៀនឡើយ។
- ***សិក្ខាបទទីពីរ*** ព្រះបាទភោគកុលកុមារបានទូន្មានចំពោះការប្រព្រឹត្តអទិន្នាទានា ដែលមនុស្សលួចទ្រព្យអ្នកដទៃបោកបញ្ឆោត បំពានដោយអាងយសសក្តិលើអ្នកដទៃ។អ្នកទាំងនេះបានបានធ្លាក់នរក ហើយត្រូវបានយមបាលចាប់ចង ធាក់វាយដំ យកបន្ទាត់ដែកមុតចាក់ផ្ទាត់សព្វកាយពីក្បាលដល់ចុងជើង អស់កាលកំណត់១

ពាន់ឆ្នាំ។ មួយពាន់ឆ្នាំឋានត្រៃត្រឹង្ស ទើបមួយថ្ងៃឋាននរក។លុះសម្រេចនៅនរកហើយមកកើតជាប្រេតវិញម្តង ដែលមានកម្ពស់ខ្ពស់ចុងត្នោត អស់ប្រាំរយជាតិ។ប្រសិនបើកើតជាមនុស្សមានទ្រព្យតិចតួច មានចោរចាំលួច បើកើតជាខ្ញុំគេ ត្រូវម្ចាស់វាយដំ។ រីឯអ្នកដែលវៀរចាក នូវសិក្ខាបទនេះមិនលួច ប៉ះពាល់ទ្រព្យសម្បត្តិអ្នកដទៃ អ្នកនឹងទៅបានកើតនៅឋានសួគ៌ត្រៃត្រឹង្សមានទេពអប្សរ បរិវកញ្ញាមួយពាន់ចោមជាបរិវារ។ នៅក្នុងប្រាសាទខ្ពស់ ទ្វាទសយោជន៍ រចនាពិចិត្រយ៉ាងប្រណិត។ គម្រប់មួយពាន់ឆ្នាំបាន ទៅកើតជាត្រកូលក្សត្រមានទ្រព្យសម្បត្តិច្រើនពន់ពេក។ បើកើតជាត្រកូលរាស្ត្រ នឹងកើតជាសេដ្ឋីមានទ្រព្យច្រើន មានសក្តិយស និង ពុំមានចោរសត្រូវណាមកបៀតបៀនឡើយ។

❖ ***សិក្ខាបទទីបី***គឺ កាមេសុមិច្ឆាចារា ដែលទ្រង់ទូន្មានថា នរណាដែលមិនមានចិត្តវង្វេងលួចភរិយាគេ ស្រីផិតប្តីឯងជាដើម។ អ្នកទាំងនោះនឹងទទួលនូវកម្មនៅនរក ត្រូវយមបាលដេញឱ្យឡើងដើមរកាដែកជាភ្លើង ប្រមាណមួយយោជន៍។ស្រីឡើងមុន បន្ទាប់មកប្រុស ផ្ទុះផ្លាយស្រែកយំគួរឱ្យសង្វេគ។ មិនតែប៉ុណ្ណោះមានឆ្កែស ប៉ុនដំរីខាំកន្ត្រាក់ ត្មាតក្អែកចាំចឹកផ្ទុះធ្លាក់ខ្លួន ត្រូវភ្លើងឆេះ។ស្លាប់ក្នុងមួយថ្ងៃពីរពាន់ដង ត្រូវវេងទុក្ខអស់ ពីរពាន់ឆ្នាំ ដែលអាយុពីរពាន់ឆ្នាំទិព្វ ស្មើនឹងឋានសួគ៌មួយថ្ងៃ មួយយប់នរក។ បើយោងយកកំណើតជាសត្វតិរច្ឆាន នឹងត្រូវគេក្រៀវ អស់ប្រាំរយជាតិ។កើតជាមនុស្សខ្ទើយប្រាំរយជាតិ បើកើតជាស្រីត្រូវព្រាត់ប្តីប្រាំរយជាតិ។ បើកើតជាមនុស្សប្រុស ត្រូវមានកម្មជួបប្រពន្ធផិតរហូត។ ផ្ទុយទៅវិញបើអ្នកប្រណិប័តន៍បានខ្ជាប់ខ្ជួននោះគេនឹងសោយសម្បត្តិសួគ៌ឋិតនៅក្នុងប្រាសាទពិចិត្រ មានទេពអប្សរពីរពាន់ចាំគាល់។ លុះអាយុបានពីរពាន់ឆ្នាំទិព្វ ច្យុតមកយោងយកកំណើតជារាជបុត្រ ប្រកបដោយលក្ខណាគ្រប់គ្រាន់។

❖ ***សិក្ខាបទទីបួន*** គឺមុសាវាទា ភោគកុលកុមារបានអប់រំថា អ្នកឯណា កុហកកាច មានពាក្យរឹងរូស ប្រទូស្តរាយកំហឹង បញ្ឆកបញ្ឆោត ភូតភរឱ្យគេបង់ទ្រព្យ បង់ស្រែ ឬកើតទុក្ខជាដើមនោះ គេនឹង ទៅនរកសោយទុក្ខអស់ បួនពាន់ឆ្នាំ ព្រោះមាត់អាក្រក់។ យមបាលយកដង្កាប់ដែកមកដុត ដកអណ្តាត ទម្លាក់ចូលទៅក្នុងរណ្តៅ គម្រប់បួនពាន់ឆ្នាំស្មើនឹងឋានតុសិតមួយថ្ងៃ។ លុះបានកើតមកជាប្រេត មាត់ឆេះចេញភ្លើង ស៊ីខ្ទុះឈាមជាអាហារ។កាលបើបានកើតជាមនុស្ស ក្លាយជាមនុស្សមាត់វៀចឆែប ល្ងង់ គថ្លង់ មាត់ស្អុយជាដើម។ រីឯអ្នកដែលប្រកាន់ខ្ជាប់ស្រដីពាក្យសត្យនោះគេនឹងទៅកើតនៅឋានតុសិត អាយុបួនពាន់ឆ្នាំមានបរិវារ ទេពអប្សរចាំគាល់នៅប្រាសាទកម្ពស់ប្រាំយោជន៍។អស់និស្ស័យនឹងកើតជាអ្នកប្រាជ្ញចេះធម៌អាថ៌។

❖ ***សិក្ខាបទទីប្រាំ*** គឺសុរាមេរិយ ដែលសិក្ខាបទនេះបានអប់រំឱ្យចៀសវាងការផឹកស្រា នាំឱ្យភ្លេចភ្លាំងស្មារតី។ អ្នកដែលប្រព្រឹត្តនឹងធ្លាក់ទៅក្នុងនរកគឺ តាបន៍នរក អស់ប្រាំបីពាន់ឆ្នាំ។ ជននោះនឹងផឹកទឹកទង់ដែង ក្តៅក្តាត់រលាករលួយ។ គេនឹងកើតជាយក្សត្រិយ មនុស្សលីលា មានពាក្យអសុរោះរឹងទ្រគោះ ដែលអ្នកផងតិះដៀលនិន្ទា ជាមនុស្សមោហោជួជាតិខ្លួនខ្មៅជាដើម។តែបើវៀរចាកការសេពសុរា អ្នកនោះនឹងទៅបានសោយសុខនៅនិម្មានិរតី កម្ពស់ប្រាសាទសាមសិបយោជន៍ មានទេពអប្សរប្រាំបីពាន់គាល់បម្រើ។ គម្រប់ប្រាំបីពាន់ឆ្នាំទិព្វកើតជាស្តេចមានចេស្តា ប្រកបដោយប្រាជ្ញាខ្លាំងក្រៃ។ ជាមនុស្សមានចិត្តខ្លាចបាប ពោលពាក្យល្អគំនិតជ្រៅជ្រះ។

ជាការពិតណាស់ដូចដែលយើងបានដឹងអំពីការលើកឡើងនូវការណែនាំរបស់ ព្រះបាទភោគកុលកុមារ ទៅដល់មន្ត្រីអស់រាស្ត្រទាំងនគរឱ្យប្រព្រឹត្តខ្ជាប់ខ្ជួនក្នុងនាមជាពលរដ្ឋល្អនិងជាពុទ្ធសាសនិកមួយ។ ការលើកឡើងនេះមិនមែនតែជាគំនិតរបស់ភោគកុលកុមារនោះទេ តែជាគំនិតរបស់កវីនិពន្ធខ្មែរ គឺព្រះឃ្លាំងនង តែម្តងក្នុងន័យអប់រំចរិយាយសម្បត្តិប្រជាជនខ្មែរឱ្យចេះគោរពគ្នា ឱ្យតម្លៃគ្នានិងរស់នៅក្នុងសង្គមមួយប្រកបដោយសន្តិភាព។ វិធីក្នុងការអប់រំរបស់លោកមិនមែនទៅយកដាវ កាំបិត ទាហានទៅបង្ក្រាប ឬប្រាប់ដោយចំៗថាខុសទៅនឹងវិន័យច្បាប់នោះទេ ។ ផ្ទុយទៅវិញ ស្ថិតនៅក្នុងចន្លោះពេលដែលខ្មែរជឿ និងទទួលឥទ្ធិពលខ្លាំងពីពុទ្ធសាសនា លោកក៏បានបញ្ច្រាបការអប់រំនេះ តាមរយៈស្នាដៃរបស់លោកឱ្យប្រជាជនកាន់តែរអាក្នុងការប្រព្រឹត្តអំពើអាក្រក់ទាំងពួង ដែលជាបាបកម្ម ត្រូវធ្លាក់ទៅនរករងទុក្ខផ្សេងៗអស់កាលរាប់ពាន់ឆ្នាំ។ លើសពីនេះ លោកយល់យ៉ាងច្បាស់អំពីបរិបទសង្គមអប់រំនាពេលនោះ ដោយការសិក្សាអប់រំប្រព្រឹត្តទៅនៅវត្តអារាម ហើយការសិក្សាគឺការរៀនទៅលើសាស្ត្រានេះឯង។ ដូច្នេះការអប់រំតាមវិធីនេះអាចមានប្រសិទ្ធភាពខ្ពស់។ ម្យ៉ាងទៀតក្រៅពីហត់នឿយក្នុងការងារ សាស្ត្រាល្បែង ជាប្រភពកម្សាន្តមួយដ៏សំខាន់ក្នុងអាន ឬស្តាប់តាមរយៈការនិទាន។ ម្ល៉ោះហើយ ការបញ្ចូលនូវបញ្ហាបុណ្យបាប សីលប្រាំរបស់លោកមានលក្ខណៈជ្រួតជ្រាបទៅក្នុងផ្នត់គំនិតខ្មែរសមនឹងពួកគាត់ជាពុទ្ធសាសនិកជនផងនោះ។

ទ្រឹស្តីប្រតិបត្តិនិច្ចសីលឬសីលប្រាំនេះ រមែងពុំស្ងួវចោលតាមរយៈការឆ្លុះបញ្ចាំងក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធសាសនានោះទេ។ ជាក់ស្តែងក្នុងរឿងមរណមាតាក៏បានលើកបង្ហាញផងដែរពីទស្សនៈនេះឱ្យមនុស្សយល់ដឹង ហើយប្រកាន់ខ្ជាប់។ តួយ៉ាងនៅពេលដែលកុដុម្ពីក៍ កាឡីនិងនាងចន្ទីត្រូវបានរត់គៀសខ្លួនពីអាជ្ញារបស់ព្រះបាទវិមលធម្មរាជ អ្នកទាំងបីបានទៅដល់ស្រុកមួយដែលស្រុកនោះពុំចែងឈ្មោះក្នុងបទបាលី ហើយត្រាច់ចរវង្វេង់ រហូតបានទៅជួបនឹងតាបសម្នាក់។ តាបសបានជួយសង្គ្រោះអ្នកទាំងបីដោយផ្តល់នូវឱវាទឱ្យខំរក្សាសីលប្រាំឱ្យបានខ្ជាប់ខ្ជួន ព្រមទាំងរក្សាទាននិងសីល ដូចបរិយាយថា៖

ពីថ្ងៃនេះទៅមុខ ចូរតាំងទុកចិត្តតម្កល់
សតិនឹកកុសល ខំរក្សាសីលទាំងប្រាំ។...
កើតមកជារូបរាង ធម៌ពីរយ៉ាងគួររក្សា
គឺទាននិងសីលា ជាពំនាក់រូបសព្វថ្ងៃ។...
បាណាតិបាតា ចាកកិរិយាញុំាងជីវិត
មនុស្សសត្វកុំប្រព្រឹត្ត ដោយកាយឬវាចាក្តី។
អទិន្នាទានា ប្រែតាមវារៈបាលី
ទ្រព្យគេច្រើនតិចក្តី វៀរកុំបីលួចប្លន់។
កាមេសុមិច្ឆា បរទារិកាប្រពន្ធ
វៀរចាកសេពមេថុន ជារបស់អ្នកដទៃ។
មុសាវាទាទៀង ពាក្យកុំល្បៀងភូតឡើយនៃ

វៀរចាកចាំសព្វថ្ងៃ ជាពំនាក់អង្គអាត្មា។

សុរាមេរយ មជ្ជប្បមាទដ្ឋានា

ឲ្យវៀរចាកកិរិយា គឺផឹកស្រាទឹកស្រវឹង។ (ទំ.១៤៨-១៤៩)

ដូចដែរយើងឃើញហើយថាតាបសបានទូន្មានកុដុម្ពីក៏យ៉ាងក្រាស់ក្រៃឱ្យលះបង់នូវគ្រឿងសៅហ្មងទាំងនេះ ហើយងាកមកចាប់យកកុសលធម៌វិញ។ ការដែលជួបតាបសនេះ មិនមែនជារឿងចៃដន្យនោះទេ ពោលគឺមកពីកុសលផលបុណ្យខ្លះដែលបានសាងមកពីជាតិមុននាំឱ្យគាត់បានជួបតាបសហើយស្រោចស្រង់ជីវិតបែបនេះ។ អ្នកទាំងបីបានប្រែក្លាយពីមនុស្សអាក្រក់មកជាមនុស្សល្អវិញ ដោយបានប្រកាន់ខ្ជាប់នូវអំពើជាកុសល របសុចរិតវិញ ហើយរស់នៅជាមួយគ្នាប្រកបដោយក្តីសុខវិញ។ ត្រង់នេះសឱ្យឃើញពីការប្រណិប័តន៍អំពើជាកុសល អាចកែប្រែជីវិតខ្លួនបានល្អ។ ក្នុងន័យម៉្យាងទៀត រាល់កំហុសទាំងឡាយដែលមនុស្សធ្វើខុស នៅតែអាចកែប្រែខ្លួនឱ្យបានជាមនុស្សល្អវិញ វាអាស្រ័យលើការតាំងចិត្ត និងការប្រតិបត្តិរបស់មនុស្ស។

### ៤.៥- តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្នុងវិធីតំណែងនិពន្ធវណ្ណកម្មខ្មែរ

អក្សរសិល្ប៍ពុទ្ធនិយមមិនត្រឹមតែ អប់រំចរិយាស្រ្តមនុស្ស និងបន្ធូរបន្ថយភាពតានតឹងទៅលើបញ្ហាសង្គមនាសម័យកណ្តាលនោះទេ តែអក្សរសិល្ប៍ពុទ្ធនិយមក៏ជាពុម្ពគំរូមួយសម្រាប់ស្នាដៃអក្សរសិល្ប៍ជំនាន់ក្រោយផងដែរ។ ពិពិធភាពនៃស្នាដៃមិនថា រឿងដែលយកចេញពីទសជាតក បញ្ញាសជាតក ឬប្រភេទនានាជាតក ហើយត្រូវអ្នកនិពន្ធតាក់តែងជាកាព្យក្តីនោះតែ សុទ្ធតែបង្ហាញពីតម្លៃ ទឹកដៃខាងផ្នែកតាក់តែងនិពន្ធគ្រប់ៗរឿងសម្រាប់អ្នកនិពន្ធជំនាន់ក្រោយក្នុងការយកជាគំរូនិងលំអានទៀតផង។

#### ក- កម្រងកែវ បទកាព្យ

ជាការពិតណាស់ បើគេនិយាយពីស្នាដៃបែបកម្រងកែវគឺគេនឹកទៅដល់រឿងព្រះវេស្សន្តរនេះឯងតែម្តង។ រឿងព្រះវេស្សន្តរបានបង្ហាញពីលក្ខណៈនៃការប្រើសំនួនបែបកម្រងកែវច្រើនជាងគេ។ តួយ៉ាងនៅក្នុងកណ្ឌជូជកលើកឡើងថា “ឯកោ ព្រាហ្មណោ មានព្រាហ្មណ៍ម្នាក់ឈ្មោះ ជូជកព្រឹទ្ធាចារ្យ រូបអន្ធការ ស្គមប្រដោង ច្រមុះកោង ទ្រូងសឹងតែឆ្អឹង សក់រឹងក្រញាង ពោះធំកំប៉ោង លោងសំពៀត ដំបៅត្រចៀកយុរយារក្រាស់ឃ្លង់ភ្លើង ជើងកាងដូចជើងសេក ភ្នែកស្រលៀងស្រឡី ...” [49] ។ ត្រង់នេះអាចជាពុម្ពគំរូមួយនៃការតាក់តែងសម្រាប់មនុស្សទូទៅដែលចង់សិក្សាកម្រងកែវនេះ។

ងាកចេញពីកម្រងកែវ ប្រភេទរឿងបញ្ញាសជាតក និងនានាជាតក ជាច្រើនត្រូវបានអ្នកកវីនិពន្ធបានយកទៅតាក់តែងជាបទកាព្យប៉ិនប្រសប់ គួរឱ្យយកគ្រាប់តាមមានចួន ផ្ទួន រណ្តំ ល្អងល្អាញណែងណងយ៉ាងពីរោះ។ តួយ៉ាងរឿងក្រុងសុភមិត្រ តាក់តែងជាកាព្យ បទកាកគតិ ព្រហ្មគីតិ ពំនោល ភុជង្គលីលា។ រីឯរឿងទេវន្ទ តាក់តែងឡើងជាបទកាកគតិសុទ្ធ។ ចំណែករឿង ភោគកុលកុមារ តែងជាបទកាកគតិ ព្រហ្មគីតិ ពំនោល ភុជង្គលីលា។ និងរឿងមរណមាតា

[49] ញ៉ុក ថែម, *មហាវេស្សន្តរជាតក*, កណ្ឌទី៥, បណ្ណាគារត្រៃរតន៍, ២០២២ ទំ. ១-២

តែងជាបទ កាកគតិ ព្រហ្មគីតិ និងបទពំនោល។ យើងឃើញហើយថា ការតាក់តែងរបស់កវីបានបញ្ចូលនូវវិធីសាស្ត្រយ៉ាងល្អឯកធ្វើឱ្យដំណើររឿងមានភាពរលូន និងប្រកបដោយសោភ័ណ។

**ខ- រូបបារូបារម្មណ៍**

នៅក្នុងការតាក់តែងនិពន្ធ លោកកវីបានប្រើវិធីសាស្ត្រក្នុងករាតែងតែងយ៉ាងល្អឯងទៅតាមសមត្ថភាពរបស់ខ្លួន។ ក្នុងនោះការប្រើប្រាស់រូបារូបារម្មណ៍នៅក្នុងកំណាព្យក៏ជាវិធីមួយធ្វើឱ្យអត្ថបទកាព្យមានភាពរស់រវើកណាស់ដែរ។ តួយ៉ាងនៅក្នុងរឿងភោគកុលកុមារ ឧកញ៉ាព្រះឃ្លាំងនង លោកពូកែរៀបរាប់សង្កេតពីរូបរាងកាយធ្វើឱ្យយើងហាក់ឃើញតួអង្គនោះពិតៗ ដូចលើកឡើងថា៖

នាងមួយឈរមុខ ផ្អៀងផ្អងថ្ងឹចថ្ងរ អំពើកែក្រាយ
ថ្កាល់ផូរផាត់ម្សៅ ពាក់អាវលាវស្វាយ ករកាន់ព្រះឆាយ
ព្រះសំអាងអង្គ។(ទំ.១២០)

រីឯអត្ថបទកាព្យរឿងទេវន្ទរបស់ អម្រឹតក្សត្រីម៉ុក វិញ លោកក៏បានបង្ហាញពីចំណាប់ចួនផ្នួនរណ្ដំ យ៉ាងល្អឯក ព្រមទាំងរៀបរាប់ព្រៃឈើយ៉ាងប៉ិនប្រសប់៖

ដកពរគ្រឡាត់ គ្រឡត់កំចាត់ គ្រលៀសកុំចាយ
សំម៉សម៉ូល ពពូលពពាយ ពពេលវល្លិ៍វាយ
ផ្កាផ្ចង់ពង្រ។(ទំ.៦៩)

ចំណែកនៅក្នុងរឿងមរណមាតា របស់ភិក្ខុអ៊ុកវិញ ក៏បានបង្ហាញពីការរៀបមុខម្ហូប បង្អែម ប្រកបដោយភាពទាក់ទាញ៖

ខ្លះធ្វើអន្សង់ ស្លនឹងផ្លែល្ហុង ខ្លះខួបង្កង
ខ្លះញាំពស់ប្រា ខ្លះភ្លាអង្រ្កង លូកភ្លក្សម្ដងៗ
ក្រែងសាបប្រៃពេក។(ទំ.៨៩)
ចំណីស្រស់ជា សុទ្ធសៀមសងខ្យា ចាហួយសារាយ
គ្រាប់ជីសតូវ តៅហ៊ូផ្លែអាយ ក្រនៀវកែវក្លាយ
រៀបរួចទុកទៅ។(ទំ.៩០)

**៤.៦- តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាក្នុងការផ្សព្វផ្សាយវប្បធម៌**

**ក- ជំនឿ**

ពិតណាស់ថាអក្សរសិល្ប៍ពុទ្ធនិយមមានគោលគំនិតចម្បងក្នុងការអប់រំមនុស្សឱ្យជឿទៅលើសាសនា ទ្រឹស្ដីពុទ្ធសាសនាជាដើម។ តែយ៉ាងណាមិញនៅពេលអ្នកនិពន្ធខ្មែរ លោកបានតាក់តែងនូវរឿងនោះ លោកក៏បានបញ្ចូលនូវលក្ខណៈជាតិរបស់ខ្មែររួមជាមួយផងដែរ ដូចជា ជំនឿលើអារក្សអ្នកតា សត្វ ប្រផ្នូលអ្វីមួយជាដើមនោះ។

នៅក្នុងរឿងទេវន្ទក៏បានបង្ហាញពីការជឿទៅលើទស្សន៍ទាយរបស់ហោរផងដែរ។ នៅពេលកំណើតរបស់ទេវន្ទមានអ័ព្ទ ភ្លៀង ខ្យល់ព្យុះបោកបក់ងងឹតលើសយប់។ ពេលប្រសូតបុត្រហើយ ហោរាក៏បានទស្សន៍ទាយពីជតារាសីរបស់ទេវន្ទថា៖

| | | |
|---|---|---|
| ព្រាហ្មណ៍ប្រាជ្ញសិល្បសព្វ | គន់គូរគ្រាន់គ្រប់ | អស់ឥតហ្មងសៅ |
| ទើបទូលបពិត្រ | មហាក្សត្រចមចៅ | រាជបុត្រនពហៅ |
| | គ្រប់លក្ខណ៍ប្រសើរ។(ទំ. ៤៧) | |

នេះសឱ្យឃើញពីទំនៀមនៃការទស្សន៍ទាយបែបព្រាហ្មណ៍និយមនេះមកលើសង្គមខ្មែរបច្ចុប្បន្នផងដែរ។ ត្បិតពេលមានអាសន្នអន់ក្រគេតែងទៅបូលជោគជាតារាសីមើល តើឡើងចុះ ខុសទាស់ត្រង់ណាជាដើមនោះ។

ជាមួយគ្នានេះដែរការជឿទៅលើប្រផ្នូលតាមរយៈសុបិន ពិតជាពេញនិយមក្នុងសង្គមខ្មែរតាំងពីបុរាណកាលមកម្ល៉េះ។ ក្នុងរឿងភោគកុលកុមារក៏បានបង្ហាញពីការជឿទៅលើប្រផ្នូលពោលគឺកំណើតរបស់ភោគកុលកុមារតែម្តង។ នារាត្រីនោះ ភរិយាភោគវុឌ្ឍីបានយល់សុបិនមានដើមចម្ប៉ាដុះក្នុងផើងមានត្រួតគ្នា លុះ១០ឆ្នាំផើងនោះក៏បែក។ លុះ៥ឆ្នាំបន្ទាប់ក៏លេចចេញផើងមាសថ្មី ហើយក៏បែកអណ្តែតត្រសែតនៅលើអាកាស មានក្លិនឈ្ងុយឈ្ងប ដូចលើកឡើង៖

| | |
|---|---|
| នាក្នុងរាត្រីកាល | នោះនាងនាថវរទេវី |
| ភរិយាភោគវុឌ្ឍី | យង់យល់សប្ដបូព៌និមិត្ត។(ទំ.១១) |

ដោយហេតុចង់ដឹងនាងក៏បានទៅរកហោរា គន់គូរហើយក៏ដឹងពីសប្តិនោះដោយ កូនប្រុសនោះបាន១០ឆ្នាំមាតានឹងស្លាប់ ហើយ១៥ឆ្នាំបិតានឹងស្លាប់ តែនឹងបានធ្វើធំ។ត្រង់នេះយើងចង់បង្ហាញពីផ្នត់គំនិតដែលជាប់មកដល់បច្ចុប្បន្នទៅនឹងការជឿលើសប្តិទាំង៧យ៉ាងគឺ សុបិននិមិត្ត ចក្ខុសម្ផស្ស ការបរិហារ ការបូល ការកកម្រើកសរសៃវិញ្ញាណ ការលេចឆ្លោឡើង សប្តិអាក្រក់ជាដើម។ ការជឿនេះបានកកើតទៅជាតម្រា ក្បួនកាត់សប្តិនិងនិងប្រាប់លេខឆ្នោតជាតិ តាមក្បួនតម្រាតន្ទទំនាយ[50] ទៀតផង។

បើយើងងាកក្រឡេកមកមើលរឿង មរណមាតាវិញ យើងឃើញថារឿងនេះបានជិតដាមជាប់សតិអារម្មណ៍របស់ប្រជាជនខ្មែរទៀតផង។ តួយ៉ាងនៅពេលម្តាយមរណមាតាបានស្លាប់ហើយទៅកើតជាត្រីដំរី ៖

| | |
|---|---|
| វាយវៃធ្លាក់ទឹកគ្រាំ | ហើយឈរច្រំនឹងច្រវា |
| មិនមាននឹកមេត្តា | មិនអាណិតកុលកេសី។ |
| នាងក្សីណក្ស័យជន្មា | ចាប់ជាតិជាត្រីដំរី |
| ហែលនៅជាប្រក្រតី | ទីកំពង់ទឹកនោះណា។ (ទំ. ៣០) |

យើងឃើញហើយថា ដោយសារតែនាងកុលកេសីស្លាប់ទៅក្លាយជាត្រីដំរីដូច្នោះហើយ ទើបធ្វើឱ្យផ្នត់គំនិតប្រជាជនខ្មែរពុំសូវនិយមចូលចិត្តពិសាត្រីដំរីនោះទេ ត្បិតគេថាវាជាមនុស្ស។

---

[50] *សូមមើលបន្ថែម* សម្ពម្មបញ្ញា, ***ក្បួនកាត់សប្តិ***, បោះពុម្ពសាជាថ្មីដោយ ស្រី ប៊ុនជន, ២០០៤

## ខ- ទំនៀមទម្លាប់ប្រពៃណី

ទោះបីជារឿងដែលយកចេញពីទសជាតកក្តី បញ្ញាសជាតកក្តី ក៏លោកកវីនិពន្ធមិនបានចម្លងយកទាំងដុលនូវលក្ខណៈ បរិយាកាស វប្បធម៌នៃរឿងនោះមកទាំងដុលដែរ។ លោកកវីនិពន្ធបានបញ្ចេញបញ្ចូលនូវលក្ខណៈជាតិ ជាអត្តសញ្ញាណជាតិរបស់ខ្លួនទៅក្នុងស្នាដៃនោះ សំដៅចែករំលែកនូវប្រពៃណីទំនៀមទម្លាប់របស់ខ្មែរយើងឱ្យនៅគង់វង្សផងដែរ។

យោងតាមប្រវត្តិអាពាហ៍ពិពាហ៍ខ្មែរ មានសម្មតិកម្មខ្លះថា ការរៀបអាពាហ៍ពិពាហ៍នេះយកតាមការរៀបចំផ្សំផ្គុំមង្គលការ ជាលីនិងក្រឹស្នា ក្នុងរឿងព្រះវេស្សន្តរនេះតែម្តង។ ម្យ៉ាងទៀតបើយោងតាមទម្រង់ការព្រះជ័យចេស្តា ឃើញថាការកាត់ខាន់ស្លានេះ គឺយកតាមការកាត់ថ្លៃក្រឹស្នា ដោយព្រះវេស្សន្តរឱ្យកាត់ ៥ម៉ឺន ២ពាន់ ៤រយតម្លឹងមាសនព្វគុណ[51]។ នេះសឱ្យឃើញថាតួនាទីរបស់រឿងព្រះវេស្សន្តរ មិនត្រឹមតែអប់រំ ផ្តល់ទស្សនៈល្អនោះទេ តែក៏បានផ្សាភ្ជាប់ ផ្សព្វផ្សាយនឹងសង្គមវប្បធម៌ប្រពៃណីខ្មែរក្នុងការរស់នៅផងដែរ។

ជាមួយគ្នានេះផងដែរ រឿងក្រុងសុភមិត្រក៏បានបង្ហាញពិធីអភិសេករបស់ក្រុងសុភមិត្រផងដែរ។ លោកកវីបានបង្ហាញពីក្បួនពិធីអភិសេកយ៉ាងល្អិតល្អន់ មានទាំងគ្រឿងរណ្តាប់ពិធី មានឆ្លិតបាំងសែង ភូតាន បៃមន់ សែនគ្វ័ន ចាមរជាដើម។ លើសពីនេះក៏បានបង្ហាញពីពិធីកម្មរបស់ព្រាហ្មណ៍ដូចលើកឡើងថា៖

| | | |
|---|---|---|
| ត្រៃស័ង្ខប្រគំ | សូរសព្ទរងំ | ទរទ្ងេភេរី |
| ទើបព្រាហ្មណ៍បុរោហិត | ចូលជិតពោធី | សែកសូត្រស្តុតី |
| | ចម្រើនជយា។( ទំ.៥៥) | |

ទន្ទឹមនឹងនេះ មុននឹងចាប់ផ្តើមរៀបមង្គលការក្នុងទំនៀមទម្លាប់ខ្មែរ មេបាលោកតែងទៅរកអាចារ្យចេះដឹងខាងពេលាមកគន់គូរ កំណត់ពេលាចេកមាសចេកប្រាក់កូនប្រុសស្រីថាអាចនឹងប្រព្រឹត្តទៅថ្ងៃណាខែណាឆ្នាំណាបាន។ អក្សរសិល្ប៍រឿងមរណមាតានេះក៏បានពាំនាំទំនៀមទម្លាប់នេះចែកចាយដល់អ្នកអានអ្នកស្តាប់ផងដែរ។ នៅពេលព្រះបាទវិមលធម្មរាជបាននាំនាងមរណមាតាមកនៅក្នុងព្រះបរមរាជវាំង ហើយក៏បានអភិសេកនាងឱ្យឡើងជាអគ្គមហេសី។ មុនព្រះរាជពិធីអភិសេកនេះ ត្រង់ក៏បានឱ្យព្រាហ្មណ៍ ហោរា រៀបគន់គូររកពេលាជ័យក្នុងការអភិសេកដូចលើកឡើងថា៖

| | | |
|---|---|---|
| ហោរាទាំងបួន | គន់គូររាល់ខ្លួន | ផ្ទៀងដួងជតា |
| ទិនកែទិនក្ស័យ | ជោគជ័យរាជា | សិទ្ធីជោគមហា |
| | សំរឹទ្ធិជ័យ។ | |
| ហ្លួងឈៀងហ្លួងឈរ | ចៀសទិនកាលមរណ៍ | ទំនួលប្រពៃ |
| បើកបានគ្រប់ពារ | ពេលាល្អក្រៃ | ទូលមកក្សត្រថ្លៃ |
| | ជ្រាបគ្រប់ប្រការ។ ( ទំ. ៨៣) | |

[51] លី សុវីរ, *ទំរង់ការ ព្រះជ័យចេស្តា*, បណ្ណាគារអង្គរ, ២០០៥, ទំ.៥

ជាការពិតណាស់ បើយើងនិយាយពីដំណើរជីវិតខ្មែរ មានការកើត ការ និងកប់។ ក្នុងពិធីបុណ្យសព ត្រូវបានគេបែងចែកជាបីផ្នែកធំៗគឺ មុនពេលស្លាប់ ក្រោយពេលស្លាប់ និង ក្បួនដង្ហែ និងរំលាយសព។កិច្ចពិធីទាំងនេះត្រូវបានគេធ្វើតាមប្រពៃណីតៗគ្នារៀងមក។ រីឯពិធីក្នុងការរំលាយសពវិញគេឃើញមាន៤យ៉ាងគឺ បោះចោលសពទៅក្នុងទន្លេ បូជាដោយភ្លើង យកសពទៅកប់ និងយកសពទៅដាក់ចោលក្នុងព្រៃស្មសាន ឱ្យសត្វស៊ី។[52] តាមរយៈរឿងភោគកុលកុមារក៏បានបង្ហាញពីលក្ខណៈនៃការរំលាយសពផងដែរ។ នៅពេលភោគវុឌ្ឍីជិតស្លាប់គាត់បានផ្ដាំឱ្យ ភោគកុលកុមារឱ្យរៀបចំរំលាយសពរបស់គាត់ដោយឱ្យយកសពទៅដាក់ព្រៃស្មសានឱ្យសត្វត្មាត ក្អែក ចឹងធីជាចំណី ដូចលើកឡើងថា៖

ថាបើអាពុកមរណ៍ ចូរអ្នកបបួលគ្នីគ្នា
មកសែងសពបិតា ទៅដាក់ដល់ព្រៃស្មសាន។
ឱ្យអស់សត្វត្មាតក្អែក ចឹកហួរហែកធីសោះឃ្លាន
ដងទឹកដាក់ឱ្យទាន ឱ្យអស់សត្វវាផឹកធី។( ទំ. ១៥ )

ជារួមយើងឃើញថា ត្បិតអត្ថន័យនៃអក្សរសិល្ប៍ពុទ្ធនិយមមានគោលគំនិតទៅសាសនាយ៉ាងណាក៏ដោយ ក៏អ្នកនិពន្ធមិនភ្លេចបញ្ចូលនូវរសជាតិខ្មែរទៅក្នុងផ្ទៃរឿង ឱ្យអ្នកអានអ្នកស្ដាប់បានស្គាល់ពីវប្បធម៌ខ្មែរដ៏ផូរផង់នេះផងដែរ។

**គ- សិល្បៈ**

ក្រៅពីផ្ដល់ពុទ្ធិចំណេះដឹង បង្ហាញពីជំនឿ ទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជន អក្សរសិល្ប៍ពុទ្ធនិយមក៏បានលើកតម្កើងនូវសិល្បៈវប្បធម៌ជាតិ ដូចជារបាំ ល្ខោន គ្រឿងតូរ្យតន្ត្រី គុនដាវលំពែង ល្បែងប្រជាប្រិយជាដើម។

រឿងក្រុងសុភមិត្រក៏បានបង្ហាញពីទម្រង់របាំ ល្ខោន មហោស្រព ព្រមទាំងល្បែង កីឡាគុនដាវផងដែរ ដូចលើកឡើងថា៖

របាំមនោហ៍រា រាំរេរកគ្នា ហាក់ហោះអាកាស
របាំល្ខោន ទន្ទោសពិលាស ហត្ថាវង់វាស
ដើរជិតតាមគ្នា។...
មានល្បែងប្រដាល់ ចេះគន់កាត់ការ ស្ទាក់ស្ទុះកែកាយ
លោលោតទៅមក៍ អួតអរវិលវាយ ស្រែកស្រួលសប្បាយ
លោលោតទៅទី។( ទំ. ៥៦ )

មិនខុសពីរឿងក្រុងសុភមិត្រ រឿងភោគកុលកុមារក៏បានបង្ហាញពីលក្ខណៈសិល្បៈខ្មែរផងដែរ។ តួយ៉ាងនៅពេលមង្គការព្រះនាងសុខុមាលទេវី និងភោគកុលកុមារ មានរបាំ ល្ខោន តន្ត្រី កីឡា និងមានឈ្មោះម្ហូបអាហារយ៉ាងសម្បូរបែប ដូចលើកឡើងថា៖

**-ម្ហូបអាហារ៖** ខ្លះបេះសាច់ទា សាច់មាន់ស្លជា ទឹកនំបញ្ចុក
ខ្លះខ្លប្រហើរ ខ្លះធ្វើហហ្មុក ធ្វើខ្យងសម្រុក

[52] ត្រឹង ងា,*អរិយធម៌ខ្មែរ ថ្នាក់បញ្ចប់*,បោះពុម្ពលើកទី៣,១៩៧៥,ទំ.១០៦

| | | | |
|---|---|---|---|
| | | បណ្ដោញភ្ញៀវផង។(ទំ.១១៨) | |
| **-តូរ្យតន្ត្រី៖** | ផ្លុំត្រែស័ង្ខសម | ស័ព្ទសូររងំ | ទទូងភេរី |
| | គោះគងប្រគំ | សូរសមតន្ត្រី | សាដៀវខ្លុយប៉ី |
| | | ស្រឡៃពាទ្យគង។ | |
| | ភ្លេងកនទ្រោនទ្រ | ចាប៉ីៗអ | គៃនកន្ទោងគង |
| | សម្ភោរនាត | ពិណពាទ្យឈឹងផង | ស្គរងាស្គរទង |
| | | ស្គរទូងស្គរទ័ព។(ទំ.១២៥) | |
| **-ល្ខោន របាំ៖** | រាំស្នែងទន្សោង | ស្ទូព្រ័ត្រយោលទោង | ផ្កាគូផ្កាពាយ |
| | ល្ខោនរបាំ | រេរាំកែកាយ | ច្រៀងច្រូចនិយាយ |
| | | ពីរោះសូរសម។(ទំ.១២៨) | |
| **-កីឡា៖** | ទាំងប្ដូនព្រះអង្គ | ស្ដេចយាត្រាត្រង់ | ទតល្បែងមហោស្រព |
| | លោតគុនពេនត្បាល់ | ប្រដាល់ប្រគប់ | ត្រីវិស័យសព្វ |
| | | កញ្ចេងជើតស្បែក។(ទំ.១២៧) | |

ជារួមការលើកយកមកឧទាហរណ៍នេះគ្រាន់តែជាចំណែកមួយនៃអក្សរសិល្ប៍ពុទ្ធនិយមប្រភេទសាស្ត្រាល្បែងប៉ុណ្ណោះ នៅមានរឿងដទៃទៀតដែលបានបង្ហាញពីវិស័យសិល្បៈជាតិក្នុងន័យផ្សព្វផ្សាយដល់អ្នកអានអ្នកស្ដាប់ឱ្យស្គាល់នូវ របាំ ល្ខោន តន្ត្រី កីឡាជារបស់ខ្មែរទាំងអស់នោះ។

### ៤.៧- តួនាទីអក្សរសិល្ប៍ពុទ្ធសាសនាមកលើសង្គមខ្មែរនាពេលបច្ចុប្បន្ន

#### ក- ធម្មទេសនា

គម្ពីរទេសជាតក ជាគម្ពីរមួយដែលរៀបរាប់រឿងទាំងដប់ជាតិរបស់ព្រះពុទ្ធអង្គមុនត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ។ រឿងទាំងនេះ គោលដើមជាភាសាបាលី មាននៅក្នុងគម្ពីរខុទ្ទកនិកាយជាតក មហានិបាត ដែលគេប្រកាន់ជឿថា ជាព្រះពុទ្ធវចនៈ ហើយនិងគម្ពីរជាតកដ្ឋកថា ដែលមានមកជាងពីរពាន់ឆ្នាំហើយ។[53]គម្ពីរទេសជាតកនេះ និយមគាំទ្រណាស់ពីសំណាក់ប្រជាពលរដ្ឋ និងតាមវត្តអារាម។ ពីបុរាណគេក៏បានធ្វើរយៈពេល ៧ថ្ងៃ៧យប់ដើម្បីស្ដាប់គម្ពីរទេសជាតកនេះ គឺ ថ្ងៃទី១ គេស្ដាប់ធម្មគោរព ថ្ងៃទី២ទី៣ទី៤ គេស្ដាប់ជាតកទាំង៩តៗគ្នា ហើយថ្ងៃទី៥គេស្ដាប់មហាជាតកគឺវេស្សន្តរជាតក ថ្ងៃទី៦ស្ដាប់បឋមត្រាស់ (ពុទ្ធប្បវត្តិ) ហើយយប់នោះត្រូវធ្វើពិធីពុទ្ធាភិសេក ស្អែកឡើងថ្ងៃទី៧សង្គាយនាបុណ្យ។ ចំណេរក្រោយមក គេក៏កាត់ឱ្យការទេសនាខ្លីសល់ត្រឹម ២ម៉ោងនេះបើតាមលោកគ្រូព្រះបុរត្ថិមវាសី អ៊ូ ចេវ វត្តលង្កា។

ជាក់ស្ដែងនាពេលបច្ចុប្បន្ន ពិធីបុណ្យទេសនាមហាជាតក៍នៅតែបន្តធ្វើតាមទីវត្តអារាមមួយចំនួនផងដែរ។ តាមបណ្ដាវត្តអារាមក្នុងខេត្តសៀមរាប គេតែងជ្រើសរើសពេលសម្រាប់ធ្វើពិធីទេសន៍មហាជាតិនេះក្នុងពេលណាមួយពីខែ

[53] ឈឹម ស៊ុម,*សង្ខេបទសជាតក៍*, បណ្ណាគារ សុមនសុវត្ថិ លេខ៤២, ភ្នំពេញ, ១៩៦២

មិគសិរដល់ខែមាឃអាស្រ័យតាមការរើសរកថ្ងៃកុំឲ្យជាន់គ្នារវាងវត្តមួយនិងវត្តមួយ។ តែបើយកឧទាហរណ៍នៅទីផ្សេងវិញ ដូចជានៅតំបន់ភ្នំវល្លិ៍ក្នុងខេត្តកំពតជាដើម គេច្រើនធ្វើនៅពេលដែលរដូវភ្លៀងជិតចូលមកដល់។ តាមធម្មតាពុទ្ធបរិស័ទក្នុងភូមិចំណុះជើងវត្តចែកគ្នាកាន់វេនតាមកណ្ឌនីមួយៗដែលតំណាងរបស់ខ្លួនចាប់ឆ្នោតបាន (ឆ្នោតនេះហៅថា «ស្លាក» ឬតាមបាលីថា «សលាកបត្ត»)[54]។

### ខ. សិល្បៈ

**-ល្ខោន**

រឿងនៅក្នុងអក្សរសិល្ប៍ពុទ្ធនិយមក៏បានក្លាយទៅជាល្ខោនយ៉ាងរស់រវើកសម្រាប់ប្រជាជនទស្សនាផងដែរ។ តួយ៉ាងនៅល្ងាចថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានអញ្ជើញចូលរួមទស្សនាល្ខោនបុរាណ រឿងមហាវេស្សន្តរជាតក ក្នុងឱកាសរំលឹកខួប៤៨ឆ្នាំ នៃការចូលទីវង្គតរបស់ព្រះសង្ឃរាជ ជួនណាត។ ល្ខោនបុរាណ រឿងមហាវេស្សន្តរជាតកនេះ ចូលរួមរួមសម្តែងដោយ លោកគ្រូ អ្នកគ្រូ អតីតសិល្បករជំនាន់មុននិងបច្ចុប្បន្ន ប្រាំជំនាន់ចំនួន១០៩នាក់ រួមគ្នាធ្វើឱ្យរស់ឡើងវិញនូវទស្សនីយភាពរឿង មហាវេស្សន្តរជាតក ដើម្បីរំឭកពីល្ខោនបុរាណខ្មែរ ជាពិសេសរក្សាអោយបានគង់វង្ស។

លើសពីនេះវិទ្យុជាតិនិងទូរទស្សន៍ជាតិក៏បានចូលរួមចំណែកក្នុងការតម្លើងជាល្ខោននិយាយ ល្ខោនយីកេ ល្ខោនបាសាក់ជាដើមដែលបានយកចេញពីអក្សរសិល្ប៍ពុទ្ធនិយមផងដែរ។ ការសម្តែងមានដូចជាការតម្លើងល្ខោនយីកេរឿងកាកី រឿងមរណមាតា... ល្ខោនបាសាក់រឿងទេវន្ទ រឿងព្រះជិនវង្ស រឿងលក្ខិណវង្ស រឿងវរវង្ស សូរវង្ស រឿងហង្សយន្ត ... ល្ខោននិយាយមានរឿងសព្វសិទ្ធ រឿងសុបិនកុមារ រឿងកាកី... រីឯល្ខោនព្រះរាជទ្រព្យ ឬរបាំបុរាណ មានរឿងមរណមាតា រឿងសព្វសិទ្ធិ រឿងសុវណ្ណហង្ស រឿងព្រះសុធនកែវមនោរា ព្រះចន្ទគោរព...ជាដើម។

**-គំនូរ ចម្លាក់**

បើនិយាយពីវិស័យគំនូរវិញ អក្សរសិល្ប៍ពុទ្ធនិយមបានរាតទីលើវិស័យនេះជាខ្លាំង។ តាមរយៈគំនូរលើជញ្ជាំងព្រះវិហារ រៀបរាប់ពីរឿងទសជាតក រឿងក្នុងបញ្ញាសជាតក និងមានរឿងក្នុងនានាជាតកផងដែរ។ តួយ៉ាងយើងឃើញមានគំនូររឿងកាកីនៅលើបង្អួចនៃសារមន្ទីរជាតិ។ សារមន្ទីរជាតិត្រូវបានកសាងឡើងនៅក្នុងឆ្នាំ ១៩១៧ នាសម័យអាណានិគមបារាំងមកលើព្រះរាជាណាចក្រកម្ពុជា (១៨៦៣-១៩៥៣) ដែលមានស្ថាបត្យករ ជនជាតិបារាំងឈ្មោះ ហ្សកហ្ស៊ូសលីយេ (George Groslier)... វាជាស្នាដៃរបស់វិចិត្រករខ្មែរដែលជា គ្រូ និងជា សិស្សរបស់សាលានេះដែលមានដូចជារឿងនាងកាកី ឬ រៀមកេរ្តិ៍ជាដើម( កាលពីសម័យ នោះអាគារនោះជាសារមន្ទីរផងនិង ជាសាលាបណ្តុះបណ្តាលផង) [55]។

---

[54] https://www.yosothor.org/publications/khmer-renaissance/chapter-two/pithy-puth-tes-moha-jea-duk.html

[55] http://www.mcfa.gov.kh/site/detail/29#.Yhyv-uhBy3A

បើនិយាយពីចម្លាក់វិញ យើងក៏អាចឃើញស្ថាបត្យករខ្មែរបានឆ្លាក់រឿងព្រះជិនវង្សលើលើបាំងសាចនាំវត្តព្រះប្រសព្វ។ ចម្លាក់ព្រះជិនវង្សនេះសាងចប់នៅព.ស.២៤៦៩ ពោលគឺនៅគ.ស. ១៩២៦ [56]។ រីរឿងព្រះជិនវង្សនេះក៏បានវិលេចជាគំនូរផងដែរនៅវត្តកៀនស្វាយក្រៅ។ ក្នុងនោះ សាលាឆាន់វត្តកៀនស្វាយក្រៅមានគូរជារឿងព្រះជិនវង្សនៅលើបន្ទះក្តារ ដែលជាហប់របស់សាលា ។ នៅក្នុងឆ្នាំ១៩៨២មានការសិក្សាលម្អិតពីគំនូរនេះ ដោយលោក Michel Jacq-Hergoualc'h ផ្សព្វផ្សាយដោយសាលាបារាំងចុងបូព៌ា នៅក្រុងប៉ារីស៍[57]។

**-ភាពយន្ត**

រីឯវិស័យភាពយន្តវិញយើងឃើញមានអក្សរសិល្ប៍ពុទ្ធនិយមក្លាយមួយចំនួន ត្រូវបានអ្នកដឹកនាំយកទៅថតតាំងពីទសវត្សទី៦០ រហូតដល់បច្ចុប្បន្នមួយចំនួនមានដូចជា៖

- រឿងភោគកុលកុមារ(ដឹកនាំរឿងដោយលោកឈា នុ ផលិតកម្មពេជ្រភាយន្តក្នុងទសវត្ស៦០)
- រឿងខ្យងស័ង្ខ(ត្រូវបានផលិតនៅឆ្នាំ ១៩៦៦ដឹកនាំរឿងដោយលោក ឡុង ស៊ីដេត)
- រឿងសុវណ្ណហង្ស(ត្រូវបានផលិតនៅឆ្នាំ១៩៦៧ ដោយផលិតករ លោក អ៊ីវ៉ង់ ហែម)
- រឿងកាកី(ត្រូវបានផលិតនៅឆ្នាំ ១៩៦៧ ដោយផលិតករ ប៊ីវ ឆៃលាង)
- រឿងពុទ្ធិសែន នាងកង្រី(ត្រូវបានផលិតនៅឆ្នាំ ១៩៦៨ ដោយផលិករលោកលី ប៊ុនយីម)
- រឿងមរណមាតា(ត្រូវបានផលិតនៅឆ្នាំ ២០០៤ ដឹកនាំរឿងដោយ លោកហ៊ួ សំអាង)
- រឿងចៅស្រទបចេក (ដោយចាងហ្វាងលោក ប្រសើរ ខៀវ ទើបថតនាស.វ.ទី២១)
- រឿងលក្ខិណវង្ស(ស្រាវជ្រាវដោយលោកយ៉ុន ប៊ុនឈឿនទើបថតនាស.វ.ទី២១)
- រឿងទិព្វសង្វារ(ថតនៅឆ្នាំ២០០៥ ដឹកនាំរឿងដោយ លោកយ៉ុន ប៊ុនឈឿន)
- រឿងភោគកុលកុមារ(ថតនៅឆ្នាំ២០០៦ ដឹកនាំរឿងដោយ លោក ជា វណ្ណា)
- រឿងសព្វសិទ្ធ(ថតនៅឆ្នាំ២០២០ ជាខ្សែភាពយន្តភាគរបស់ទូរទស្សន៍PNN)
- រឿងមរណមាតា (ថតឆ្នាំ២០២២ ជាខ្សែភាពយន្តភាគរបស់ទូរទស្សន៍CTN PNN)ជាដើម។

**-ចម្រៀង**

រីឯបទចម្រៀងមួយចំនួនក៏បានផលិតចេញពីលំនាំនៃរឿងល្បែងផងដែរដូចជានៅក្នុងរឿងព្រះលក្ខិណវង្ស មានបទស្នេហាព្រះព្រះលក្ខិណវង្ស មន្តស្នេហ៍នោត ទំនួញនាងព្រាហ្មកេសរ ច្រៀងដោយ អ្នកស្រីហ៊ឹមស៊ីវន អ្នកនាងទូចស្រីនិច្ច លោកហេងប៊ុនលាភ។ ចម្រៀងក្នុងរឿងភោគកុលកុមារ បទនាងចម្ប៉ាវង្សី និពន្ធបទភ្លេងនិងទំនុកច្រៀង ស៊ិនស៊ីសាមុត និងច្រៀងដោយរស់សេរីសុទ្ធា បទទំនួញភោគកុលកុមារ និពន្ធបទភ្លេងនិងទំនុកច្រៀងស៊ីនស៊ីសាមុត ច្រៀងដោយស៊ិនស៊ីសាមុត។ រឿងព្រះសុធននាងកែវមនោរាហ៍ ជាកម្រងបទចម្រៀងមានដូចជា បទក្រសាលស្រះស្រង់ ដោយ ស៊ីវន សាវី ស្រីនីន ...។ រីឯរឿងព្រះជិនវង្សដែលផលិតកម្មអង្គរបានធ្វើទៅជាបទចម្រៀង ដោយដឹកនាំដោយអ្នក

---

[56] អាំងជូលាន,ព្រាប ចាន់ម៉ារ៉ា, ស៊ីយ៉ុន សុភារិទ្ធ,គង់ វីរៈ, ហេងសុផាឌី, ជីវដ្ឋា, សួង សុខរ៉ូ *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១៥, ២០២០, ទំ.៥៧

[57] -ដ-,ទំ.៥៤

ស្រី អីវ៉ែត ស ប្រមាណ៤ម៉ោងជាង ពោលគឺមួយចប់រឿងព្រះជិនវង្សតែម្តងមានបទចម្រៀងដូចជា បទផ្សំផ្គុំបុត្រយើង នាងទាសីល្ងង់ជាដើម។ ជាមួយគ្នានេះរឿងសង្ខសិល្បជ័យ ក៏ត្រូវបានផលិតកម្មហង្សមាស បានធ្វើជាវីដេអូចម្រៀង មានរយៈពេលមួយម៉ោងជាង មួយចប់សាច់រឿងតែម្តង។ តួយ៉ាងដូចជាបទទំនួញសេនាកុត្តរាជ អាសូររៀមផង ទំនួញ នាងបទុមា បណ្តាំនាងកែវសុមន្ទា សង្គ្រាមបាស្កាជាដើម។

**គ. នរនាម**

មកដល់ពេលបច្ចុប្បន្ន ឈ្មោះរបស់តួអង្គក្នុងអក្សរសិល្ប៍ពុទ្ធនិយមមួយចំនួនត្រូវបានគេយកទៅដាក់ឈ្មោះឱ្យ បុត្រធីតា ដូចជា មទ្រី ជាលី ក្រឹស្នា មុជ្ជលិន កេសរមន្ទា សកុណា កេសនី...ជាដើម។ ការដែលដាក់ឈ្មោះនេះ មកពី យល់ពីអត្ថន័យនៃឈ្មោះ រួមជាមួយសកម្មភាពរបស់តួអង្គដែលនាំកើតមានសិរីសួស្តីក្នុងគ្រួសារផងដែរ។

## សន្និដ្ឋាន

ជារួមមក តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរពិតជាបានចូលរួមយ៉ាងសកម្មជួយដល់ប្រជាជនខ្មែរក្នុងកំឡុងពេលកម្ពុជាធ្លាក់ក្នុងភ្នក់ភ្លើងនៃសង្គ្រាមដ៏វែងអន្លាយ។ ការឈានចូលមកដល់របស់អក្សរសិល្ប៍ពុទ្ធនិយមនេះបានបន្ធូរអារម្មណ៍ ធ្វើឱ្យមនុស្សរសាយនូវកង្វល់ទាំងឡាយដែលញាំញីដោយវិបត្តិសង្គម។ ពិតណាស់ថាអក្សរសិល្ប៍ពុទ្ធនិយមបានបណ្ដុះនូវទស្សនៈគំនិតលើឱ្យជឿលើពុទ្ធសាសនាក្ដី តែរឿងពុទ្ធនិយមបានចូលរួមចំណែកដ៏សំខាន់ក្នុងកិច្ចការអប់រំចរិយាសាស្ត្រ សីលធម៌ គុណធម៌របស់មនុស្សនាសម័យ។ ត្រង់នេះពុទ្ធសាសនាហាក់បីដូចជាវាំងននមួយតែបើយើងបើកវាំងនននោះចេញយើងនឹងឃើញតម្លៃទស្សនវិជ្ជាដ៏ច្រើនសម្បូរបែបសម្រាប់អប់រំមនុស្សដូចជាបញ្ហាការឆ្ពោះទៅរកសន្តិភាពជាដើម។ លើសពីនេះអក្សរសិល្ប៍ពុទ្ធនិយមក៏បានបង្កប់និងបង្ហាញពីលក្ខណៈជាតិដ៏ច្រើនសម្បូរបែប មានដូចជាជំនឿ ទំនៀមទម្លាប់ ប្រពៃណីរបស់ក្សត្រ របស់អ្នកស្រុកជាដើម។ មួយវិញទៀតអក្សរសិល្ប៍ពុទ្ធនិយមនេះក៏ជាពុម្ពគំរូមួយដ៏សំខាន់នៃការតាក់តែងនិពន្ធសម្រាប់កវីនិពន្ធជំនាន់ក្រោយយកជាគំរូផងដែរ។

យើងឃើញហើយថា តួនាទីអក្សរសិល្ប៍ពុទ្ធនិយមក្រោយសម័យអង្គរនេះពិតជាមានតម្លៃខ្លាំងក្លាទាំងផ្នែកស្មារតី និងពុទ្ធិ។ ភាពចម្រុះពណ៌នេះហើយទើបធ្វើឱ្យផលិតករបានកែច្នៃរឿងទាំងនោះទៅជាសិល្បៈ ល្ខោន គំនូរភាពយន្ត ចម្រៀងជាដើម ដើម្បីបន្តយកទស្សនៈអប់រំនិងពិពិធភាពនៃស្នាដៃនោះមកបង្ហាញដល់កូនខ្មែរជំនាន់ក្រោយ។ម៉្យាងទៀតវិស័យសោតទស្សន៍ គួរព្យាយាមបញ្ចូលនូវស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមនានា ដែលបានសម្ដែងជាភាពយន្តក្ដីជាល្ខោនក្ដីនៅក្នុងកម្មវិធីរបស់ខ្លួន។ ត្រង់នេះ វាអាចចូលរួមជួយផលិតករ ក៏ដូចជាសិល្បករក្នុងបំពេញនូវការងារផ្នែកវប្បធម៌ជាតិ។ ម៉្យាងនេះវាក៏បានលើគុណតម្លៃនៃអក្សរសិល្ប៍ពុទ្ធនិយមឱ្យយុវជនយល់ដឹងនឹងត្រងត្រាប់យកជាបទពិសោធទៀតផង។ មួយវិញទៀត ផលិតករភាពយន្តអាចទាញយករឿងចេញពីគម្ពីរផ្សេងៗក្នុងការថតជាខ្សែភាពយន្តព្រោះគ្រប់រសជាតិនៃជីវិតបានឆ្លុះបញ្ចាំងតាមរយៈខ្សែរឿងដ៏ល្អរបស់កវីជំនាន់មុន។ មិនត្រឹមតែប៉ុណ្ណោះ វាបានលើកតម្លៃអក្សរសាស្ត្រជាតិ ជាជាងទៅចម្លងរឿងពីបរទេសមកនាំឱ្យគេមាក់ងាយនិងតិះដៀលគំនិតរបស់ជនជាតិយើងទៀតផង។

# គន្ថនិទ្ទេស


❖ កុល ផេង, *ព្រះសុវណ្ណសាមជាតក*, ពិស្តារ,ភ្នំពេញ, ២៥៦០
❖ កេង វ៉ាន់សាក់, ***ទិដ្ឋភាពខ្លះៗនៃអក្សរសិល្ប៍ខ្មែរ***, ប្រែសម្រួលដោយ សេន សេង, បោះពុម្ពលើកទី១, ភ្នំពេញ, ២០១៦
❖ គូ សុភាព, ***សីលធម៌ព្រះពុទ្ធសាសនា***, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ២០០៨
❖ ឃិន យ៉ង់, ***អក្សរសិល្ប៍តន្ត្រី,*** ស.ភ.ភ.ព. ២០១៥
❖ ឃីង ហុកឌី, ***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*** ,បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៣
❖ ឃីង ហុកឌី, ***មាលីបទ អក្សរសិល្ប៍ខ្មែរសតវត្សទី១៩*** ,បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៣
❖ ឃីង ហុកឌី, ***ភោគកុលកុមារ*** ,បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៥
❖ ជីវតាក្វាន់, ***ទឹកដីនិងប្រពៃណីអ្នកស្រុកចេនឡា,*** រាជបណ្ឌិត្យសភាកម្ពុជា, ភ្នំពេញ, ២០១៣
❖ ឈឹម ស៊ុម,***សង្ខេបទសជាតក៍***, បណ្ណាគារ សុមនសុវត្ថិ លេខ៤២, ភ្នំពេញ, ១៩៦២
❖ ឈុន គឹមអៀក, ***ទ្រឹស្តីកម្មផល*** ,បោះពុម្ពលើកទី២, ២០០១
❖ ញាន គឿន ស៊ិន សុវណ្ណនិ, ***លំអានទំនៀមខ្មែរបុរាណ*** ភាគ៤, ភ្នំពេញ, ២០១៦
❖ ញ៉ុក ថែម, ***មហាវេស្សន្តរជាតក***, បណ្ណាគារត្រៃរតន៍, ២០២២
❖ ត្រឹង ងារ,***អរិយធម៌ខ្មែរ ថ្នាក់បញ្ចប់***,បោះពុម្ពលើកទី៣,១៩៧៥
❖ ***ទេវន្ទ*** ,ចងក្រងដោយនិស្សិតមួយក្រុម, ២០១៦
❖ ទឹម សឿន, ***សីល៥ជាធម៌របស់មនុស្ស***, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ២០០២
❖ ធ សោ, ***សិក្សារឿងព្រះវេស្សន្តរជាតក***, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ១៩៩៤
❖ ធ សោ, ***ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ*** ,ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ ១៩៩៤
❖ ប៊ុត សាវង្ស, ***ស្ត្រីក្នុងព្រះពុទ្ធសាសនា***, ២៥៥១
❖ ប្រសិទ្ធ វីជីវី, ***ល្ខោនក្បាច់បុរាណ រឿងព្រះជិនវង្ស***, សារណាបញ្ចប់បរិញ្ញាបត្រដឹកនាំរឿង, ស.ភ.វ.ស,២០០៩
❖ ប៉ាង ខាត់, ***ប្រវត្តិពុទ្ធសាសនានៅប្រទេសកម្ពុជា*** ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦១
❖ ពុទ្ធសាសនបណ្ឌិត្យ, ***វចនានុក្រមខ្មែរ ភាគ១ភាគ២*** ,ភ្នំពេញ, ១៩៦៨
❖ ពុទ្ធសាសនបណ្ឌិត្យ,***សុបិនកុមារ***, ភ្នំពេញ, ព.ស. ២៥០២
❖ ពុទ្ធសាសនបណ្ឌិត្យ,***ទិព្វសង្វារ*** ,ភ្នំពេញ, ១៩៦៣
❖ ពុទ្ធសាសនបណ្ឌិត្យ,***សង្ខសិល្បជ័យ*** ,ភ្នំពេញ, ១៩៦៦
❖ ពុទ្ធសាសនបណ្ឌិត្យ ***ហង្សយន្ត*** ភ្នំពេញ ១៩៨៤
❖ ពុទ្ធសាសនបណ្ឌិត្យ,***ពុទ្ធិសែននាងកង្រី*** ,ភ្នំពេញ, ១៩៧២

❖ ពុទ្ធសាសនបណ្ឌិត្យ,*ច្បាប់ផ្សេងៗ*,ភ្នំពេញ, ១៩៧៥
❖ ពន់ ឆាយ, *អក្សរសិល្ប៍ប្រៀបធៀប ខ្មែរ - ឥណ្ឌា*,ភ្នំពេញ ២០១៣
❖ ពៅ សាមី,*មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ ភាគ១-២-៣*,គ្រឹស្ថានបោះពុម្ព សុកមង្គល, ភ្នំពេញ ,២០១២
❖ ព្រះធម្មបញ្ញា អ៊ុក, *មរណមាតា*,ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥០៧
❖ ព្រះមហា ជា សុខ, *ពុទ្ធសាសនា ធ្វើប្រយោជន៍ដល់សង្គមមនុស្សអ្វីដែរ?* ,ពុទ្ធសាសនបណ្ឌិត្យ ១៩៦៦
❖ ព្រះអរិយគាមុនីហ៊ីង, *ព្រះជិនវង្ស*,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៤
❖ ម៉ុញ សារី, *វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ*, មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាពកម្ពុជា, ២០១១
❖ ម៉ែម ទីន មន, *កម្ម អ្នកសាងលោកពិត*,រោងពុម្ពម៉េងហាវ, ភ្នំពេញ, ២០១៥
❖ យ៉ាន់ សុភី, *ល្ខោនក្បាច់បុរាណ ព្រះនាងចំប៉ាថោង*, សារណាបញ្ចប់បរិញ្ញាបត្រដឹកនាំរឿង, ស.ភ.វ.ល,២០០៥
❖ យស ងិន, *ស្រទបចេក*,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៧
❖ លាង ហាប់អាន, *ប្រវត្តិអក្សរសាស្ត្រខ្មែរ*, បណ្ណាគារ គិម អេងលេខ, ភ្នំពេញ, ១៩៦៧
❖ លាង ហាប់អាន, *សិក្សាអត្ថបទអក្សរសិល្ប៍ខ្មែរ* ភាគ១, ១៩៦៦
❖ លឹម ហាក់, *សិក្សាអំពីប្រវត្តិ និងបច្ចេកទេសគម្ពីរខ្មែរ*,សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យា,១៩៩៥
❖ លី សុវីរ, *អរិយធម៌ខ្មែរទាក់ទងនឹងអក្សរសិល្ប៍បែប ពុទ្ធនិយម បែបព្រហ្មនិយម បែបខ្មែរនិយម*, ភ្នំពេញ, បោះពុម្ពលើកទី២, ២០០២
❖ លី សុវីរ, *ទំរង់ការ ព្រះជ័យចេស្តា*, បណ្ណាគារអង្គរ, ២០០៥, ទំ.៥
❖ លី ធាមតេង, *អក្សរសាស្ត្រខ្មែរ*,១៩៦០
❖ លាស់ ឡាយ, *ប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធបរិនិព្វាន*, ២៥០៨
❖ វង់សុធារ៉ា ណុបសុខា, *ប្រវត្តិសាស្ត្រខ្មែរ*, ២០១៣
❖ សុខ ខឿន, *ល្ខោនក្បាច់បុរាណ រឿងសង្ខ័សិល្បជ័យ*, សារណាបញ្ចប់បរិញ្ញាបត្រដឹកនាំរឿង, ស.ភ.វ.ស,២០០៤
❖ ស៊ុំ ឈុំប៊ុន, *ឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ឯកទេសអក្សរសិល្ប៍*, ២០០៣
❖ សោម សុមុនី, *ឯកសារមេរៀនសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ ឯកទេសអក្សរសិល្ប៍*, ២០០៣
❖ សម ញាណ, *ប្រវត្តិពុទ្ធសាសនា ដែលផ្សាយចូលមកប្រទេសកម្ពុជា* ,១៩៥៧
❖ សេង សុវណ្ណដារ៉ា, *អម្រឹតក្សត្រី ម៉ុក កវីនិពន្ធខ្មែរនាសតវត្សទី១៩* ,និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ ស.ភ.ភ.ព. ២០១៩
❖ សេង សោភា, *សាស្ត្រាល្បែង*, សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៣ មុខជំនាញអក្សរសិល្ប៍ រាជបណ្ឌិត្យសភា, ២០០៤
❖ ស្រី. ធម្មានន្ទ, *អ្វីខ្លះពុទ្ធសាសនិកជឿ*,ពុទ្ធសាសនាបណ្ឌិត្យ, ២០១៩
❖ សម្មម្មបញ្ញោ, *ក្បួនកាត់សព្ទ*, បោះពុម្ពសាជាថ្មីដោយ ស្រី ប៊ុនដន, ២០០៤

- *ហង្សយន្ត*, ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥៥២
- ហ៊ីនភក្តីអក្សរតន់ *សព្វសិទ្ធិ* ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៩៧
- ហួត តាត, *ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប*, ពុទ្ធសាសនបណ្ឌិត្យ, ២៩៧០
- ហ៊ុន ជារិទ្ធ, *អរិយមគ្គនៃអង្គ៨តាមរយៈប្រជុំរឿងព្រេងខ្មែរ*, និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ ,២០១៨
- ហង់ជួន ណារ៉ុន, *វិភាគទានការសិក្សាអក្សរសិល្ប៍ខ្មែរ ក្នុងការលើកកម្ពស់អំណាននៅកម្ពុជា*, គ្រឹះស្ថានបោះពុម្ពស៊ីប៉ា, ២០១៩
- ឡុង សៀម, *សាកល្បងសិក្សារឿងមហាវេស្សន្តរ*, ការផ្សាយរបស់អ្នកនិពន្ធ
- អាំងជូលាន,ព្រាប ចាន់ម៉ារ៉ា, ស៊ីយ៉ុន សុភារិទ្ធ,គង់ វីរៈ, *កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ*,លេខ១-១៦
- អៀន ហ៊ៃវីស, *ប្រវត្តិនិងការប្រេតិបត្តិព្រះពុទ្ធសាសនានៅកម្ពុជាភាគ១*, នគរវត្ត, ២០១០
- អ៊ុម ស៊ុម, *គម្ពីរស្លឹករឹត*, ចុះផ្សាយក្នុងទស្សនាវដ្ដី កម្ពុជសុរិយា លេខ ៤៨, ១៩៩៤
- អ៊ុក ចួន, *ចំនោទនិងសំរាយបញ្ហា ក្នុងអក្សរសិល្ប៍ខ្មែរ* ,សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១៩៨៨
- អ៊ុំ មារឌី, *អត្ថបទវិជ្ជា រឿងក្រុងសុភមិត្រ* ,ភ្នំពេញ, ១៩៦៣
- ឧកញ៉ាកោសាធិបតី កៅ, *ក្រុងសុភមិត្រ* ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦០
- ឧកញ៉ា ព្រះឃ្លាំងនង, *ភោគកុលកុមារ* ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៦
- ឧកញ៉ាសុភាធិបតី អ៊ុក, *ខ្យងស័ង្ខ* ,ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦០
- https://www.yosothor.org/
- http://5000-years.org/
- https://khmerarchaeo.wordpress.com/
- https://www.efeo.fr/base.php?s=10
- https://www.academia.edu/
- https://www.pdfdrive.com/
- https://ams.com.kh/khmercivilization/
- http://www.mcfa.gov.kh/